**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**


## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍរបស់សហគមន៍នេសាទ
# ត្រពាំងសង្កែ

កម្មសិក្សាចាប់ពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៩

ឈ្មោះស្ថាប័ន៖ **សហគមន៍នេសាទត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត**


តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **ឡុង សុខជា**

**សុត ឌុន**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ពហុ**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ៣

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេររបាយការណ៍ ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ឡុង សុខជា** និង **សុត វុន** ដែលជានិស្សិតថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ឆ្នាំទី៤ ជំនាន់ទី៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច។ តាមរយៈការណែនាំ និងផ្តល់យោបល់ជាច្រើន ដែលជួយឱ្យរបាយការណ៍បញ្ចប់ការសិក្សារបស់ពួកយើងខ្ញុំទទួលបានជោគជ័យជាស្ថាពរ។

សូមសំដែងនូវការគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- លោកឪពុក អ្នកម្តាយ នូវគុណដ៏ធំគ្មានអ្វីប្រៀបស្មើបាន គឺលោកបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងទូន្មានប្រៀនប្រដៅដល់ពួកយើងខ្ញុំ។ ជាពិសេសនោះ លោកបានលះបង់គ្រប់សព្វបែបយ៉ាងដោយមិនគិតពីពេលវេលា និងការលំបាកអ្វីឡើយដើម្បីឱ្យពួកយើងខ្ញុំបានសិក្សារៀនសូត្ររហូតមកដល់បច្ចុប្បន្ននេះ។
- ឯកឧត្តមសាកលវិទ្យាធិការ លោក លោកស្រី សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោកគ្រូ និងអ្នកគ្រូ ព្រមទាំងសាស្រ្តចារ្យទាំងអស់នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលបានខិតខំប្រឹងប្រែង យកចិត្តទុកដាក់ បង្ហាត់បង្រៀន ផ្តល់នូវចំណេះដឹង និងបទពិសោធន៍ល្អៗគ្រប់បែបយ៉ាងដល់ពួកយើងខ្ញុំ។
- សូមថ្លែងអំណរគុណជាពិសេសដល់ លោកសាស្រ្តាចារ្យបណ្ឌិត **ឈុន ពហុ** ដែលបានខិតខំផ្តល់ជាមតិយោបល់ ជួយពន្យល់ណែនាំ និងព្រមទាំងចំណាយពេលសម្រាប់ការកែតម្រូវ និងបញ្ចេញគំនិតសំរាប់ការច្នៃប្រឌិតបន្ថែមទៀត ដើម្បីធ្វើឱ្យការស្រាវជ្រាវរបស់ពួកយើងខ្ញុំកាន់តែប្រសើរឡើងរហូតដល់បញ្ចប់របាយការណ៍នេះ។
- ឯកឧត្តម លោក លោកស្រី ដែលជាមន្រ្តីរដ្ឋបាលជលផល ខេត្តកំពត ដែលបានជួយសម្របសម្រួល ផ្តល់ជាឯកសារមួយចំនួន និងអនុសាសន៍ដ៏មានតម្លៃដល់ពួកយើងខ្ញុំក្នុងអំឡុងពេលចុះសិក្សាស្រាវជ្រាវ។
- សូមថ្លែងអំណរគុណដល់លោក **សឹម ហ៊ីម** ដែលជាប្រធានសហគន៍នេសាទត្រពាំងសង្កែ សមាជិកសហគមន៍នេសាទ ប្រជាពលរដ្ឋក្នុងសហគមន៍ និងប្រធានឃុំ ប្រធានភូមិ ដែលបានចំណាយពេលវេលាដល់ពួកយើងខ្ញុំក្នុងការធ្វើបទសម្ភាស និងបានផ្តល់ជាព័ត៌មានលម្អិត និងឯកសារពាក់ព័ន្ធទៅនឹងការអភិវឌ្ឍសហគមន៍នេសាទ។

ជាចុងក្រោយ យើងខ្ញុំសូមប្រសិទ្ធពរជ័យ សិរីមង្គលគ្រប់ប្រការ ជូនចំពោះអ្នកមានគុណទាំងអស់ឱ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ក្នុងនាមជានិស្សិតនៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានសិក្សាលើថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ពួកយើងបានសិក្សាស្វែងយល់ពីអំពីមេរៀនទ្រឹស្តី និងការស្រាវជ្រាវជាច្រើនដែលបានឆ្លុះបញ្ចាំងពីការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ជាពិសេសដោយមើលឃើញពីការអភិវឌ្ឍនៅតាមសហគមន៍ជាផ្នែកមួយក្នុងសង្គម ហើយក៏ជាបញ្ហាសំខាន់សំរាប់ការអភិវឌ្ឍប្រទេសផងដែរនោះ ទើបពួកយើងខ្ញុំបានធ្វើការចុះស្រាវជ្រាវ និងរៀបចំចងក្រងជារបាយការណ៍កម្មសិក្សាមួយស្តីពី "**ការអភិវឌ្ឍរបស់សហគមន៍នេសាទត្រពាំងសង្កែ**" ។

ចំពោះកម្រងឯកសារស្រាវជ្រាវដែលលោកអ្នកកំពុងកាន់នៅនឹងដៃនេះ ជាសមិទ្ធិផលមួយដែលឆ្លងកាត់ការស្រាវជ្រាវ ពីសំណាក់កម្រងឯកសារជាច្រើន រួមនឹងការតម្រែតម្រង់ទិសពីសំណាក់លោកសាស្ត្រាចារ្យ **ឈុន ពហុ** ដែលបានផ្តល់នូវគំនិតសំខាន់ៗដែលជាគន្លឹះនៃការស្រាវជ្រាវប្រធានបទនេះផងដែរ។ ចំពោះការសិក្សាស្រាវជ្រាវពីប្រធានបទខាងលើ បានផ្តល់នូវចំណេះដឹងបន្ថែមដល់យើងខ្ញុំ និងយល់កាន់តែច្បាស់អំពីដំណើរការនៃការអភិវឌ្ឍរបស់សហគមន៍ យល់ដឹងអំពីបញ្ហាប្រឈម និងដំណោះស្រាយល្អៗដែលមាននៅក្នុងការអភិវឌ្ឍសហគមន៍។ យើងខ្ញុំសង្ឃឹមថាកិច្ចការស្រាវជ្រាវមួយនេះ និងអាចចូលរួមចំណែកក្នុងការជួយសម្រួលដល់ស្ថាប័នដែលពាក់ព័ន្ធនឹងការអភិវឌ្ឍនៅតាមសហគមន៍ ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវទាំងឡាយផងដែរ។

ជាចុងក្រោយ យើងខ្ញុំសូមអភ័យទោសទុកជាមុនរាល់កំហុសខុសឆ្គងទាំងឡាយណាដែលបានកើតឡើងដោយអចេតនា ព្រោះការធ្វើរបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាមួយឡើងតែងតែមានកំហុសខ្លះៗកើតឡើងដោយចៀសមិនផុតឡើយ។ យើងខ្ញុំទាំងពីរសូមស្វាគមន៍ នូវរាល់ការរិះគន់ដើម្បីស្ថាបនាពីសំណាក់លោកអ្នក ដែលបានអានសៀវភៅនេះគ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីធ្វើឱ្យសៀវភៅមួយក្បាលនេះកាន់តែល្អប្រសើរឡើងជាងនេះមួយកម្រិតទៀត។

# មាតិកា


បញ្ជីអក្សរកាត់ ..... v
បញ្ជីតារាង ..... vi
បញ្ជីក្រាហ្វិក ..... vii
បញ្ជីរូបភាព ..... viii
បញ្ជីឧបសម្ព័ន្ធ ..... ix


## សេចក្តីផ្តើម


១. លំនាំបញ្ហា ..... ១
២. ចំណោទបញ្ហា ..... ១
៣. គោលបំណងនៃការស្រាវជ្រាវ ..... ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ..... ២
៥. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ..... ៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ ..... ៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៤


## ជំពូកទី១
## ទ្រឹស្តីពាក់ព័ន្ធនឹងការអភិវឌ្ឍសហគមន៍


១.១. ទ្រឹស្តីការអភិវឌ្ឍ ..... ៦
១.១.១. និយមន័យការអភិវឌ្ឍ ..... ៦
១.១.១.១. ទ្រឹស្តីលោក François Perroux ..... ៦
១.១.១.២. ទ្រឹស្តីលោក Harrod-Domar ..... ៧
១.១.១.៣. ទ្រឹស្តីលោក Micheal P. Todaro ..... ៨
១.១.២. និយមន័យសហគមន៍ ..... ៨
១.១.៣. និយមន័យការអភិវឌ្ឍសហគមន៍ ..... ៩
១.១.៤. សហគមន៍នេសាទ ..... ៩
១.១.៥. ការអភិវឌ្ឍសហគមន៍នេសាទ ..... ១០
១.២. គោលគំនិតនៃការអភិវឌ្ឍសហគមន៍ ..... ១០
១.២.១. ទស្សនៈវិស័យនៃការអភិវឌ្ឍសហគមន៍ ..... ១០

១.២.២. គោលការណ៍នៃការអភិវឌ្ឍសហគមន៍........................................១១
១.២.៣. គោលបំណងនៃការអភិវឌ្ឍសហគមន៍ ........................................ ១២
១.២.៤. មូលហេតុនៃការអភិវឌ្ឍសហគមន៍ ........................................១៣
១.៣. គោលនយោបាយរបស់រដ្ឋាភិបាលដើម្បីអភិវឌ្ឍន៍សហគមន៍ ........................ ១៣
១.៣.១. គោលនយោបាយអភិវឌ្ឍន៍សហគមន៍ ........................................១៤
១.៣.២. ទិសដៅអភិវឌ្ឍន៍........................................១៥
១.៣.៣. យុទ្ធសាស្ត្រការអភិវឌ្ឍ ........................................១៦
១.៣.៤. បេសកម្មរបស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ........................................១៦

## ជំពូកទី២

## ស្ថានភាពទូទៅជុំវិញការអភិវឌ្ឍរបស់សហគមន៍នេសាទត្រពាំងសង្កែ

២.១. ប្រវត្តិ និងទីតាំងភូមិសាស្ត្ររបស់សហគមន៍ ........................................១៨
២.២. ប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម........................................១៩
២.២.១. ប្រជាពលរដ្ឋ........................................១៩
២.២.២. មុខរបរ........................................ ២០
២.៣. ទស្សនៈវិស័យ និងគោលបំណងរបស់សហគមន៍នេសាទ ........................................ ២០
២.៣.១. ទស្សនៈវិស័យ........................................ ២០
២.៣.២. គោលបំណង........................................ ២០
២.៣.៣. សកម្មភាព ........................................ ២១
២.៣.៤. ឈ្មោះ និងស្លាកសញ្ញារបស់សហគមន៍........................................ ២១
២.៤. រចនាសម្ព័ន្ធ និងការបែងចែកតួនាទីភារកិច្ច ........................................ ២២
២.៤.១. រចនាសម្ព័ន្ធ ........................................ ២២
២.៤.២. ការបែងចែកតួនាទីភារកិច្ច........................................២៣
២.៥. ការកសាងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ........................................ ២៥
២.៦. ទីតាំងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងសហគមន៍នេសាទ..................២៧
២.៦.១. ទីតាំង ........................................២៧
២.៦.២. ការកំណត់ព្រំប្រទល់សហគន៍នេសាទ........................................ ២៨
២.៦.៣. ដែននេសាទ ........................................ ២៨

២.៦.៤. តំបន់ដែលសហគមន៍បង្កើតកន្លែងអភិរក្ស ...... ២៩
២.៦.៥. កន្លែងសហគមន៍បង្កើតតំបន់ទេសចរណ៍ ...... ២៩
២.៦.៦. ធនធានជលផល ...... ៣០
២.៧. ការធ្វើផែនការអភិវឌ្ឍន៍របស់សហគមន៍នេសាទ ...... ៣០
២.៧.១. ការធ្វើផែនការគ្រប់គ្រងសហគមន៍ ...... ៣០
២.៧.១.១. ការកំណត់បញ្ហា ...... ៣០
២.៧.១.២. ការកសាងផែនការ ...... ៣១
២.៧.១.៣. យុទ្ធសាស្ត្រអនុវត្តផែនការ ...... ៣២
២.៧.១.៤. ការចុះកិច្ចព្រមព្រៀងសហគមន៍នេសាទ ...... ៣៣
២.៧.១.៥. ការផ្គត់ផ្គង់ និងគ្រប់គ្រងហិរញ្ញវត្ថុ ...... ៣៤
២.៧.២. ផែនការគ្រប់គ្រងកន្លែងនេសាទរបស់សហគមន៍ត្រពាំងសង្កែ ...... ៣៤
២.៧.២.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ ...... ៣៥
២.៧.២.២. ផែនការកែលម្អដែននេសាទ ...... ៣៦
២.៧.២.៣. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ...... ៣៧
២.៧.២.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក ...... ៣៧
២.៧.២.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ...... ៣៨
២.៧.២.៦. ផែនការសាងសង់ស្នាក់ការល្បាតសហគមន៍នេសាទ ...... ៣៩
២.៧.២.៧. ផែនការថវិកាសម្រាប់ទ្រទ្រង់អភិវឌ្ឍន៍សហគមន៍នេសាទ ...... ៤០
២.៧.៣. ផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍសហគមន៍នេសាទ ...... ៤១
២.៨. ចំនួនអ្នកនេសាទ ឧបករណ៍ និងអនុផលនេសាទ ...... ៤២
២.៨.១. អ្នកនេសាទ ...... ៤២
២.៨.២. ឧបករណ៍នេសាទ ...... ៤២
២.៨.៣. ការប៉ាន់ប្រមាណផលនេសាទប្រចាំឆ្នាំ ...... ៤៦

## ជំពូក៣

## ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

៣.១. ការវិភាគលើស្ថានភាពរបស់សហគមន៍នេសាទត្រពាំងសង្កែ ...... ៤៧
៣.១.១. ស្ថានភាពរស់នៅមុនពេលបង្កើតសហគមន៍នេសាទត្រពាំងសង្កែ ...... ៤៧

៣.១.២. ស្ថានភាពរស់នៅក្រោយពេលបង្កើតសហគមន៍នេសាទត្រពាំងសង្កែ ............៤៨
៣.២. សមិទ្ធិផលរបស់សហគមន៍នេសាទត្រពាំងសង្កែ ...................................................... ៥២
៣.៣. បញ្ហាប្រឈមចំពោះការអភិវឌ្ឍសហគមន៍នេសាទ.....................................................៥៤
៣.៤. ដំណោះស្រាយចំពោះបញ្ហាប្រឈមនៃការអភិវឌ្ឍសហគមន៍នេសាទ ..........................៥៤
៣.៥. ការវិភាគ SWOT ...................................................................................................៥៥
៣.៥.១. ការវិភាគលើចំណុចខ្លាំង ...........................................................................៥៥
៣.៥.២. ការវិភាគលើចំណុចខ្សោយ .........................................................................៥៦
៣.៥.៣. ឱកាស .........................................................................................................៥៦
៣.៥.៤. ការគំរាមកំហែង .........................................................................................៥៦

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន......................................................................................................... ៥៧
២. ការផ្តល់អនុសាសន៍ ......................................................................................................៥៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- ម ៖ ខ្នាតប្រវែងគិតជាម៉ែត្រ
- ហ.ត ៖ ហិចតា
- គក ៖ ខ្នាតទំងន់គិតជាគីឡូក្រាម
- % ៖ ភាគរយ
- K ៖ Capital
- GDP ៖ Gross Domestic Product
- CWDCC ៖ Children and Woman Development Center in Cambodia
- FACT ៖ Fishery Action Coalition Team
- NGOs ៖ Non-government Organizations
- GPS ៖ Global Positioning System

# បញ្ជីតារាង

តារាង២.១ ៖ ផែនការប្រើប្រាស់ឧបករណ៍នេសាទ ............ ៣៥
តារាង២.២ ៖ ផែនការកែលម្អដែននេសាទ ............ ៣៦
តារាង២.៣ ៖ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ............ ៣៧
តារាង២.៤ ៖ ផែនការគ្រប់គ្រងព្រៃលិចទឹក ............ ៣៨
តារាង២.៥ ៖ ផែនការអភិវឌ្ឍន៍វារីវប្បកម្មនៅក្នុងសហគមន៍នេសាទត្រពាំងសង្កែ ............ ៣៩
តារាង២.៦ ៖ ផែនការសាងសង់ស្នាក់ការល្បាត ............ ៣៩
តារាង២.៧ ៖ ផែនការថវិកាសម្រាប់ទ្រទ្រង់អភិវឌ្ឍន៍សហគមន៍ ............ ៤០
តារាង២.៨ ៖ គ្រឿងឧបករណ៍នេសាទដែលអនុញ្ញាតឲ្យប្រើសម្រាប់សមាជិកសហគមន៍ ..... ៤៣
តារាង២.៩ ៖ គ្រឿងឧបករណ៍នេសាទដែលអនុញ្ញាតឲ្យប្រើសម្រាប់ប្រាស់អ្នកមិនមែនជាសមាជិកសហគមន៍នៅក្នុងតំបន់ ............ ៤៤
តារាង២.១០៖ គ្រឿងឧបករណ៍នេសាទដែលអនុញ្ញាតឲ្យប្រើសម្រាប់អ្នកដែលមិនមែនជាសមាជិកសហគមន៍ និងអ្នកនេសាទមកពីក្រៅសហគមន៍ ............ ៤៥
តារាង២.១១៖ ការប៉ាន់ប្រមាណទិន្នផលនេសាទប្រចាំឆ្នាំរបស់សហគមន៍ ............ ៤៦

# បញ្ជីក្រាហ្វិក

ក្រាហ្វិក៣.១៖ បង្ហាញពីស្ថានភាពរស់នៅក្រោយពេលបង្កើតសហគមន៍នេសាទត្រពាំងសង្កែ ........៥៨

## បញ្ជីរូបភាព

រូបភាពទី១ ៖ ឈ្មោះ និងស្លាកសញ្ញារបស់សហគមន៍នេសាទត្រពាំងសង្កែ ............................ ២១
រូបភាពទី២ ៖ រចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទត្រពាំងសង្កែ ................................ ២២
រូបភាពទី៣ ៖ ផែនទីរបស់សហគមន៍នេសាទត្រពាំងសង្កែ.................................................... ២៧
រូបភាពទី៤ ៖ ការសម្ភាសន៍ជាមួយប្រធានសហគមន៍នេសាទត្រពាំងសង្កែ ............................ ៣១

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ បញ្ជីសំណួរពាក់ព័ន្ធការស្រាវជ្រាវ
ឧបសម្ព័ន្ធទី២ ៖ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហាគមន៍នេសាទត្រពាំងសង្កែ
ឧបសម្ព័ន្ធទី៣ ៖ ផែនការគ្រប់គ្រងកន្លែងនេសាទសហាគមន៍នេសាទត្រពាំងសង្កែ
ឧបសម្ព័ន្ធទី៤ ៖ កិច្ចព្រមព្រៀងកន្លែងនេសាទសហាគមន៍
ឧបសម្ព័ន្ធទី៥ ៖ ផែនទីកន្លែងនេសាទសហាគមន៍នេសាទត្រពាំងសង្កែ
ឧបសម្ព័ន្ធទី៦ ៖ ទិដ្ឋភាពចុះកម្មសិក្សានៅក្នុងសហាគមន៍នេសាទត្រពាំងសង្កែ

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជា ជាប្រទេសមួយកំពុងអភិវឌ្ឍន៍ដែលពឹងផ្អែកលើវិស័យកសិកម្ម។ ប្រជាជនភាគច្រើនមានចំណូលពីការធ្វើកសិកម្មដូចជា ការដាំដំណាំ ការចិញ្ចឹមសត្វ ការនេសាទ និងការប្រកបរបរផ្សេងៗទៀតជាលក្ខណៈគ្រួសារជាដើម។ ក្នុងនោះមានវិស័យជលផលក៏បានដើរតួនាទីយ៉ាងសំខាន់ ដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋក៏ដូចជា ការរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឲ្យមានការរីកចម្រើនផងដែរ។

មកដល់ពេលបច្ចុប្បន្ននេះ ការគ្រប់គ្រងវិស័យជលផលនៅក្នុងប្រទេសកម្ពុជាយើងមានការប្រែប្រួលយ៉ាងខ្លាំង ហើយបទពិសោធន៍នៃការគ្រប់គ្រងថ្មីត្រូវបានចាប់ផ្តើមបង្កើតឡើង។ កំណែទម្រង់វិស័យជលផល គឺបានផ្តោតទៅលើការគាំទ្រដល់អ្នកនេសាទទ្រង់ទ្រាយតូចហើយនឹងលើកទឹកចិត្តដល់អ្នកនេសាទទាំងនោះឲ្យរួមសហការគ្នា ដើម្បីបង្កើតជាសហគមន៍នេសាទនៅតាមមូលដ្ឋានរបស់ខ្លួននីមួយៗ។ នៅក្នុងដំណាក់កាលនេះ លិខិតបទដ្ឋានគតិយុត្តិជាច្រើនត្រូវបានរៀបចំ និងបានកែសម្រួលឲ្យសមស្របទៅតាមស្ថានភាពបច្ចុប្បន្ន នៃការគ្រប់គ្រង និងការអភិវឌ្ឍវិស័យជលផល។ នៅក្នុងនោះច្បាប់ស្តីពីជលផល និងអនុក្រិត្យស្តីពីការគ្រប់គ្រងដើម្បីការអភិវឌ្ឍន៍សហគមន៍នេសាទត្រូវបានរៀបចំ និងត្រូវបានដាក់ឲ្យប្រើប្រាស់ដើម្បីគាំទ្រដល់ដំណើរការរៀបចំសហគមន៍នេសាទឲ្យបានសមស្រប។ ហើយយើងក៏ឃើញមាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទនៃរដ្ឋបាលជលផល ត្រូវបានបង្កើតឡើងនៅក្នុងគោលបំណងដើម្បីសម្របសម្រួលដល់ដំណើរការសហគមន៍នេសាទនៅកម្ពុជាផងដែរ។

ផ្អែកលើកត្តានេះហើយ ទើបជម្រុញឱ្យរាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ អង្គការក្នុង និងក្រៅប្រទេសបានយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍធនធានជលផល តាមបែបសហគមន៍នៅក្នុងគោលបំណងដើម្បីធ្វើការអភិវឌ្ឍ និងការប្រើប្រាស់នូវធនធានជលផលឱ្យកាន់តែមានប្រសិទ្ធភាពនិងនិរន្តរភាព។ លើសពីនេះទៅទៀត បន្ទាប់ពីរាជរដ្ឋាភិបាលបានប្រកាសធ្វើកំណែទម្រង់វិស័យជលផលនៅចុងឆ្នាំ ២០០០មកការរៀបចំសហគមន៍នេសាទបានប្រព្រឹត្តទៅយ៉ាងទូលំទូលាយនៅទូទាំងប្រទេសកម្ពុជាស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

## ២. ចំណោទបញ្ហា

យ៉ាងណាមិញ បើទោះបីជាមានការយកចិត្តទុកដាក់ទៅលើសហគមន៍នេសាទនានាពីស្ថាប័នពាក់ព័ន្ធ អង្គការក្នុងស្រុក និងក្រៅប្រទេសមួយចំនួនយ៉ាងណា ក៏គេឃើញថាការរស់នៅ

របស់ប្រជាជននៅក្នុងសហគមន៍នេសាទតាមមាត់ទន្លេ និងតំបន់ឆ្នេរសមុទ្រកម្ពុជានៅតែមានបញ្ហាមួយចំនួនដោយសារតែតម្រូវការរបស់មនុស្សចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលជាហេតុធ្វើឲ្យមានការប្រកួតប្រជែងនៅក្នុងការប្រើប្រាស់ឥតឈប់ឈរ និងការនេសាទមានការកើនឡើង ហើយឈានដល់ការប្រើប្រាស់ឧបករណ៍ខុសច្បាប់ជាដើម។ តាមរយៈបញ្ហាទាំងនេះតើសហគមន៍នេសាទត្រពាំងសង្កែមានការដោះស្រាយ និងអភិវឌ្ឍន៍សហគមន៍យ៉ាងដូចម្តេច? ហើយថាតើមានបញ្ហាប្រឈមអ្វីខ្លះកើតមាននៅក្នុងកំឡុងដំណើរការអភិវឌ្ឍសហគមន៍នេសាទនេះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងដូចជា ៖

- សិក្សាពីទ្រឹស្តីពាក់ព័ន្ធនិងការអភិវឌ្ឍសហគមន៍
- សិក្សា និងស្វែងយល់អំពីស្ថានភាពទូទៅ និងដំណើរការនៃការអភិវឌ្ឍសហគមន៍
- សិក្សា និងស្វែងយល់អំពីការធ្វើផែនការ និងយុទ្ធសាស្ត្រដែលសហគមន៍នេសាទរៀបចំឡើង នៅក្នុងការអភិវឌ្ឍសហគមន៍
- ស្វែងយល់អំពីបញ្ហាដែលបានជួបប្រទះរបស់សហគមន៍ និងដំណោះស្រាយក្នុងការអភិវឌ្ឍសហគមន៍នេសាទ
- ធ្វើការវិភាគ SWOT
- សិក្សា និងវាយតម្លៃលើការអភិវឌ្ឍរបស់សហគមន៍នេសាទ និងផ្តល់ជាអនុសាសន៍សម្រាប់ការអភិវឌ្ឍសហគមន៍នេសាទ ឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺស្ថិតនៅក្នុងសហគមន៍នេសាទត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត ហើយរបាយការណ៍ស្រាវជ្រាវនេះនឹងសិក្សាអំពីផែនការ យុទ្ធសាស្ត្រ និងការអភិវឌ្ឍរបស់សហគមន៍នេសាទទាំងមូល។ ចំពោះការស្រាវជ្រាវនេះត្រូវបានធ្វើឡើង ចាប់ពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩។ របាយការណ៍ស្រាវជ្រាវនេះមានការចងក្រងដោយធ្វើការប្រមូលជាឯកសារ និងមានការជួបសម្ភាសន៍ផ្ទាល់ជាមួយប្រជាពលរដ្ឋសមាជិកនៅក្នុងសហគមន៍នេសាទ ប្រធានសហគមន៍នេសាទត្រពាំងសង្កែ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតអំពីស្ថានភាពទូទៅទាក់ទងការអភិវឌ្ឍនៅក្នុងសហគមន៍ផងដែរ។ បន្ថែមពីនេះទៀត ការស្រាវជ្រាវនេះក៏អាចជួយដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗទៀត និងជាជំនួយដល់ការយល់ដឹងអំពីការអភិវឌ្ឍរបស់សហគមន៍នេសាទដល់ប្អូនៗជំនាន់ក្រោយផងដែរ។

## ៥. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវនេះ យើងបានប្រើប្រាស់នូវទិន្នន័យចំនួនពីរប្រភេទដើម្បីកំណត់នូវវិធីសាស្ត្រស្រាវជ្រាវគឺ ទិន្នន័យបឋម(Primary Data) និងទិន្នន័យបន្ទាប់បន្សំ(Secondary Data)៖

➢ **ទិន្នន័យបឋម(Primary Data)**

- យើងបានធ្វើការចុះជួបសម្ភាសន៍ និងប្រជុំដោយផ្ទាល់ជាមួយ **លោក សឹម ហ៊ឹម** ដែលជាប្រធានសហគមន៍ និងសមាជិកនៅក្នុងសហគមន៍នេសាទត្រពាំងសង្កែ។
- ធ្វើការចុះជួបជាមួយអ្នកនេសាទ និងប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ដើម្បីសាកសួរព័ត៌មានផ្សេងៗដែលទាក់ទងនឹងជីវភាពរបស់ពួកគាត់ពីការនេសាទ។
- យើងបានបង្កើតជាបញ្ជីសំនួរ ដើម្បីឲ្យការប្រមូលទិន្នន័យមានភាពងាយស្រួល និងចំណាយពេលវេលាអស់តិច។

❖ ព័ត៌មានសំខាន់ៗដែលយើងបានចងក្រងគឺផ្តោតទៅលើ៖

- ស្ថានភាពទូទៅរបស់សហគមន៍នេសាទត្រពាំងសង្កែ ទីតាំងភូមិសាស្ត្រ រចនាសម្ព័ន្ធគ្រប់គ្រងរបស់សហគមន៍នេសាទ ទស្សនៈវិស័យ បេសកកម្ម និងសកម្មភាពជាដើម។
- សមិទ្ធិផលរបស់ប្រជាជន នៅក្នុងសហគមន៍នេសាទត្រពាំងសង្កែដែលទទួលបានពីការអភិវឌ្ឍ មានដូចជា ឱកាសការងារ ចំណេះដឹងទូទៅ និងប្រាក់ចំណូលជាដើម។
- គោលនយោបាយ និងការអភិវឌ្ឍរបស់សហគមន៍ ដែលទាក់ទងនឹងការធ្វើគម្រោងអភិវឌ្ឍន៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ បញ្ហាប្រឈមនានារបស់សហគមន៍ និងដំណោះស្រាយជាដើម។
- និងទិសដៅក្នុងការអភិវឌ្ឍនៅឆ្នាំក្រោយៗទៀត។

➢ **ទិន្នន័យបន្ទាប់បន្សំ (Secondary Data)**

- ឯកសារបណ្ណាល័យ និងឯកសារដែលទាញយកពីប្រព័ន្ធអ៊ីនធឺណែត
- សៀវភៅកិច្ចការស្រាវជ្រាវ និងរបាយការណ៍របស់និស្សិតច្បងជំនាន់មុន
- ឯកសារដែលមានស្រាប់ពីរដ្ឋបាលជលផល
- ឯកសារផែនការ យុទ្ធសាស្ត្រ និងទិន្នន័យ ដែលបានមកពីការិយាល័យសហគមន៍នេសាទត្រពាំងសង្កែជាដើម។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

តាមរយៈការសិក្សាស្រាវជ្រាវនេះ បានផ្តល់នៅសារៈសំខាន់ដល់យើងខ្ញុំដូចជា ៖

- ផ្តល់នូវបទពិសោធន៍ និងចំណេះដឹងនៅក្នុងការស្វែងយល់អំពីការអភិវឌ្ឍរបស់សហគមន៍នេសាទ និងរបៀបប្រមូលឯកសារ ឬទិន្នន័យនានាដើម្បីចងក្រងធ្វើជាឯកសារ។
- ពង្រីកចំណេះដឹងបន្ថែមដែលបានសិក្សាកន្លងមក និងទ្រឹស្តីផ្សេងៗដែលទាក់ទងនិងការអភិវឌ្ឍ។
- យល់ដឹងអំពីអត្ថប្រយោជន៍នៃព្រៃឈើដែលជាជំរកសំខាន់របស់មច្ឆជាតិ។
- លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ និងត្រូវបានរក្សាទុកដើម្បីធ្វើជាឯកសារសម្រាប់សិក្សា និងស្វែងយល់ទាក់ទងការអភិវឌ្ឍសហគមន៍នេសាទសម្រាប់និស្សិតជំនាន់ក្រោយៗទៀត។
- ជាប្រយោជន៍ដល់សង្គមជាតិ តាមរយៈការជម្រុញដល់ការអភិវឌ្ឍសហគមន៍នៅតាមទីជនបទ។
- ជាពិសេសរបាយការណ៍នេះ ក៏អាចជួយផ្សព្វផ្សាយពីកេរ្តិ៍ឈ្មោះរបស់សហគមន៍នេសាទត្រពាំងសង្កែ ហើយក៏អាចជួយទាក់ទាញមូលនិធិសម្រាប់ធ្វើការអភិវឌ្ឍពីអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

តាមរយៈការស្រាវជ្រាវ យើងខ្ញុំបានធ្វើការបែងចែកប្រធានបទនេះជាបីជំពូកធំៗ រួមមាន៖

- ជំពូកទី១ ទ្រឹស្តីពាក់ព័ន្ធការនឹងអភិវឌ្ឍសហគមន៍ គឺធ្វើការសិក្សាទៅលើទស្សនៈផ្សេងៗស្តីពីការអភិវឌ្ឍទាក់ទងទៅនិងសហគមន៍នេសាទ ដោយយកទស្សនៈនៃការអភិវឌ្ឍរបស់សេដ្ឋវិទូមួយចំនួន ដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍមកបកស្រាយពន្យល់។ បន្ថែមពីនេះទៀត យើងនិងធ្វើការបកស្រាយអំពីគោលការណ៍មួយចំនួនរបស់សហគមន៍ និងបង្ហាញពីលទ្ធផលដែលទទួលបានពីការអភិវឌ្ឍសហគមន៍តាមរយៈទ្រឹស្តី។
- ជំពូកទី២ ស្ថានភាពទូទៅជុំវិញការអភិវឌ្ឍរបស់សហគមន៍នេសាទ គឺយើងបានធ្វើការសិក្សាទាក់ទងទៅនឹងស្ថានភាពទូទៅ និងការអភិវឌ្ឍរបស់សហគមន៍នេសាទត្រពាំងសង្កែ ដែលនិយាយអំពីទីតាំងភូមិសាស្រ្ត ស្ថានភាពប្រជាសាស្រ្ត មុខរបរ

តំបន់នេសាទ និងតំបន់ជំរកត្រីជាដើម។ លើសពីនេះទៅទៀត យើងនិងបង្ហាញពីការអភិវឌ្ឍទៅលើវិស័យការងារ ចំណេះដឹង ការថែរក្សា អភិរក្សធនធានធម្មជាតិដែលស្ថិតនៅក្នុងដែននេសាទរបស់សហគមន៍នេសាទ និងរៀបរាប់អំពីផែនការគ្រប់គ្រងសំរាប់ការអភិវឌ្ឍសហគមន៍នេសាទ។

- ជំពូកទី៣ ការវិភាគ និងបកស្រាយពីលទ្ធផលនៃការសិក្សាស្រាវជ្រាវដែលមាននៅក្នុងសហគមន៍នេសាទត្រពាំងសង្កែ។ ជំពូកនេះនឹងបង្ហាញពីការសិក្សាស្រាវជ្រាវដោយធ្វើការបកស្រាយ ពីបញ្ហាដែលប្រជាពលរដ្ឋនៅក្នុងសហគមន៍នេសាទកំពុងជួបប្រទះមុនពេលដែលមិនទាន់បង្កើតសហគមន៍នេសាទ និងក្រោយពីការបង្កើតសហគមន៍នេសាទ។ ជាពិសេស យើងនឹងធ្វើការរៀបរាប់អំពីសមិទ្ធិផលរបស់សហគមន៍នេសាទ បញ្ហាប្រឈមនានាដែលកើតមាននៅក្នុងសហគមន៍នេសាទ និងដំណោះស្រាយរបស់សហគមន៍នេសាទ។ ហើយចំណុចសំខាន់ចុងក្រោយនេះគឺធ្វើការវិភាគអំពីចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងកត្តាគំរាមកំហែងនៅក្នុងសហគមន៍នេសាទត្រពាំងសង្កែ។

# ជំពូកទី១

# ទ្រឹស្តីពាក់ព័ន្ធនឹងការអភិវឌ្ឍសហគមន៍

## ១.១. ទ្រឹស្តីការអភិវឌ្ឍ

### ១.១.១. និយមន័យការអភិវឌ្ឍ

**ការអភិវឌ្ឍ** គឺជាដំណើរការនៃការធ្វើឲ្យប្រសើរឡើងនូវគុណភាពជីវិតក្នុងការរស់នៅ និងសមត្ថភាពរបស់មនុស្សទាំងអស់ ដោយតាមរយៈការបង្កើននូវកម្រិតជីវភាពរស់នៅរបស់ប្រជាជន ការគោរព ការឲ្យតម្លៃ ការជឿទុកចិត្តលើខ្លួនឯង និងសេរីភាពរបស់មនុស្ស[1]។

**ការអភិវឌ្ឍ** ត្រូវបានគេចាត់ទុកថាមានន័យគ្រប់គ្រាន់នៅក្នុងឧស្សាហូបនីយកម្ម។ ជាការពិតណាស់គោលបំណងចុងក្រោយរបស់វា គឺរួមមានការបង្កើតនូវប្រាក់ចំណូល និងដំណើរការនៃការផ្តល់ឲ្យប្រជាជនក្រីក្រវិញនូវទំនិញ សេវាកម្មផ្សេងៗឲ្យបានគ្រប់គ្រាន់ និងលើសពីនេះទៀតគឺធ្វើឱ្យសង្គមមានការរីកចម្រើន។ បើនិយាយឲ្យខ្លី គឺសំដៅដល់ការធ្វើឲ្យជីវភាពរបស់ប្រជាជនក្រីក្រកាន់តែមានលក្ខណៈប្រសើរឡើង ហើយជាបន្ទាប់មកទៀតគឺឈានទៅដល់ការធ្វើឱ្យប្រទេសជាតិក្លាយជាប្រទេសឧស្សាហកម្មរីកចម្រើន ដែលអាចបង្កើននូវផលិតកម្ម និងផលិតផលសម្រេច[2]។

**ការអភិវឌ្ឍ** គឺសង្កត់ធ្ងន់លើបញ្ហានានាដែលទាក់ទិនដល់ការកែប្រែជាវិជ្ជមានលើគុណភាពជីវិតរបស់មនុស្សទូទៅប្រកបដោយចិរភាព និងជាដំណើរនៃការផ្តួចផ្តើមអ្វីៗដែលថ្មី និងបង្កើតនូវអ្វីៗដែលមិនទាន់មាន ហើយធ្វើការជួសជុលឲ្យបានប្រសើរឡើងនូវអ្វីៗដែលមានរួចមកហើយ។ ជាការពិតណាស់ ការអភិវឌ្ឍទទួលបាននូវការបន្ថែមជាអត្ថន័យ និងការរិះគន់ជាច្រើនដែលធ្វើឲ្យមានការលំបាកយ៉ាងខ្លាំងក្នុងការសំយោគអត្ថន័យរបស់វា។ ហេតុដូចនេះហើយទើបយើងឃើញមានអ្នកនិពន្ធជាច្រើនបានរកឃើញអំណះអំណាងផ្សេងៗគ្នាដូចជា ទ្រឹស្តីលោក François Perroux ទ្រឹស្តីលោក Hanrro-Domar និងលោក Micheal P. Todaro ជាដើម។

#### ១.១.១.១. ទ្រឹស្តីលោក François Perroux

លោក François Perroux គឺជាអ្នកទ្រឹស្តីនៃការអភិវឌ្ឍលើមនុស្ស គាត់បានឲ្យនិយមន័យការអភិវឌ្ឍថា គឺជាការចូលរួមនៃបំណាស់ប្តូរគំនិតចំពោះសង្គមរបស់ប្រជាជនមួយក្រុម ហើយក្នុងការរួមផ្សំនោះបានផ្តល់មកវិញនូវកំណើនផ្ទួនៗ និងស្ថិតថេរនៃផលិតផលសរុបរបស់ពួកគេ[3]។

---

[1] Michael P. Todaro and Stephen C. Smith,2009, page 5

[2] John Rapley, 2007, page 13

[3] https://Regional-Economic-Development-Francois-Perroux/dp/ (ចូលមើលថ្ងៃទី ០១ ឧសភា ២០១៩)

ដូចច្នេះ ការអភិវឌ្ឍគឺជាដំណើរការផ្លាស់ប្តូរសង្គមកិច្ច ឬការផ្លាស់ប្តូរនូវរចនាសម្ព័ន្ធសេដ្ឋកិច្ច ដើម្បីពង្រឹងហេដ្ឋារចនាសម្ព័ន្ធនយោបាយ សង្គម វប្បធម៌ ដែលធ្វើឲ្យមានភាពសុក្រិត យុត្តិធម៌នៅក្នុងស្ថាប័ន និងរដ្ឋាភិបាលនៅក្នុងការជំរុញឲ្យមានការអភិវឌ្ឍដើម្បីកាត់បន្ថយភាពក្រីក្រ ដែលធ្វើឲ្យមានភាពស្មើគ្នារវាងអ្នកមាន និងអ្នកក្រ ដើម្បីលុបបំបាត់នូវអនក្ខរកម្ម ដោយផ្តល់សេវាទាក់ទងចំណេះដឹងដល់ប្រជាជនទូទៅដើម្បីថែរក្សាបរិស្ថាន ឬធនធានធម្មជាតិឲ្យមានតុល្យភាព និងស្ថិតថេរគង់វង្សរហូត។

### ១.១.១.២. ទ្រឹស្តីលោក Harrod-Domar

នៅក្នុងគំរូរបស់លោក Harrod-Domar គ្រប់បណ្តាសេដ្ឋកិច្ចទាំងអស់ចាំបាច់ត្រូវតែមានការសន្សំដោយសមាមាត្រពិតប្រាកដនឹងចំណូលជាតិ ដើម្បីយកទៅចំណាយទៅលើទំនិញមូលធន (Capital good) ដែលចាស់ៗ និងខូចខាតដែលត្រូវធ្វើការជួសជុលដូចជា អាគារ ឧបករណ៍ និងគ្រឿងបរិក្ខារជាដើម។

ដើម្បីឲ្យមានកំណើនសេដ្ឋកិច្ច គឺចាំចាច់ត្រូវតែមានការវិនិយោគថ្មីបន្ថែមទៀតទៅលើផ្នែកស្តុកមូលធន (Capital Stock) ។ ដោយសន្មតថា មានទំនាក់ទំនងសេដ្ឋកិច្ចពីរ ដោយផ្ទាល់រវាងទំហំសរុបនៃស្តុកមូលធន(K) និងផលិតផលនៅក្នុងស្រុកសរុប (GDP) នោះមានន័យថា គេនឹងយកមួយភាគរយនៃផលិតផលក្នុងស្រុក ដែលបានតាមរយៈការសន្សំទៅធ្វើការវិនិយោគថ្មីពោលគឺយកទៅវិនិយោគលើស្តុកមូលធន ដើម្បីបង្កើននូវទិន្នផល។

គំរូរបស់លោក Harrod-Domar ត្រូវបានចែកចេញជាបីដំណាក់កាល នៅក្នុងការបង្ហាញពីទំនាក់ទំនងនៃសេដ្ឋកិច្ចរួមមាន៖

- ទំនាក់ទនងរវាងសន្សំ និងចំណូលសរុប
- ទំនាក់ទំនងរវាងការវិនិយោគ និងបំរែបំរួលស្តុកមូលធន
- សន្សំជាតិសរុបត្រូវតែស្មើនឹងវិនិយោគសរុប។

តាមទស្សនៈរបស់សេដ្ឋវិទូខាងលើ គន្លះនៃការអភិវឌ្ឍគឺ ស្ថិតនៅលើការចេះប្រមូលមូលធនក្នុងស្រុកសរុប ដោយធ្វើឲ្យកម្រិតនៃការសន្សំនៅក្នុងស្រុកមានកម្រិតខ្ពស់ និងការយកមូលធនដែលប្រមូលបានពីការសន្សំដើម្បីយកទៅធ្វើការវិនិយោគទាំងអស់ នោះជាលទ្ធផលគេនឹងទទួលបានអត្រាកំណើនកាន់តែខ្ពស់តាមនេះដែរ។ តាមទស្សនៈនេះ មានន័យថាកាលណាអត្រាកំណើនសេដ្ឋកិច្ចកាន់តែខ្ពស់ការអភិវឌ្ឍនឹងមានសភាពកាន់តែខ្លាំងផងដែរ[4]។

[4] Michael P. Todaro and Stephen C. Smith, 2009, page112

#### ១.១.១.៣. ទ្រឹស្តីលោក Micheal P. Todaro

ចំពោះការអភិវឌ្ឍនេះដដែល បើតាមលោក Micheal P. Todaro បានយល់ឃើញ ការអភិវឌ្ឍអាចកើតមានឡើង និងប្រកបដោយចិរភាព វាត្រូវបានចាប់ផ្ដើមឡើងពីតំបន់ជនបទ ជាពិសេសក្នុងវិស័យកសិកម្ម ហើយប្រទេសមួយអាចឈានដល់ការអភិវឌ្ឍបានយ៉ាងហោចណាស់ត្រូវមានចំណុចបីយ៉ាងដូចខាងក្រោម[5]៖

- ការពន្លឿនអូរភុតតាមរយៈការធ្វើកំណែទំរង់ស្ថាប័ន និងបច្ចេកវិទ្យាដែលត្រូវបានរៀបចំឡើងដើម្បីបង្កើនផលិតភាពសំរាប់កសិករតូចតាច។
- បង្កើននៅតំរូវការក្នុងស្រុកសំរាប់ផលិតផលកសិកម្ម ដែលមានប្រភពច្បាស់លាស់មកពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ការងារតំបន់ជាយក្រុង។
- សកម្មភាពអភិវឌ្ឍន៍ជនបទដើម្បីពង្រីកកម្លាំងពលកម្ម និងវិស័យផ្សេងៗទៀតដែលគាំទ្រដោយផ្ទាល់ ឬដោយប្រយោលពីស្ថាប័នពាក់ព័ន្ធ។

### ១.១.២. និយមន័យសហគមន៍

**សហគមន៍** គឺជាការរស់នៅប្រមូលផ្តុំគ្នារវាងមនុស្សម្នាក់ៗ និងគ្រួសារនីមួយៗនៅក្នុងភូមិសាស្ត្រជាមួយនឹងប្រជាជនដែលស្គាល់គ្នាយ៉ាងជិតស្និទ្ធ ចេះជួយទុក្ខធុរៈគ្នាទៅវិញទៅមក មានសាមគ្គីភាពល្អជាមួយគ្នា មានជីវភាពរស់នៅប្រហាក់ប្រហែលគ្នា។ ជាទូទៅការរៀបចំចងក្រងជាសហគមន៍ គឺជាវិធីមួយដែលផ្តល់ឲ្យសមាជិកនីមួយៗរបស់សហគមន៍នូវ ចំណេះដឹង ជំនាញ ឥរិយាបថ ក្នុងការបង្ហាញ និងកំណត់អាទិភាព សេចក្តីត្រូវការ បញ្ហារបស់ពួកគេដោយត្រូវបានប្រើប្រាស់ធនធានដែលពួកគេមាន ដើម្បីដោះស្រាយបញ្ហា និងរួមគ្នាធ្វើសកម្មភាពផ្សេងៗឱ្យរីកចម្រើនទាំងអស់គ្នា[6]។

**សហគមន៍** គឺជាក្រុមមនុស្សដែលរស់នៅតំបន់ជាមួយគ្នា មានបំណងរួមគ្នា ប្រយោជន៍រួមគ្នា មានវប្បធម៌ដូចគ្នា មានបញ្ហាប្រហាក់ប្រហែលគ្នា ហើយចែករំលែកនូវចំណេះដឹង បទពិសោធន៍ និងដោះស្រាយបញ្ហាជាមួយគ្នា[7]។

---

[5] Michael P. Todaro "Economic Development" Fifth Edition 1994 page 8

[6] ឃឹម ចាន់ល័ក្ខ និងឈុន សិរីចណ្ណ, "ការអភិវឌ្ឍរបស់សហគមន៍នេសាទកំពុងត្រឡាចលើ," (របាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៦), ទំព័រទី ១១-១២។

[7] នួន វណ្ណា, ឆៃលាង បញ្ញា និងឯម វណ្ណារ៉ា, "គំរោងអភិវឌ្ឍន៍សហគមន៍អ្នកក្រីក្រក្នុងរាជធានីភ្នំពេញ," (របាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០០៦), ទំព័រទី ១៣។

### ១.១.៣. និយមន័យការអភិវឌ្ឍសហគមន៍

ជារួមមក ការអភិវឌ្ឍសហគមន៍កន្លងមកត្រូវបានគេមើលឃើញច្រើនបំផុតថា គឺជាការអភិវឌ្ឍសំរាប់តែមនុស្ស។ វាពិតជាត្រឹមត្រូវ និងចាំបាច់ប៉ុន្តែវាគ្រាន់ជាទស្សនៈវិស័យដល់ខ្លីមួយដែលមិនគ្រប់គ្រាន់សំរាប់អត្ថន័យនៃការអភិវឌ្ឍសហគមន៍។ ហេតុដូចនេះទើបយើងឃើញមានការលើកឡើងផ្សេងៗគ្នាពីនិយមន័យនៃការអភិវឌ្ឍសហគមន៍ផងដែរ។

**ការអភិវឌ្ឍសហគមន៍** ជាដំណើរការបន្តបន្ទាប់ឥតឈប់ឈរមួយដែលធ្វើសន្សឹមៗក្នុងរយៈពេលយូរអង្វែងដើម្បីនាំមកនូវការរីកចម្រើន ផ្លាស់ប្តូរកែប្រែ ជឿនលឿនដែលអាចទទួលយកបានសំរាប់កែលំអរជីវភាពរស់នៅរបស់សង្គមឲ្យកាន់តែប្រសើរឡើងជាលំដាប់។

**ការអភិវឌ្ឍសហគមន៍** គឺជាការរួមបញ្ចូលនូវដំណោះស្រាយ នឹងសកម្មភាពទាំងឡាយដែលមានគោលបំណងធ្វើឲ្យប្រសើរឡើងនូវសុខមាលភាព និងជីវភាពរស់នៅរបស់ប្រជាជននៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាលដើម្បីធ្វើការអភិវឌ្ឍ។ ដំណោះស្រាយទាំងនេះត្រូវតែគិតគូរយ៉ាងយកចិត្តទុកដាក់ចំពោះបញ្ហាសង្គម ជាពិសេស គឺការរៀបចំសហគមន៍ឲ្យបានល្អប្រសើរ[8]។

### ១.១.៤. សហគមន៍នេសាទ

សហគមន៍នេសាទ គឺជារូបវន្តបុគ្គលមួយក្រុមមានសញ្ជាតិខ្មែរ រស់នៅទីជិត ឬខាងនៃដែននេសាទដែលត្រូវបានបង្កើតឡើងដោយស្ម័គ្រចិត្ត និងមានគំនិតផ្តួចផ្តើមបង្កើនជីវភាពរស់នៅរបស់ខ្លួនតាមរយៈការប្រើប្រាស់ និងកែច្នៃធនធានជលផលប្រកបដោយចិរភាព ដើម្បីរួមចំណែកលើកតម្កើងសេដ្ឋកិច្ច សង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ[9]។

យោងតាមច្បាប់ស្តីពីច្បាប់ជលផល មាត្រា ៥៩ បានឱ្យនិយមន័យសហគមន៍នេសាទថា សំដៅដល់ក្រុមប្រជាពលរដ្ឋខ្មែរដែលរស់នៅក្នុងភូមិមួយ ឬច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជាបានយល់ព្រមសហការគ្នាចូលរួមដោយស្ម័គ្រចិត្តនៅក្នុងគោលបំណងចូលរួមគ្រប់គ្រង អភិរក្សធនធានធម្មជាតិ និងអភិវឌ្ឍន៍ការប្រើប្រាស់ធនធាននៅតាមមូលដ្ឋានប្រកបដោយនិរន្តរភាព និងការពារសិទ្ធិ ព្រមទាំងផលប្រយោជន៍ប្រជាពលរដ្ឋខ្មែរស្របតាមលិខិតបទដ្ឋានគតិយុទ្ធនានាដែលពាក់ព័ន្ធនឹងវិស័យជលផល[10]។

[8] https://en.wikipedia.org/wiki/Rural-Community-Development (ចូលមើលថ្ងៃទី ០១ ឧសភា ២០១៩)

[9] អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ, ២០០៥

[10] ច្បាប់ស្តីពីជលផល, ២០០៧

#### ១.១.៥. ការអភិវឌ្ឍសហគមន៍នេសាទ

ការអភិវឌ្ឍសហគមន៍នេសាទ មានន័យថាជាការអភិវឌ្ឍដែលមិនធ្វើឱ្យប៉ះពាល់ដល់ធនធានជលផលទាំងឡាយ ដែលមាននៅក្នុងសហគមន៍ដោយធ្វើយ៉ាងណាឱ្យបុគ្គលទាំងអស់ដែលរស់នៅក្នុងសហគមន៍នោះធ្វើការថែរក្សា អភិវឌ្ឍន៍ អភិរក្សដើម្បីឱ្យធនធានទាំងនោះអាចមានលទ្ធភាពបង្កបង្កើត ឬបន្តពូជទៅមុខទៀតសំរាប់កូនចៅជំនាន់ក្រោយ[11]។

ជាពិសេសនោះ ការអភិវឌ្ឍសហគមន៍នេសាទអាចជួយអាចជួយឱ្យពួកគាត់មានម្ហូបអាហារ និងធនធានជលផលគ្រប់គ្រាន់សំរាប់ធ្វើការផ្គត់ផ្គង់ដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ និងអាចជួយផ្តល់ការងារធ្វើដល់ប្រជាជនក្នុងសហគមន៍ផងដែរ។ បន្ថែមពីនេះទៀត ការអភិវឌ្ឍនេះក៏អាចជួយផ្តល់ចំណេះដឹងពីការនេសាទដល់ប្រជាពលរដ្ឋ និងដំណោះស្រាយផ្សេងៗសម្រាប់ជួយសម្រួលដល់ការនេសាទរបស់ប្រជាជននៅក្នុងសហគមន៍ ហើយការផ្តល់ចំណេះដឹងពីការនេសាទនេះអាចជួយឱ្យពួកគាត់នេសាទដោយត្រឹមត្រូវ មានន័យថាពួកគាត់នេសាទដោយមិនធ្វើឱ្យបំពុលដល់បរិស្ថាន ប៉ះពាល់ដល់ធនធានធម្មជាតិ និងជីវៈចម្រុះជាដើម។

សរុបសេចក្តីមក ការអភិវឌ្ឍសហគមន៍នេសាទនេះអាចជួយឱ្យប្រជាពលរដ្ឋក្នុងសហគមន៍រកចំណូលបានគ្រប់គ្រាន់ ដែលអាចជួយដល់កូនៗរបស់ពួកគាត់ក្នុងការរៀនសូត្រផងដែរ[12]។

### ១.២. គោលគំនិតនៃការអភិវឌ្ឍសហគមន៍

#### ១.២.១.ទស្សនៈវិស័យនៃការអភិវឌ្ឍសហគមន៍

នៅក្នុងទស្សនៈវិស័យនៃការអភិវឌ្ឍសហគមន៍គឺ[13]៖

- ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងភាពក្រីក្រ ភាពមិនចេះអក្សរ ភាពមានជំងឺ និងភាពអសកម្មរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍។
- ដើម្បីចូលរួមចំណែកនៅក្នុងការអភិវឌ្ឍស្ថានភាពគ្រួសារ ដែលនាំទៅរកការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសជាតិ។
- ដើម្បីធ្វើឲ្យបានសម្រេចនូវការបែងចែកធនធាន និងផលនៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងនិរន្តរភាព។

[11] http://aquaticcommons.org/2496/1/CFDOStrategicPlan_opt.pdf(ចូលមើលថ្ងៃទី ០៣ ឧសភា ២០១៩)

[12] https://opendevelopmentcambodia.net/topics/community-fisheries/(ចូលមើលថ្ងៃទី ០៣ ឧសភា ២០១៩)

[13] ស្រ៊ន វត្ថុ និងហេង វុំបូ, "ការអភិវឌ្ឍសហគមន៍ចម្រុះរបស់អង្គការការីតាស កម្ពុជា នៅឃុំព្រៃកប្បស្សី ស្រុកល្វាឯម ខេត្តកណ្តាល", (របាយរបាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១២), ទំព័រទី ១៤។

- ដើម្បីសម្រេចឲ្យបាននូវយុត្តិធម៌ និងសមភាពរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងសហគមន៍ និងក្នុងពិភពលោកដោយមិនគិតពីជាតិសាសន៍ ជំនឿសាសនា វប្បធម៌ ស្ថានភាពសង្គម សេដ្ឋកិច្ច និងនិន្នាការនយោបាយជាដើម។

### ១.២.២. គោលការណ៍នៃការអភិវឌ្ឍសហគមន៍

តាមគោលការណ៍នៃការអភិវឌ្ឍសហគមន៍នេះចែកចេញជាបួនចំណុច ដែលក្នុងនោះរួមមានការចូលរួមក្នុងសហគមន៍ ភាពជាអ្នកដឹកនាំ ការផ្តល់អំណាច និងរៀនពីជីវិត។

- **ការចូលរួមក្នុងសហគមន៍** មនុស្សម្នាក់ៗបានធ្វើវិភាគទានដែលមានតម្លៃមួយ និងបានចូលរួមជាសមាជិករបស់សហគមន៍ ដែលអាចចូលរួមក្នុងកម្រិតណាមួយដែលខ្លួនមានបំណង ហើយសមាជិកមានសិទ្ធពេញលេញចំពោះការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងការវាយតម្លៃ ការសាកល្បង ការចូលរួម និងការកំណត់ទិសដៅនៅគ្រប់ជាន់ថ្នាក់ទាំងអស់។
- **ភាពជាអ្នកដឹកនាំសហគមន៍** សមាជិកទាំងអស់មានទំនាក់ទំនងគ្នាយ៉ាងសកម្មនៅក្នុងការធ្វើការសម្រេចចិត្ត និងមានភាពដឹកនាំនៃសកម្មភាពកណ្តាល។ ការបញ្ចូលនូវគណៈកម្មការគ្រប់គ្រងអ្នកស្ម័គ្រចិត្ត ត្រូវបានជ្រើសរើសដោយសមាជិកដែលរស់នៅ និងធ្វើការ ឬមានការចូលរួមពីសហគមន៍នៅក្នុងស្រុក ដើម្បីគ្រប់គ្រងគណៈកម្មការកណ្តាលនីមួយៗ។
- **ការផ្តល់អំណាច** ជាដំណើរការមួយដែលមានការគោរព មានគុណតម្លៃ និងពង្រឹងនូវសមត្ថភាពរបស់មនុស្ស ដើម្បីបំពេញនូវតម្រូវការរបស់ពួកគេ និងស្មារតីនៅក្នុងការយល់ដោយខ្លួនឯង និងបង្ហាញពីវិធីដែលធ្វើឲ្យមានគុណប្រយោជន៍នៃជំនាញ បទពិសោធន៍ និងសក្តានុពល។
- **រៀនពីជីវិត** ជាការបញ្ចូលគ្នានូវគ្រប់រូបភាពទាំងអស់នៃសកម្មភាពកណ្តាលដូចជាការបង្កើននូវចំណេះដឹង និងគាំទ្រនូវជំនាញ ចំណេះដឹង និងសមត្ថភាពព្រមទាំងភាពមិនចុះញមរបស់មនុស្ស។ ពួកគេបានពង្រឹងនូវសុខភាព សុខមាលភាព ទំនាក់ទំនងគ្នា និងព្រមទាំងគ្រួសាររបស់ពួកគេ តាមរយៈវិធីសាស្ត្រជាផ្លូវការ និងមិនផ្លូវការ នៅក្នុងការសិក្សាអប់រំ ការស្វែងយល់អំពីបទពិសោធន៍ កិច្ចការ និងការអភិវឌ្ឍខ្លួនឯង។

សរុបមក គោលការណ៍នៃការអភិវឌ្ឍសហគមន៍នេះគឺចង់ឱ្យប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ទាំងមូលទទួលបាននូវផលប្រយោជន៍យ៉ាងច្រើន ដោយអាចឲ្យពួកគេអភិវឌ្ឍន៍នូវខ្លួនរបស់ពួកគេ និងក្រុមគ្រួសារផង ដែលជាហេតុធ្វើឱ្យសហគមន៍ទាំងមូលទទួលបាននូវវឌ្ឍនៈភាព និងការអភិវឌ្ឍយ៉ាងឆាប់រហ័ស[14]។

### ១.២.៣. គោលបំណងនៃការអភិវឌ្ឍសហគមន៍

ការអភិវឌ្ឍ គឺជាកត្តាជំរុញឱ្យមានការរីកចំរើនតាមរយៈការទទួលបានប្រាក់ចំណូលទាបមកទទួលបានប្រាក់ចំណូលខ្ពស់។ ហេតុនេះហើយ ទើបនាំឲ្យកើតមានការបង្កើតសហគមន៍នៅតាមជនបទ និងទីដាច់ស្រយាលនៅក្នុងគោលបំណងដើម្បីកាត់បន្ថយភាពក្រីក្រ។ ដូច្នេះហើយទើបរដ្ឋាភិបាលបង្កើតនូវវិធីសាស្ត្រថ្មីៗ ដើម្បីមានការអភិវឌ្ឍប្រកបដោយចិរភាព។ សកម្មភាពទាំងអស់នេះបានឆ្លុះបញ្ចាំងពីគោលបំណងនៃការអភិវឌ្ឍសហគមន៍មានដូចជា៖

- បង្កើនជីវភាពរស់នៅរបស់ប្រជាសហគមន៍
- បង្កើនសុខភាព អនាម័យ និងសុខាភិបាល
- បង្កើនគមនាគមន៍ ដើម្បីឲ្យផលិតផលមានចរន្តចេញចូល
- បង្កើតការងារធ្វើឲ្យប្រជាជន ដើម្បីកុំឱ្យពួកគេចំណាកស្រុក
- ផ្តល់ឱកាសឱ្យប្រជាពលរដ្ឋ និងការប្រើប្រាស់សិទ្ធរបស់ខ្លួននៅក្នុងសហគមន៍
- ធ្វើការបង្កើននូវផលិតផល ដើម្បីឱ្យមានប្រាក់ចំណូលទៅដល់គ្រួសារកសិករដែលពួកគាត់គ្មានបទពិសោធន៍ក្នុងជីវិត
- ផ្តល់ឱកាសជូនប្រជាពលរដ្ឋឱ្យចេះធ្វើការជួយសង្គ្រោះ និងឱ្យយល់នូវសិទ្ធិរបស់ខ្លួនបានច្រើនថែមទៀត និងសីលធម៌វិន័យសង្គម និងមានទំនាក់ទំនងគ្នាបានល្អ
- បង្រៀនឲ្យប្រជាជនចេះយល់ដឹងដើម្បីជួយថែរក្សាធនធានធម្មជាតិ និងមច្ឆជាតិជាដើម។

សរុបមកគោលបំណងនៃការអភិវឌ្ឍន៍សហគមន៍ គឺចង់ឱ្យប្រជាពលរដ្ឋមានជីវភាពប្រសើរឡើងជាពិសេសបង្រៀនឱ្យប្រជាជនចេះថែរក្សា អភិរក្ស និងធ្វើការអភិវឌ្ឍធនធានទាំងឡាយដែលមាននៅក្នុងសហគមន៍ ដើម្បីលើកកម្ពស់សេដ្ឋកិច្ចរបស់ប្រទេសជាតិឱ្យមានការរីកចម្រើន[15]។

---

[14] ស៊ុត សុជាមុនីរត្ន និងស៊ាង សុខ, "ការអភិវឌ្ឍសហគមន៍របស់អង្គការស៊ីស៊ីឌីដើម្បីកាត់បន្ថយភាពក្រីក្រក្នុងខេត្តក្រចេះ" (របាយរបាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១១) ទំព័រទី ៨-៩។

[15] ឡៅ ធន់សោភ័ណ្ឌ និងអន សុខអេង, "ការអភិវឌ្ឍសហគមន៍នៅក្នុងភូមិព្រៃទទឹង," (របាយរបាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១១), ទំព័រទី ១២។

### ១.២.៤. មូលហេតុនៃការអភិវឌ្ឍសហគមន៍

ប្រជាជននៅតាមជនបទ និងទីដាច់ស្រយាលចំពោះចំណេះដឹងនៅមានកំរិតនៅឡើយ ហេតុដូចនេះហើយទើបរដ្ឋាភិបាល ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលបានជម្រុញ និងធ្វើការបង្កើតឡើងឲ្យមានសហគមន៍នៅតាមទីជនបទ ដើម្បីបង្កើនឲ្យមានការអភិវឌ្ឍព្រមទាំងជីវភាពរបស់ប្រជាជននៅក្នុងតំបន់ឱ្យមានការរីចម្រើនឡើង។

## ១.៣. គោលនយោបាយរបស់រដ្ឋាភិបាលដើម្បីអភិវឌ្ឍន៍សហគមន៍

ការបង្កើត និងបំពេញភារកិច្ចនៃនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ បន្ទាប់ពីធ្វើការបោះឆ្នោតជាសកលកាលពីឆ្នាំ ១៩៩៣ ក្រសួងអភិវឌ្ឍន៍ជនបទត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលនៅក្នុងអណត្តិទី១ យោងតាមព្រះរាជក្រមលេខ នស/រកម/១១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ និងយោងតាមអនុក្រិតលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០២ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។ នៅក្នុងទិសដៅបង្កើនកំរិតជីវភាពប្រជាជន និងកាត់បន្ថយភាពក្រីក្រនៅតាមជនបទផងដែរនោះ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍បានចាប់បដិសន្ធិឡើងនៅក្រោមអាណាព្យាបាលរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលជានាយកដ្ឋានជំនាញទទួលបន្ទុកការងារអភិវឌ្ឍន៍សហគមន៍ទូទាំងប្រទេស ដើម្បីធ្វើឱ្យមានការប្រែប្រួលដល់សង្គមជនបទទាំងមូល។ នាយកដ្ឋាននេះមានការិយាល័យចំនួនប្រាំគឺ ការិយាល័យទូទៅ ការិយាល័យសន្តិសុខស្បៀង ការិយាល័យអប់រំក្រៅប្រព័ន្ធ ការិយាល័យអភិវឌ្ឍន៍មូលដ្ឋាននិងការិយាល័យមជ្ឈមណ្ឌលអភិវឌ្ឍន៍ ដែលមានបំណងក្នុងការផ្លាស់ប្តូរផ្នត់គំនិត និងការរីកចម្រើនគ្រប់បែបយ៉ាងរបស់ប្រជាជនដោយរាប់បញ្ចូលទាំងបំណងប្រាថ្នាថ្មីៗជាច្រើន ចំពោះជំនាញ និងជំនឿទុកចិត្តថ្មីៗ ដែលពួកគេមានពីមុនមកដែលជាប្រភពធនធានដ៏មានសារៈសំខាន់បំផុត ដែលត្រូវយកមកប្រើប្រាស់ក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម នៅក្នុងពេលបច្ចុប្បន្ននេះ។

គោលនយោបាយនេះ នាយកដ្ឋានបានលើកពីផែនការអភិវឌ្ឍន៍សហគមន៍សំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែងដោយសិក្សាស្រាវជ្រាវលើគំរោងជួសជុល កសាងហេដ្ឋារចនាសម្ព័ន្ធជនបទដូចជាស្ពាន ផ្លូវ ថ្នល់ សាលារៀន មជ្ឈមណ្ឌលសុខភាពអភិវឌ្ឍន៍ភូមិ។ល។ ព្រមទាំងធ្វើការគ្រប់គ្រងមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ដោយធ្វើការរៀបចំបែបជនបទ ដែលពាក់ព័ន្ធទៅនិងដំណើរការថែរក្សាហេដ្ឋារចនាសម្ព័ន្ធជនបទរបស់ប្រជាជន ដើម្បីធ្វើការធានាឱ្យមានការអភិវឌ្ឍប្រកបដោយចិរភាព តាមផែនការដែលបានដាក់ចុះដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និង

ជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋឲ្យបង្កើតនូវផលិតផលដើម្បីផ្គត់ផ្គង់គ្រួសារ និងទីផ្សារ។ ចំពោះការអប់រំក្រៅប្រព័ន្ធ នាយកដ្ឋានមានតួនាទីបញ្ជូនភ្នាក់ងារអភិវឌ្ឍន៍សហគមន៍ ចុះទៅតាមមូលដ្ឋានដើម្បីធ្វើការអប់រំប្រជាពលរដ្ឋអំពីអក្ខរកម្ម ការការពារបរិស្ថាន និងធនធានធម្មជាតិ ព្រមទាំងលើកទឹកចិត្តឲ្យប្រជាជនដាំដើមឈើឡើងវិញ និងផ្តល់ការណែនាំស្តីអំពីការថែរក្សាប្រពៃណី វប្បធម៌ និងសុជីវធម៌នៅក្នុងការរស់នៅក៏ដូចជាការអប់រំពីសិទ្ធ លទ្ធិប្រជាធិបតេយ្យ បច្ចេកវិទ្យាសមស្របក្នុងដំណើរផលិតកម្ម និងការការពារគ្រាប់មីន។ល។ នាយកដ្ឋានត្រូវយកចិត្តទុកដាក់ក្នុងការបង្កើតពង្រឹងរចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទ ជាពិសេសគណកម្មាធិការអភិវឌ្ឍន៍ភូមិឃុំ និងជួយដោះស្រាយដល់ជនមាតុភូមិនិវត្តន៍ និងជនផ្លាស់ប្តូរទីលំនៅ[16]។

### ១.៣.១. គោលនយោបាយអភិវឌ្ឍន៍សហគមន៍

ការងារអភិវឌ្ឍន៍សហគមន៍ គឺជាយន្តការដ៏ល្អមួយដែលធ្វើសកម្មភាពដោយផ្ទាល់ជាមួយសហគមន៍មូលដ្ឋានដែលសំដៅដល់ការធ្វើឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា ឥរិយាបថ និងផ្នត់គំនិតរបស់ប្រជាសហគមន៍នៅតាមទីជនបទ ដើម្បីធ្វើការអភិវឌ្ឍមួយឆ្ពោះទៅរកភាពរីកចម្រើន និងប្រកបដោយនិរន្តភាព។ សកម្មភាពអភិវឌ្ឍន៍សហគមន៍បានចូលរួមយ៉ាងសំខាន់ នៅក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ ដែលសកម្មភាពនេះធ្វើឡើងស្របតាមគោលនយោបាយ វិមជ្ឈការ វិសហមជ្ឈការ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ជានាយកដ្ឋានមួយចំណុះឱ្យអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានតួនាទីជាសេនាធិការទទួលបន្ទុកការងារអភិវឌ្ឍន៍សហគមន៍ជនបទទូទាំងប្រទេស។ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយ កាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ នាយកដ្ឋានបានធ្វើសកម្មភាពអភិវឌ្ឍន៍សហគមន៍ចម្រុះដូចជាការបង្កើត និងពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ការអភិវឌ្ឍភូមិចម្រុះ ការបណ្តុះបណ្តាលអនក្ខរកម្ម ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ និងការពង្រឹងនូវសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ។ ហើយសកម្មភាពទាំងអស់នេះ ក៏បានចូលរួមយ៉ាងសំខាន់នៅក្នុងការជួយគាំទ្រដល់យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជាឱ្យទទួលបានជោគជ័យផងដែរ[17]។

---

[16]សែម ឡុងឌី និងយឹង មឿន, "ការអភិវឌ្ឍន៍សហគមន៍តាមរយៈកសិកម្មចំរុះ," (របាយរបាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០០៧), ទំព័រទី ១៦-១៧។

[17] http://fia.maff.gov.kh/newsdetail/skvYflaFbf (ចូលមើលថ្ងៃទី ០៣ ឧសភា ២០១៩)

### ១.៣.២. ទិសដៅអភិវឌ្ឍន៍

- លើកស្ទួយកំរិតជីវភាពរស់នៅរបស់ប្រជារាស្ត្រនៅតាមជនបទ ឲ្យមានស្វ័យភាពសេដ្ឋកិច្ចគ្រប់គ្រាន់ និងឈានឡើងប្រហាក់ប្រហែលបណ្តាប្រទេសនានានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងពេលអនាគត ដោយត្រូវតែខិតខំបំពេញនូវតម្រូវការដែលចាំបាច់ ដើម្បីជាមូលដ្ឋាននៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ ព្រមទាំងបង្កើតនូវប្រាក់ចំណូល និងមុខរបរក្រៅពីការងារកសិកម្ម។
- លើកទឹកចិត្ត និងចលនាប្រជារាស្ត្រជនបទឲ្យចូលរួមគ្រប់ដំណាក់កាលនៃគម្រោងការងារអភិវឌ្ឍន៍ ដើម្បីធានានូវប្រសិទ្ធិភាពការងារ និងភាពស្ថិតស្ថេរនៃគម្រោងទៅអនាគត។ ចលនាប្រជាជនឱ្យចូលរួមការពារ និងនិតិសម្បទា ធនធានធម្មជាតិ និងបរិស្ថាននៅតាមទីជនបទ ដើម្បីបង្កលក្ខណៈឱ្យការរស់នៅមានតុល្យាភាពជាមួយនិងធនធានធម្មជាតិដោយរៀបចំកម្មវិធីសេដ្ឋកិច្ចឱ្យបានសមស្របទៅតាមលទ្ធភាព និងជំនាញនៃសង្គមជនបទ។ ណែនាំប្រជាកសិករឱ្យចូលរួមក្នុងការកែលំអផលិតកម្មកសិកម្ម ការរកទីផ្សារដែលអាចជំរុញឱ្យសេដ្ឋកិច្ចជាតិកាន់តែល្អប្រសើរឡើង។
- ប្រគល់សិទ្ធិ និងភារកិច្ចជូនទៅប្រជាកសិករឲ្យមានទំនុកចិត្តលើខ្លួនឯង និងមានតួនាទីយ៉ាងសំខាន់នៅក្នុងការដោះស្រាយបញ្ហាសហគមន៍របស់គេដោយផ្ទាល់ ជាងការរង់ចាំដំណោះស្រាយពីរាជរដ្ឋាភិបាល ឬពីភ្នាក់ងារអភិវឌ្ឍន៍ជនបទផ្សេងទៀត។
- ខិតខំសហការជាមួយស្ថាប័នដែលពាក់ព័ន្ធ និងធ្វើការដោះស្រាយបញ្ហាដែលកកស្ទះនៃប្រជាពលរដ្ឋទីក្រុង ដែលបង្កឡើងដោយការជម្លៀសចេញមកពីជនបទ នៅក្នុងរយៈពេលសង្គ្រាមបីទសវត្សកន្លងមកនេះ[18]។

### ១.៣.៣. យុទ្ធសាស្ត្រការអភិវឌ្ឍ

ឈានចេញពីទិសដៅខាងលើរាជរដ្ឋាភិបាលបានកំណត់នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ដូចជា៖

- ជំរុញសកម្មភាពចុះធ្វើការស្រាវជ្រាវ និងស្រង់ទិន្នន័យនៅតាមថ្នាក់ភូមិឃុំឱ្យបានឆាប់រហ័ស ដើម្បីជាមូលដ្ឋានបង្អែកដ៏រឹងមាំក្នុងការកសាងផែនការអភិវឌ្ឍជនបទប្រកបដោយប្រសិទ្ធភាព។
- ដំណើរការការងារនៅក្នុងការអភិវឌ្ឍ ដោយយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លានៅក្នុងការដោះស្រាយបញ្ហាសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងសន្តិសុខនៅតំបន់ណាដែល

[18] ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ៥ឆ្នាំលើកទី២ (២០០១-២០០៥) ក្រសួងអភិវឌ្ឍន៍ជនបទឆ្នាំ២០០០។

បានកំណត់ជាក់លាក់ទៅតាមលំដាប់លំដោយ នៃអាទិភាពសមស្របទៅតាមស្ថានភាពជាក់ស្តែង និងតម្រូវការរបស់ប្រជាពលរដ្ឋដោយការធ្វើវិមជ្ឈការទំនួលខុសត្រូវជូនគណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង នៅក្នុងការកំណត់តំបន់គោលដៅនៅតាមមូលដ្ឋានរបស់គេ។

- លើកកម្ពស់កំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមគ្រប់តំបន់ ដូចជាតំបន់មិនសូវលូតលាស់ តំបន់លូតលាស់មធ្យម និងតំបន់រីកចម្រើន។ រាជរដ្ឋាភិបាលបានធ្វើការប្រមូលផ្តុំកម្លាំង និងធនធាននៅក្នុងការអភិវឌ្ឍតំបន់មិនសូវលូតលាស់ និងតំបន់លូតលាស់មធ្យម។ ទន្ទឹមនឹងនេះ ក៏មានគាំទ្រការវិនិយោគទុនដោយផ្តែកលើឯកជននៅតំបន់រីកចម្រើន
- គាំទ្រតួនាទីរបស់សហគមន៍ និងប្រជាពលរដ្ឋជនបទទូទៅ នៅក្នុងការដោះស្រាយបញ្ហាផ្ទាល់ដោយខ្លួនឯង និងឈានទៅដល់ការដោះស្រាយបញ្ហាសហគមន៍ដែលអាចលើកទឹកចិត្តឲ្យសហគមន៍ និងប្រជាពលរដ្ឋកាន់តែបង្កើនឡើងនូវសកម្មភាពស្វ័យឧបត្ថម្ភ និងទំនុកចិត្តលើខ្លួនឯង[19]។

### ១.៣.៤. បេសកកម្មរបស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍

ដើម្បីសម្របសម្រួលការបង្កើត និងដើម្បីគាំទ្រការអនុវត្តន៍សហគមន៍នេសាទនៅទូទាំងប្រទេសកម្ពុជាដែលជាដៃគូគ្រប់គ្រងធនធានរបស់រដ្ឋបាលជលផល នៅក្នុងកិច្ចប្រឹងប្រែងមួយសម្រាប់ការប្រើប្រាស់ធនធានវារិជាតិ ប្រកបដោយសមធម៌ និរន្តរភាព និងប្រសិទ្ធភាព នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍មានបេសកកម្មដូចជា ៖

- រៀបចំបង្កើត និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តិនានា (រួមមាន សេចក្តីណែនាំតួនាទីបទបញ្ជា និងបទបញ្ញត្តិជាដើម) និង គាំទ្រដល់ការអនុវត្តន៍ច្បាប់
- កំណត់ព្រំប្រទល់សហគមន៍នេសាទ
- ការចុះបញ្ជីទទួលស្គាល់សហគមន៍នេសាទជាផ្លូវការ
- កសាងសមត្ថភាពសំរាប់ការគ្រប់គ្រងសហគមន៍នេសាទ
- តាមដាន និងវាយតំលៃសកម្មភាពសហគមន៍នេសាទ
- ធ្វើការសិក្សាស្រាវជ្រាវអំពីសហគមន៍នេសាទ
- ដោះស្រាយ និងការគ្រប់គ្រងជំលោះនៅក្នុងដែនសហគមន៍នេសាទ

[19] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨, រាជរដ្ឋាភិបាលកម្ពុជា, ទំព័រទី២១០។

- ធ្វើអោយមានភាពប្រសើរឡើង ប្រកបដោយនិរន្តរភាពលើមុខរបរចិញ្ចឹមជិវិតចំរុះរបស់សហគមន៍នេសាទ
- ជំរុញការគាំទ្រ និងរៀបចំបង្កើតអោយមានតំបន់អភិរក្សនៅក្នុងដែនសហគមន៍នេសាទ
- ធានាអោយមានការចូលរួមច្រើនពីប្រជាពរដ្ឋក្នុងការគ្រប់គ្រងសហគមន៍នេសាទ
- ធានាឱ្យមានសមធម៌យេនឌ័រនូវរាល់សកម្មភាពនៅក្នុងសហគមន៍ និងទិដ្ឋភាពទាំងអស់របស់សហគមន៍នេសាទ
- ធ្វើការសម្របសម្រួលបណ្តាញការងារជាមួយដៃគូ និងអ្នកពាក់ព័ន្ធដ៏ទៃទៀតដើម្បីគាំទ្រដល់សហគមន៍ នេសាទ[20]។

[20]http://www.fia.gov.kh/khmer/index.php?page=cfdd&fbclid=IwAR3DON0MDeu7jnczivRVa_YaCMztGYmNs3uQCwHtfPbgyvBTEWDeHd3Slto (ចូលមើលថ្ងៃទី ០៥ ឧសភា ២០១៩) ។

# ជំពូកទី២

# ស្ថានភាពទូទៅជុំវិញការអភិវឌ្ឍរបស់សហគមន៍នេសាទត្រពាំងសង្កែ

## ២.១. ប្រវត្តិ និងទីតាំងភូមិសាស្ត្ររបស់សហគមន៍

ភូមិត្រពាំងសង្កែបានកកើតឡើងតាំងពីដើមមក ដែលពេលនោះប្រជាពលរដ្ឋភាគច្រើនប្រកបរបរជាអ្នកនេសាទទាញផលពីសមុទ្រ កសិករធ្វើស្រែចំការ និងធ្វើកសិកម្មផ្សេងៗជាច្រើនប្រភេទទៀត។ រហូតមកដល់ឆ្នាំ១៩៧៥ ប្រជាពលរដ្ឋបាននាំគ្នាចាកចេញពីភូមិស្រុកធ្វើដំណើរទៅកាន់ខេត្តផ្សេងៗ ដោយសារសង្គ្រាមនៃរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ(ប៉ុល ពត)។ ក្រោយពីថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនក្នុងភូមិនេះក៏វិលមករស់នៅដូចដើមវិញ និងមានអ្នកចំណូលថ្មីខ្លះៗផងដែរ។ នៅក្នុងពេលនោះមានប្រជាពលរដ្ឋប្រហែលជា ៣០០គ្រួសារដែលរស់នៅក្នុងភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត។ ក្រោយមកដោយសារកំណើនប្រជាជនមានការកើនឡើងជាលំដាប់នោះ ក្នុងឃុំត្រពាំងសង្កែមានប្រជាជនប្រហែលជា ៩០០គ្រួសារដែលមករស់នៅ និងប្រកបមុខរបរផ្សេងៗគ្នា។

ក្នុងអំឡុងពេលនោះ ប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិត្រពាំងសង្កែគឺបានជួបឧបសគ្គមួយចំនួនដូចជា សង្គ្រាមបញ្ហាសុខភាពដោយសារគ្មានមន្ទីរពេទ្យ និងសេវាសុខាភិបាលមិនគ្រប់គ្រាន់ ការបែកបាក់គ្រួសារ ខ្វះខាតការអប់រំ ខ្វះខាតទឹកស្អាតប្រើប្រាស់ និងអគ្គិសនីជាដើម និងមិនមានការអភិវឌ្ឍគ្រប់វិស័យ។ ប្រជាពលរដ្ឋនៅពេលនោះ ពួកគាត់បានប្រកបរបរនេសាទ ធ្វើស្រែចំការ និងធ្វើកសិកម្មចម្រុះ។ រហូតមកដល់កំឡុងឆ្នាំ ២០០៤ និង ២០០៥ នៅពេលនោះដែលមិនមានការបែងចែកតំបន់នេសាទ ព្រៃកោងកាង ឬតំបន់អភិរក្សនោះទេ គឺប្រជាពលរដ្ឋមានការប្រើប្រាស់រួមគ្នាជាសាធារណៈ ប៉ុន្តែក្រោយមកក៏មានការនេសាទខុសច្បាប់ ការឈ្លានពានដែននេសាទពីប្រទេសជិតខាង និងការកាប់បំផ្លាញព្រៃកោងកាងយ៉ាងអនាធិបតេយ្យ។ មិនត្រឹមតែប៉ុណ្ណោះទេ ភូមិត្រពាំងសង្កែក៏ចាប់ផ្តើមប្រឈមមុខជាមួយបញ្ហាមួយចំនួនទៀតដូចជា បញ្ហាដីធ្លី បញ្ហាគំរោងអភិវឌ្ឍន៍ និងក្រុមហ៊ុនឯកជនអ្នកមានអំណាចមកចាប់យកដី និងចាក់លុបព្រៃកោងកាង និងព្រែកជាដើម។ ដោយសារតែបញ្ហាទាំងអស់នោះ ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធទាំងអស់បានរួមគ្នាបង្កើតជាសហគមន៍មួយឈ្មោះថា សហគមន៍នេសាទត្រពាំងសង្កែដែលបង្កើតឡើងនៅថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៩ ដោយមានការចុះបញ្ជីត្រឹមត្រូវនៅក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្នុងឆ្នាំ ២០១១ ដែលមានការគាំទ្រពីមន្ទីរជំនាញដែលពាក់ព័ន្ធមួយចំនួនដូចជា មន្ទីរបរិស្ថាន មន្ទីទេសចរណ៍ ខណ្ឌរដ្ឋបាលជលផល អង្គការ CWDCC (មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រី

នៅកម្ពុជា) និងអង្គការសង្គមស៊ីវិលមួយចំនួនទៀតផង។ ការរៀបចំចងក្រងសហគមន៍នេសាទនេះ ឡើងក្នុងឆ្នាំ២០០៩ មានសមាជិកចូលរួមសរុបចំនួន ២០២៧នាក់ ស្រី១០២៩នាក់ ដែលជាអ្នកគាំទ្រសហគមន៍។

សហគមន៍នេសាទនេះ មានព្រំប្រទល់ខាងលិចជាប់ទៅនឹងឃុំជ្រុំក្រាល និងឃុំសំរោង ខាងកើតជាប់នឹងឃុំកូនសត្វ ខាងជើងជាប់នឹងឃុំត្រពាំងព្រីង និងខាងត្បូងជាប់នឹងឆ្នេរសមុទ្រ។ សហគមន៍នេះមានផ្ទៃដីនេសាទសរុបជាង ៣៣៧ហ.ត និងប្រជាជនជាង ៨០% ជាអ្នកនេសាទ។ បន្ថែមពីនេះទៀត សហគមន៍នេសាទត្រពាំងសង្កែនេះក៏ស្ថិតនៅក្រោមការត្រួតពិនិត្យ និងគាំទ្រពីរដ្ឋបាលជលផលថ្នាក់ខេត្តផងដែរ។ លើសពីនេះទៅទៀត សហគមន៍នេសាទត្រពាំងសង្កែក៏ទទួលបានការគាំទ្រពីអង្គការជាដៃគូដែលជួយគាំទ្រផ្នែកបច្ចេកទេស និងថវិការជាដើម។ តាមរយៈការជួយគាំទ្រទាំងនេះ បានធ្វើឱ្យសហគមន៍នេសាទមានការអភិវឌ្ឍយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ។ បច្ចុប្បន្ននេះសហគមន៍នេសាទត្រពាំងសង្កែ មានទីតាំងស្ថិតនៅក្នុងភូមិចំនួនបីគឺ ភូមិត្រពាំងសង្កែ ភូមិត្រពាំងធំ និងភូមិកំពង់កែស ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត។

## ២.២. ប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ២.២.១. ប្រជាពលរដ្ឋ

បច្ចុប្បន្ននេះសហគមន៍នេសាទត្រពាំងសង្កែមាន៖

- ចំនួនប្រជាពលរដ្ឋសរុបក្នុងតំបន់មាន ៥,៧៩២នាក់ ស្រី ៣,១០២នាក់ ក្នុងនោះមានចំនួន ១,០៦២គ្រួសារ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ៧៥% កាន់សាសនាឥស្លាមចំនួន២៤% និងសាសនាកាតាលិក១%។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរចំនួន៣៦នាក់ ស្រី២៣នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន៤១៨នាក់ ស្រី២០១នាក់ កម្រិតមធ្យមសិក្សាចំនួន២៦៤នាក់ ស្រី១៣២នាក់ និងកម្រិតឧត្តមសិក្សាចំនួន១៦នាក់ មានស្រីចំនួន៧នាក់។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមានចំនួន២៩នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមានចំនួន៣នាក់ ស្រី១នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមានចំនួន៧នាក់ ស្រី៤នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមានចំនួន២នាក់ ស្រី១នាក់
- ចំនួនអ្នកជម្ងឺរាំរ៉ៃក្នុងសហគមន៍នេសាទមានចំនួន៣នាក់ ស្រី២នាក់។

### ២.២.២. មុខរបរ

មុខរបរសំខាន់របស់ប្រជាពលរដ្ឋក្នុងសហាគមន៍នេសាទត្រពាំងសង្កែ រួមមាន៖

- ធ្វើនេសាទចំនួន២៥៦គ្រួសារ
- កែច្នៃផលនេសាទចំនួន២២គ្រួសារ
- ធ្វើស្រែចំនួន១៨៧គ្រួសារ ទំហំ៧៩ហិចតា
- ធ្វើចំការចំនួន១៨គ្រួសារ ទំហំ៩ហិចតា
- ធ្វើវារីវប្បកម្មចំនួន១៦គ្រួសារ ស្រះចំនួន១០ស្រះ ទំហំ១៥មx១០មx២ម បែចំនួន៦បែ ទំហំ២,៥មx៣មx១,៥ម។
- ជាងផ្ទះចំនួន២គ្រួសារ
- លក់ដូរចំនួន៥១គ្រួសារ
- កម្មករចំនួន៨គ្រួសារ
- មន្ត្រីរាជការ១២គ្រួសារ
- ចិញ្ចឹមសត្វ៣៨គ្រួសារ
- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ៧,២០០,០០០រៀល។

## ២.៣. ទស្សនៈវិស័យ និងគោលបំណងរបស់សហាគមន៍នេសាទ

### ២.៣.១. ទស្សនៈវិស័យ

សហាគមន៍នេសាទត្រពាំងសង្កែ មានទស្សនៈវិស័យចូលរួមគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយដោយសមធម៌ និងចីរភាព ដើម្បីធ្វើការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ២.៣.២. គោលបំណង

សហាគមន៍នេសាទត្រពាំងសង្កែ ត្រូវបានបង្កើតឡើងក្នុងគោលបំណង៖

- រួមគ្នាជាកម្លាំងដើម្បីចូលរួមការពារធនធានធម្មជាតិឱ្យមាននិរន្តភាព
- បង្កើនចំណេះដឹង និងបង្កើតមុខរបរបន្ថែមដល់ប្រជាពលរដ្ឋ
- ចង់ឱ្យអ្នកនេសាទយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទ
- ចង់ឱ្យមានការប្រើប្រាស់សិទ្ធិដោយស្របច្បាប់
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។

- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍចម្រុះ ដោយមានការចូលរួមពីសមាជិកក្នុងសហគមន៍។
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

### ២.៣.៣. សកម្មភាព

សកម្មភាពរបស់សហគមន៍នេសាទត្រពាំងសង្កែ រួមមាន៖

- ផ្សព្វផ្សាយពីច្បាប់ជលផល និងការប្រើប្រាស់ឧបករណ៍នេសាទ
- ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃសហគមន៍ តាមរយៈការប្រជុំប្រចាំខែជាមួយប្រជាជន
- ពង្រឹងការងារចុះល្បាតដោយមានការចូលរួមពីប្រជាជន
- ចងបណ្តាញសហគមន៍នៅក្នុងតំបន់ និងប្រជុំបណ្តាញ
- រៀបចំវេទិការពិគ្រោះយោបល់ជាមួយប្រជាជនក្នុងសហគមន៍
- ថែរក្សាការពារតំបន់អភិរក្សជាដើម។

### ២.៣.៤. ឈ្មោះ និងស្លាកសញ្ញារបស់សហគមន៍

រូបភាពទី១ ៖ ឈ្មោះ និងស្លាកសញ្ញារបស់សហគមន៍នេសាទត្រពាំងសង្កែ

ប្រភព៖ ហ្វេសបុកផេករបស់សហគមន៍នេសាទត្រពាំងសង្កែ

## ២.៤. រចនាសម្ព័ន្ធ និងការបែងចែកតួនាទីភារកិច្ច

### ២.៤.១. រចនាសម្ព័ន្ធ

រូបភាពទី ២ ៖ រចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទត្រពាំងសង្កែ




ប្រភព៖ សៀវភៅកម្រងព័ត៌មានបច្ចុប្បន្នភាព សហគមន៍នេសាទត្រពាំងសង្កែ

### ២.៤.២. ការបែងចែកតួនាទីភារកិច្ច

➢ **ប្រធានគណៈកម្មការសហគមន៍**

- ដឹកនាំ និងទទួលខុសត្រូវរួមក្នុងការអនុវត្តន៍ការងារនៅក្នុងសហគមន៍នេសាទ
- សម្របសម្រួលការងារជាមួយស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋាន ដើម្បីគាំទ្រដល់ការងារសហគមន៍នេសាទ
- ទំនាក់ទំនងជាមួយអង្គការនានា ដើម្បីស្វែងរកជំនួយទ្រទ្រង់សកម្មភាពសហគមន៍
- សម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗដែលមាននៅក្នុងសហគមន៍នេសាទ
- តាមដានត្រួតពិនិត្យរាល់សកម្មភាពការងាររបស់សហគមន៍នេសាទ
- ដឹកនាំរាល់ការប្រជុំ និងមហាសន្និបាតនៅក្នុងការបូកសរុបវាយតម្លៃ និងធ្វើការរៀបចំផែនការការងារនៅក្នុងសហគមន៍នេសាទ
- ផ្តល់ភាពយុត្តិធម៌ និងតម្លាភាពដល់សមាជិកសហគមន៍នេសាទ។

➢ **អនុប្រធានគណៈកម្មការសហគមន៍នេសាទ**

- ចូលរួមអនុវត្តការងារជាមួយប្រធានសហគមន៍
- ជំនួសមុខឲ្យប្រធាននៅពេលអវត្តមាន
- អនុប្រធានទី១ ទទួលបន្ទុកផ្នែកបេឡា និង លេខា
- អនុប្រធានទី២ ទទួលបន្ទុកផ្នែកផ្សព្វផ្សាយ អប់រំ និង ផ្នែកល្បាត
- ទទួលភារកិច្ចផ្សេងៗ ដែលប្រធានប្រគល់ជូន។

➢ **លេខា**

- កត់ត្រារាល់សកម្មភាព និងរក្សាទុកដាក់ឯកសារផ្សេងៗរបស់សហគមន៍
- ធ្វើកំណត់ហេតុរាល់ការប្រជុំ និងមហាសន្និបាត របស់សហគមន៍នេសាទ
- រៀបចំលិខិតអញ្ជើញ និងទីតាំងប្រជុំ
- ទទួលពាក្យស្នើសុំចូលជាសមាជិក និងលាលែងពីសមាជិក
- កត់ត្រា និងគ្រប់គ្រងសម្ភារៈរបស់សហគមន៍នេសាទ
- រៀបចំបែបបទ និងលិខិតស្នាមផ្សេងៗដែលទាក់ទងនឹងការគ្រប់គ្រងសហគមន៍
- ទទួលពាក្យបណ្តឹងតវ៉ាផ្សេងៗ
- ព្រាងរបាយការណ៍ពីលទ្ធផលការងាររបស់សហគមន៍នេសាទ ដើម្បីដាក់ជូនប្រធានពិនិត្យ និងសម្រេច។

➢ **បេឡា**

- ទទួលខុសត្រូវការងារហិរញ្ញវត្ថុរបស់សហគមន៍នេសាទឲ្យបានត្រឹមត្រូវតាមប្រព័ន្ធការងារគណនេយ្យ
- រៀបចំគំរោងផែនការប្រើប្រាស់ហិរញ្ញវត្ថុសហគមន៍នេសាទ ដើម្បីឲ្យគណៈកម្មការពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ និងរាយការណ៍ពីស្ថានភាពចំណូល-ចំណាយ ជូនគណៈកម្មការជារៀងរាល់ខែ
- ស្នើសុំការឯកភាពពីគណៈកម្មការសហគមន៍នេសាទ នូវរាល់ចំណាយផ្សេងៗ និងរក្សាទុកដាក់ ឯកសារឲ្យបានត្រឹមត្រូវ។

➢ **ជំនួយការបេឡា**

- ទទួលបន្ទុករាល់ការងារដែលប្រធានដាក់ឲ្យដើម្បីសម្រេចបានតាមទិសដៅ
- ជួយកិច្ចការបេឡានៅពេលចាំបាច់

➢ **ផ្នែកអប់រំ ផ្សព្វផ្សាយ**

- ធ្វើការអប់រំ ផ្សព្វផ្សាយពីខ្លឹមសារលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ច្បាប់ អនុក្រឹត្យ សេចក្តីជូនដំណឹង និងរាល់លិខិតបទដ្ឋាននានាដែលពាក់ព័ន្ធលើការគ្រប់គ្រងវិស័យជលផល បរិស្ថាន សិទ្ធិមនុស្ស អនាម័យ និងសុខភាព។ល។ ជូនដល់សមាជិកនៅក្នុងសហគមន៍របស់ខ្លួន និងសហគមន៍នេសាទជិតខាង។
- ស្វែងរកវិធីសាស្ត្រ និងបទពិសោធន៍ល្អៗ សម្រាប់ធ្វើការអប់រំ ផ្សព្វផ្សាយឲ្យរឹតតែមានប្រសិទ្ធភាព
- រៀបចំឯកសារបណ្តុះបណ្តាល ទស្សនៈកិច្ចសិក្សា ដើម្បីលើកកម្ពស់កម្រិតយល់ដឹង និងផ្លាស់ប្តូរបទពិសោធន៍នៅក្នុងការងារគ្រប់គ្រងធនធានធម្មជាតិ
- ធ្វើរបាយការណ៍ពីលទ្ធផលលើការងារអប់រំ និងវាយតម្លៃលើផែនការអនុវត្តការអប់រំជូនប្រធានគណៈកម្មការសហគមន៍នេសាទជារៀងរាល់ខែ។

➢ **ជំនួយការផ្សព្វផ្សាយ**

- ស្វែងយល់ពីមធ្យោបាយលើការផ្សព្វផ្សាយទៅតាមស្ថានភាពសង្គម
- ចូលរួមវគ្គបណ្តុះបណ្តាលនានា ដើម្បីទទួលបានវិធីសាស្ត្រថ្មីៗសម្រាប់ការផ្សព្វផ្សាយ និងអប់រំ។

➢ **ផ្នែកល្បាត**

- ទទួលខុសត្រូវលើកិច្ចការការពារធនធានជលផល និងទប់ស្កាត់បទល្មើស ដែលកើតមានក្នុងដែននេសាទសហគមន៍
- ទទួលបន្ទុកពិនិត្យ តាមដាន ឃ្លាំមើល និងល្បាតនូវរាល់សកម្មភាពនេសាទ នៅក្នុងករណីចាំបាច់ត្រូវរាយការណ៍ព័ត៌មានជូនប្រធានឲ្យបានឆាប់រហ័ស។
- សហការជាមួយសមត្ថកិច្ចជលផល បង្ក្រាបរាល់បទល្មើសជលផល នៅក្នុងកន្លែងនេសាទសហគមន៍ នៅក្នុងករណីបន្ទាន់ និងចាំបាច់ ផ្នែកល្បាតសហគន៍នេសាទអាចស្នើសុំអន្តរាគមន៍ពីសមត្ថកិច្ច អាជ្ញាធរដែនដី ដើម្បីឃាត់ទុកវត្ថុតាងនៃបទល្មើស និងឃាត់ខ្លួនជនល្មើស រួចត្រូវតែបញ្ជូនជាបន្ទាន់ទៅឱ្យសមត្ថកិច្ចជលផល ដើម្បីធ្វើការដោះស្រាយបទល្មើសទៅតាមច្បាប់
- រៀបចំផែនការល្បាតតាមដែនសហគមន៍ និងចាត់វិធានការការពារធនធានធម្មជាតិនៅក្នុងកន្លែងនេសាទសហគមន៍ ដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាព
- តាមដាន ស្រាវជ្រាវ និងត្រួតពិនិត្យអ្នកមិនមែនជាសមាជិកសហគន៍នេសាទដែលចូលរកនេសាទក្នុងកន្លែងនេសាទសហគមន៍
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលប្រចាំខែ និងសកម្មភាពការងាររបស់ខ្លួនជូនទៅប្រធានគណៈកម្មការសហគមន៍នេសាទ រៀងរាល់ខែ។

## ២.៥. ការកសាងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង

តាមរយៈការសម្ភាសជាមួយមន្ត្រីខណ្ឌរដ្ឋបាលជលផលខេត្តកំពត និងគណៈកម្មការរបស់សហគមន៍នេសាទបានមានប្រសាសន៍ថា ការបង្កើតលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ត្រពាំងសង្កែនេះ ត្រូវបានធ្វើឡើង ៣ដំណាក់កាលៈ

- ដំណាក់កាលទី១៖ យកគំរូលក្ខន្តិកៈដែលទទួលបានពីរដ្ឋបាលជលផលមកធ្វើការកែសម្រួលទៅតាមស្ថានភាពជាក់ស្តែងរបស់សហគមន៍នេសាទត្រពាំងសង្កែ ដោយលក្ខន្តិកៈនេះមានខ្លឹមសារដូចខាងក្រោម៖
  - និយាយពីគោលបំណង និងនាមករណ៍ ទីតាំងរបស់សហគមន៍
  - ចែងពីលក្ខខណ្ឌនៃការសុំចូលជាសមាជិក កាតព្វកិច្ច និងសិទ្ធរបស់សមាជិក
  - លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញពីសមាជិក
  - របៀបរបបកាន់បញ្ជី និងឯកសារនានាដែលទាក់ទងនឹងសហគមន៍នេសាទ

- តួនាទី សិទ្ធិ និងសមាសភាពរបស់គណៈកម្មការសហគមន៍នេសាទ
- របៀបរបបប្រជុំរបស់គណៈកម្មការ និងមហាសន្និបាតសហគមន៍នេសាទ
- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ និងតួនាទីរបស់គណៈកម្មការរៀបចំការបោះឆ្នោត
- លក្ខខណ្ឌនៃការរំសាយ និងនិតិវិធីដោះស្រាយវិវាទក្នុងសហគមន៍នេសាទ និងនីតិវិធីកែប្រែលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ។

- ដំណាក់កាលទី២៖ ដំបូងគេយកគំរូលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង ដាក់ឆ្លងរួមគ្នាជាមួយគណៈកម្មការសហគមន៍ដែលទើបតែជាប់ឆ្នោតថ្មីៗ និងក្រុមប្រឹក្សាឃុំទៅលើជំពូក និងប្រការនីមួយៗ។ បន្ទាប់មកយកគំរូលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងបញ្ជូនតាមរយៈគណៈកម្មការ និងក្រុមប្រឹក្សាឃុំទៅឆ្លងជាមួយសមាជិកសហគមន៍នេសាទ ដើម្បីកែតម្រូវតាមភាពជាក់ស្តែង និងកំណត់ពេលវេលាពិភាក្សាលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងជាមួយប្រជានេសាទ។
- ដំណាក់កាលទី៣៖ ជាដំណាក់កាលចុងក្រោយ គឺយកលក្ខន្តិកៈដែលឆ្លងរួចហើយជាមួយគណៈកម្មការក្រុមប្រឹក្សាឃុំ យកមកដាក់ឆ្លងជាមួយប្រជានេសាទ និងបញ្ជូនលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុងទៅខណ្ឌរដ្ឋបាលជលផល ដើម្បីចុះហត្ថលេខាយល់ព្រម និងអនុញ្ញាតឲ្យធ្វើការអនុវត្ត។ នៅក្នុងដំណាក់កាលនេះគណៈកម្មការសហគមន៍ក៏អញ្ជើញស្ថានប័នពាក់ព័ន្ធមួយចំនួន មកចូលរួមផងដែរមានដូចជាតំណាងអង្គការដៃគូ មន្ត្រីជំនាញជលផល អាជ្ញាធរមូលដ្ឋាន ចាស់ព្រឹទ្ធាចារ្យចូលរួមផងដែរ។

ជាទូទៅនៅក្នុងការធ្វើលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងត្រូវបានធ្វើឡើងដោយយកគំរូពីកម្រងលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធ និងយកសហគមន៍នេសាទនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការណែនាំរបស់ខណ្ឌរដ្ឋបាលជលផលខេត្តកំពត។ ដូចនេះយើងអាចសង្កេតឃើញថាការបង្កើតឡើងនូវបទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈសហគមន៍នេសាទត្រពាំងសង្កែត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវនឹងសមស្រប ដោយមានការចូលរួមប្រជុំ ដោយដាក់ឆ្លងសមាជិកសហគមន៍នេសាទ គណៈកម្មការសហគមន៍នេសាទ រដ្ឋបាលជលផលខេត្ត ក្រុមប្រឹក្សាឃុំសង្កាត់ តំណាងអង្គការ NGOs ចាស់ព្រឹទ្ធាចារ្យ និងកម្រងលិខិតបទដ្ឋានគតិយុត្តិ ដែលពាក់ព័ន្ធនឹងសហគមន៍នេសាទនៃព្រះរាជាណាចក្រកម្ពុជា របស់រដ្ឋបាលជលផលផងដែរ។ ក្នុងនោះក៏បានរៀបរាប់ពីការប្តេជ្ញាចិត្ត

ការទទួលខុសត្រូវរបស់ជួរគណៈកម្មការ និងសមាជិកក្នុងសហគមន៍នេសាទតាមរយៈការចងក្រងជាបទបញ្ញត្តិ សិទ្ធិក្នុងការប្រើប្រាស់នូវឧបករណ៍នេសាទ និងទោសបញ្ញត្តិក្នុងដំណើរការគ្រប់គ្រងដែននេសាទសហគមន៍សម្រាប់ពួកគាត់។ (ឧបសម្ព័ន្ធទី២)

## ២.៦. ទីតាំងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងសហគមន៍នេសាទ

### ២.៦.១. ទីតាំង

សហគមន៍នេសាទត្រពាំងសង្កែស្ថិតនៅភូមិត្រពាំងធំ ភូមិត្រពាំងសង្កែ និងភូមិកំពង់កែស ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត។ សហគមន៍នេសាទត្រពាំងសង្កែបានទទួលធ្វើការចុះបញ្ជីកន្លែងនេសាទដោយបានជោគជ័យនៅក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ នៅថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១១ ដែលមានទំហំកន្លែងនេសាទ៣៣៧ហិចតា។

មកដល់ឆ្នាំ២០១៧ សហគមន៍នេសាទត្រពាំងសង្កែបានធ្វើបច្ចុប្បន្នភាពឯកសារ និងផែនទីរបស់ខ្លួន ដែលបានបែងចែកជា៣តំបន់សំខាន់ៗក្នុងផែនការគ្រប់គ្រង រួមមាន៖

- កន្លែងនេសាទសហគមន៍ទំហំ៤១៥ហិចតា ដែលមានបែងចែកជាតំបន់អភិរក្សស្មៅសមុទ្រមានទំហំ៤០ហិចតា (មិនអនុញ្ញាតឱ្យមានការនេសាទទេ តែសហគមន៍អាចនេសាទក្រៅតំបន់នេះក្នុងតំបន់គ្រប់គ្រងរបស់ខ្លួនបាន) និងតំបន់អភិរក្សព្រៃកោងកាងដែលមានទំហំសរុប៥៧ហិចតា (ព្រៃកោងកាងចាស់ទំហំ ៣១ហិចតា និងព្រៃកោងកាងថ្មីទំហំ២៦ហិចតា)
- មណ្ឌលការពារព្រៃកោងកាងទំហំ០.៧ហិចតា ។
- មជ្ឈមណ្ឌលទេសចរណ៍ទំហំ ០.៨១ហិចតា (ទីស្នាក់ការសហគមន៍) បង្កើតនៅក្នុងឆ្នាំ ២០១៤។

រូបភាពទី៣ ៖ ផែនទីរបស់សហគមន៍នេសាទត្រពាំងសង្កែ




ប្រភព៖ សៀវភៅកម្រងព័ត៌មានបច្ចុប្បន្នភាព សហគមន៍នេសាទត្រពាំងសង្កែ

### ២.៦.២. ការកំណត់ព្រំប្រទល់សហគមន៍នេសាទ

ទីតាំងសហគមន៍នេសាទ គឺត្រូវកំណត់ព្រំប្រទល់ជាក់ស្តែង និងនៅលើផែនទីដែលត្រូវផ្ញើជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីចុះហត្ថលេខាយល់ព្រមលើផែនទីព្រំប្រទល់របស់សហគមន៍នេសាទ។ បើយោងទៅតាមខណ្ឌរដ្ឋបាលជលផលខេត្តកំពត និងប្រធានគណៈកម្មការសហគមន៍នេសាទបានមានប្រសាសន៍ថា ការកំណត់ព្រំប្រទល់សហគមន៍មានដូចជា៖

- ដំណាក់កាលទី១៖ ប្រជុំអ្នកដែលពាក់ព័ន្ធដើម្បីវាយតម្លៃទីតាំងដោយមានអាជ្ញាធរព្រំប្រទល់ទាំងសងខាង មេឃុំជលផល សមាជិកសហគមន៍ និងគណៈកម្មការ។
- ដំណាក់កាលទី២៖ កំណត់ភូមិសាស្ត្រ ដោយប្រើប្រាស់ឧបករណ៍ GPS ចុចដោយស្ថាប័នជំនាញ ដោយដាំបង្គោលឈើ។
- ដំណាក់កាលទី៣៖ ចុះទៅបោះបង្គោលស៊ីម៉ង់ដោយមានការចូលរួមពីមន្ត្រីជំនាញអង្គការដៃគូ មន្ត្រីរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ អាជ្ញាធរមូលដ្ឋាន សមាជិក និងគណៈកម្មការសហគមន៍នេសាទ។ រាល់ការបញ្ចូលទិន្នន័យកូអរដោនេ អាប់ស៊ីស និងបង្កើតផែនទីត្រូវបានសម្របសម្រួលដោយមន្ត្រីរដ្ឋបាលជលផល។

ជាចុងក្រោយគណៈកម្មការសហគមន៍នេសាទត្រូវរៀបចំផែនទីជាផ្លូវការ ដោយត្រូវដាក់បញ្ចូលនៅក្នុងកិច្ចព្រមព្រៀងសហគមន៍នេសាទ ហើយផ្ញើមករដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចុះហត្ថលេខាយល់ព្រម។

សហគមន៍នេសាទត្រពាំងសង្កែមានព្រំប្រទល់៖

- ខាងជើងទល់នឹងផ្លូវជាតិក្នុងឃុំត្រពាំងសង្កែ និងជាប់ឃុំត្រពាំងព្រីង
- ខាងត្បូងទល់នឹងសមុទ្រ
- ខាងកើតទល់នឹងសហគមន៍កំពង់សាមគ្គី ឃុំអូរក្រសារ ស្រុកទឹកឈូ
- ខាងលិចទល់នឹងឃុំកំពង់សំរោងនិងឃុំជុំគ្រៀល។

### ២.៦.៣. ដែននេសាទ

កន្លែងនេសាទសហគមន៍ត្រពាំងសង្កែជាកន្លែងនេសាទទឹកសាប ទឹកប្រៃ និងដែននេសាទតំបន់ឆ្នេរសមុទ្រ ព្រៃកោងកាង និងមានព្រែកចំនួន២ ប្រឡាយចំនួន២ ត្រពាំងចំនួន៧។

- ព្រែកឈ្មោះ ក្បាលរមាស ទំហំ៤០ម x ៨០០០ម x ៦ម (អាចនេសាទបានពេញមួយឆ្នាំ)
- ព្រែកឈ្មោះ ស្ពានព្រៃលីទំហំ២០ម x ៥០០០ម x ៣ម (អាចនេសាទបានពេញមួយឆ្នាំ)
- ប្រឡាយឈ្មោះ ត្រពាំងធំ ទំហំ៤ម x ៥០០ម x ១.៥ម (នេសាទពីខែមិថុនា ដល់ ខែមករា)

- ប្រឡាយឈ្មោះ ភ្នំតូច ទំហំ២៥ម x ៣០០០ម x ២ម (នេសាទពីខែមិថុនា ដល់ ខែធ្នូ)
- ត្រពាំងឈ្មោះ ត្រពាំងក្រពើ ទំហំ៥០ម x ៥០ម (នេសាទពីខែមិថុនា ដល់ ខែធ្នូ)
- ត្រពាំងឈ្មោះ កើត(អង្រុត) ទំហំ៤០ម x ៤០ម x ៣ម (នេសាទពីខែមិថុនា ដល់ ខែធ្នូ)
- ត្រពាំងឈ្មោះ ត្រពាំងធំ ទំហំ៤០ម x ៤០ម x ១ម (នេសាទពីខែមិថុនា ដល់ ខែធ្នូ)
- ត្រពាំងឈ្មោះ ត្រពាំងសារាយ ទំហំ៣០ម x ៤០មx១.៥ម(នេសាទពីខែមិថុនា ដល់ខែ មីនា)
- ត្រពាំងឈ្មោះ ត្របាំងម៉ែស: ទំហំ៣០ម x ៤០ម x ២ម (នេសាទពីខែមិថុនា ដល់ ខែមីនា)
- ត្រពាំងឈ្មោះ ត្រពាំងកាប៊ូ ទំហំ៤០ម x ៤០ម x ៣.៥ម (នេសាទពីខែមិថុនា ដល់ ខែមេសា)
- ត្រពាំងឈ្មោះ ត្រពាំងគល់ ទំហំ៥០ម x ៦០ម x ៤ម (នេសាទពីខែមិថុនា ដល់ ខែមេសា)
- ព្រៃកោងកាង ទំហំសរុប ៥៧ហិចតា (ព្រៃថ្មី២៦ហិចតារួមទាំងកន្លែងបម្រុងដាំបន្ថែ និង មានព្រៃកោងកាងចាស់ ៣១ហិចតា)។
- ព្រៃឈ្មោះ កោះលលក ទំហំ ៤ហិចតា។

### ២.៦.៤. តំបន់ដែលសហគមន៍បង្កើតកន្លែងអភិរក្ស

សក្តានុពលដែលសហគមន៍នេសាទមើលឃើញ អាចបង្កើតតំបន់អភិរក្សបានគឺស្ថិតនៅក្នុងកន្លែងនេសាទសហគមន៍ ដែលបានបែងចែកជា ២តំបន់គឺ តំបន់អភិរក្សស្មៅសមុទ្រមានទំហំ ៤០ហិចតា និងតំបន់អភិរក្សព្រៃកោងកាងទំហំ ៥៧ហិចតា។

១. សហគមន៍នេសាទត្រពាំងសង្កែ បានកំណត់តំបន់អភិរក្សស្មៅសមុទ្រស្ថិតនៅក្នុងកន្លែងនេសាទសហគមន៍ ដែលមិនអនុញ្ញាតឱ្យមានការនេសាទទេ តែសហគមន៍អាចនេសាទក្រៅតំបន់នេះក្នុងតំបន់គ្រប់គ្រងរបស់ខ្លួនបាន។ តំបន់អភិរក្សស្មៅសមុទ្រនេះ សំរាប់រក្សាជម្រកត្រីពងកូន រក្សាស្មៅសមុទ្រ និងធនធានជីវៈចម្រុះជាច្រើនទៀត ដែលមានទំហំ ៤០ហិចតា។

២. តំបន់អភិរក្សព្រៃកោងកាងមានទំហំសរុប ៥៧ហិចតា ដែលមានព្រៃកោងកាងចាស់ចំនួន ៣១ហិចតា និងព្រៃកោងកាងថ្មីចំនួន ២៦ហិចតា។ ព្រៃកោងកាងចាស់ គឺជាព្រៃកោងកាងដែលសហគមន៍នេសាទទុកជាកន្លែងទេសចរណ៍ ដែលមានស្ពានដើរទស្សនាទិដ្ឋភាពធម្មជាតិ និងព្រៃកោងកាង សត្វស្លាប មានកូនផ្ទះសំរាប់លំហែរជាដើម។ ព្រៃកោងកាងថ្មីសំរាប់ឱ្យភ្ញៀវទេសចរដាំដើមកោងកាង ព្រមទាំងជាកន្លែងដែលរក្សាជីវៈចម្រុះ និងលើកកម្ពស់បរិស្ថានជាដើម។

### ២.៦.៥ កន្លែងសហគមន៍បង្កើតតំបន់ទេសចរណ៍

សហគមន៍នេសាទត្រពាំងសង្កែ បានខិតខំប្រឹងប្រែងអភិវឌ្ឍន៍សហគមន៍រហូតបង្កើតបានជាតំបន់ទេសចរណ៍បែបអេកូទេសចរណ៍ធម្មជាតិ ដែលមានមជ្ឈមណ្ឌលទេសចរណ៍(ទីស្នាក់ការ)

ទំហំចំនួន ០.៨១ហិចតា នៅក្នុងភូមិកំពង់កែស ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត ដែលមានព្រំប្រទល់ឆ្នេរព្រែក ៥០០ម៉ែត្រ។ សហគមន៍នេសាទបានប្រើប្រាស់តំបន់អភិរក្សព្រៃកោងកាងដែលមានទំហំ ៥៧ហិចតា ហើយមានសេវាកម្មជូនភ្ញៀវទេសចរដូចខាងក្រោម៖

- សេវាកម្មទូកជូល សំរាប់ជិះកំសាន្តមើលព្រៃកោងកាងដែលសហគមន៍នេសាទធ្វើការអភិរក្ស និងចូលរួមដាំដើមកោងកាងសំរាប់ធ្វើជាជំរកត្រី។
- សេវាកម្មផ្ទះស្នាក់នៅ
- សេវាកម្មម្ហូបអាហារ
- និងមានស្ពានសម្រាប់ដើរកំសាន្តទស្សនាធនធានធម្មជាតិ សមុទ្រ ព្រៃកោងកាង និងសត្វស្លាបជាដើម។

### ២.៦.៦. ធនធានជលផល

ធនធានជលផលដែលសហគមន៍នេសាទរកបានមានដូចជា៖

- ប្រភេទត្រី ៖ ត្រីឆ្តង់ ត្រីក្បក ត្រីក្អុក ត្រីប្រកុង ត្រីទីឡាព្យា ត្រីអាំងកឹយ ត្រីចង្គោមបី ត្រីជំឡូង ត្រីក្តចិន ត្រីប្លាធូ ត្រីម្រេច ត្រីស្លុងក្រហម ត្រីផ្ទោង ត្រីត្រសក់ ត្រីឆ្លាម ត្រីកិ ត្រីកាវ៉ាវ ត្រីប្រម៉ា ត្រីកាម៉ុង ត្រីក្បាលឡាន ត្រីអណ្តែងប៉ុយ ត្រីកន្ទាំង ត្រីបបែល ត្រីកន្ទុយរឹង ត្រីកាប៉ាស ត្រីឆ្លាត ។ល។
- ប្រភេទវារីសត្វ ៖ បង្កង បង្គា ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ មឹក ក្រែងឈាម ងាវ ងាវភក់ ងាវហ្វូល ងាវស បង្កងកណ្តូប បង្កងប៉ាក អណ្តើក កន្ទាយ បល្ល័ងកាស កញ្ចា អន្ទង់ ផ្សោតស ផ្សោតខ្មៅ ផ្សោតបារ៉ាមិច ពស់ ។ល។
- ប្រភេទនៃរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ៖ កោងកាង ក្រញឹប អម្ពូ អម្ពា ក្របាញញី ក្របាញឈ្មោល ប៊ឹង ប្រាសាក់ បើស ឈើជ័រ ដើមក្លាយ ដើមឡេវអាវ ដើមដូងទឹក ធ្នង់ ។ល។

## ២.៧. ការធ្វើផែនការអភិវឌ្ឍន៍របស់សហគមន៍នេសាទ

### ២.៧.១. ការធ្វើផែនការគ្រប់គ្រងសហគមន៍

#### ២.៧.១.១. ការកំណត់បញ្ហា

យោងទៅតាម ការសម្ភាសន៍ជាមួយប្រធានគណៈកម្មការសហគមន៍នេសាទត្រពាំងសង្កែ គាត់បាននិយាយថា ការរៀបចំផែនការនេះត្រូវបានធ្វើឡើងតាមរយៈការប្រជុំជាមួយនឹងសមាជិកគណៈកម្មការសហគមន៍ សមាជិកសហគមន៍ រដ្ឋបាលជលផលខេត្ត ប៉ូលីស មេភូមិ មេឃុំ មន្ត្រី

សម្របសម្រួល បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ប្រជាជនភូមិ និងចាស់ព្រឹទ្ធាចារ្យ ដើម្បីលើកឡើងនូវបញ្ហាដែលកំពុងតែកើតមាន រិះរកមធ្យោបាយដោះស្រាយដោយសន្តិវិធី និងសមោហាភាព។ ពិសេសនោះ គឺការរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំបន្ទាប់ទៀត ដូចនេះគេត្រូវបានកំណត់យកអាទិភាពនៃបញ្ហាមកធ្វើការប្រជុំពិភាក្សា ធ្វើការរកដំណោះស្រាយ ក៏ដូចជាកំណត់ផែនការយុទ្ធសាស្ត្រ សម្រាប់ការដឹកនាំគ្រប់គ្រងសហគមន៍នេសាទ។

រូបភាពទី៤៖ ការសម្ភាសន៍ជាមួយប្រធានសហគមន៍នេសាទត្រពាំងសង្កែ



### ២.៧.១.២. ការកសាងផែនការ

ការកសាងផែនការត្រូវបានធ្វើឡើងដូចខាងក្រោមនេះ៖

- បំពាក់បំប៉នសមាជិកសហគមន៍ និងអ្នកភូមិពីការរៀបចំទាក់ទងផែនការអភិវឌ្ឍន៍សហគមន៍នេសាទ។
- រៀបចំការងារស្រាវជ្រាវបន្ថែម ដើម្បីឲ្យដឹងកាន់តែស៊ីជម្រៅពីបញ្ហានានានៅក្នុងសហគមន៍នេសាទ។
- សម្របសម្រួលពិភាក្សាជាមួយក្រុមតូចៗ និងពិគ្រោះយោបល់ជាមួយអ្នកភូមិដើម្បីវិភាគអំពីបញ្ហា។
- ធ្វើសេចក្តីព្រាងផែនការគ្រប់គ្រងសហគមន៍នេសាទ។

- ពិភាក្សាជាមួយអ្នកភូមិ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធនានាស្តីពីការធ្វើផែនការគ្រប់គ្រងសហាគមន៍នេសាទ និងធ្វើការសម្របសម្រួលប្រសិនបើមានការចាំបាច់។
- ផែនការគ្រប់គ្រងត្រូវបានសម្រេចដោយមហាសន្និបាតរបស់សហាគមន៍។
- ដាក់ឆ្លងផែនការគ្រប់គ្រងទៅមេឃុំ ចៅសង្កាត់ ខណ្ឌរដ្ឋបាលជលផលថ្នាក់ខេត្ត ដើម្បីស្នើសុំការយល់ព្រម។
- ចំពោះកន្លែងអភិរក្សរបស់សហាគមន៍ ដែលបានកំណត់នៅក្នុងផែនការគ្រប់គ្រងត្រូវបានទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

បើតាមសំដីរបស់លោក **ហ៊ីម នី** អនុប្រធានសហាគមន៍នេសាទបានប្រាប់ឲ្យដឹងថាក្នុងដំណាក់កាលនីមួយៗនៃការកសាងផែនការគ្រប់គ្រងសហាគមន៍នេសាទ ត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវដោយមានការជួយសម្របសម្រួលដោយមន្ត្រីរដ្ឋបាលជលផលថ្នាក់ខេត្ត និងដោយមានគម្រូតាមសៀវភៅកម្រងលិខិតបទដ្ឋានគតិយុត្តិ ដែលពាក់ព័ន្ធទៅនឹងសហាគមន៍នេសាទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៨ ផងដែរ។

### ២.៧.១.៣. យុទ្ធសាស្ត្រអនុវត្តផែនការ

នៅពេលដែលផែនការគ្រប់គ្រងសហាគមន៍ត្រូវបានរៀបចំ និងអនុម័តយល់ព្រមហើយនោះ សហាគមន៍នេសាទគម្បីត្រូវអនុវត្តផែនការគ្រប់គ្រងទាំងនោះ ព្រោះជាកត្តាជំរុញប្រកបដោយភាពជោគជ័យលើដំណើរការគ្រប់គ្រងសហាគមន៍នេសាទ។ លើសពីនេះ ដើម្បីអនុវត្តន៍ផែនការឲ្យទទួលបានជោគជ័យ គណៈកម្មការសហាគមន៍នេសាទត្រពាំងសង្កែបានធ្វើការរៀបចំចងក្រងជាយុទ្ធសាស្ត្រមួយចំនួនសម្រាប់សកម្មភាពអនុវត្តន៍ដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តន៍ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ ក្នុងនោះមានសមាជិកគណៈកម្មការសហាគមន៍នេសាទ ចាស់ទុំ និងសមាជិកសហាគមន៍នេសាទដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗ ជាពិសេសអំពីបញ្ហានេសាទ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលដូចជា ការធ្វើផែនការដើម្បីអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចំរុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការស្វែងរកថវិកាគាំទ្រសហាគមន៍ជាដើម។
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ។

- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឲ្យបានជាក់លាក់ ដោយទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីស្នើសុំការគាំទ្រ និងជួយរកដៃគូសម្រាប់គាំទ្រការទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រង។
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ។
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍នេសាទ។
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ។
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីធ្វើការចូលរួមចំណែកនៅក្នុងការអនុវត្តផែនការ។
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់។

  ប្រភព៖ (ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទត្រពាំងសង្កែ)

### ២.៧.១.៤. ការចុះកិច្ចព្រមព្រៀងសហគមន៍នេសាទ

ការចុះកិច្ចព្រមព្រៀង គឺជាការចុះហត្ថលេខារវាងសហគមន៍នេសាទ និងរដ្ឋបាលជលផល ដើម្បីទទួលបានសិទ្ធិស្របច្បាប់ទៅលើការគ្រប់គ្រងកន្លែងនេសាទសហគមន៍។ បើតាមសម្ដីរបស់ប្រធានសហគមន៍នេសាទបានមានប្រសាសន៍ថា ដំបូងគណៈកម្មការសហគមន៍នេសាទត្រូវរៀបចំសេចក្ដីព្រៀងរបស់សហគមន៍ ដោយមានការពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍នេសាទ ពិភាក្សាក្រុមតូចៗជាមួយអ្នកភូមិ និងទទួលយកការរិះគន់របស់អ្នកភូមិ និងអ្នកពាក់ព័ន្ធ។ បន្ទាប់មកត្រូវរាយការណ៍ជូនរដ្ឋបាលជលផលមកត្រួតពិនិត្យស្ថានការណ៍ និងឧបករណ៍នេសាទដែលប្រើដោយសហគមន៍។ នៅក្នុងការចុះកិច្ចព្រមព្រៀងនេះ រួមមានឯកសារដូចជា លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ការកំណត់ព្រំប្រទល់ រចនាសម្ព័ន្ធ ការបែងចែកតួនាទី និងផែនការគ្រប់គ្រងកន្លែងនេសាទជាដើម។ ក្នុងនោះអ្នកចូលរួមមាន គណៈកម្មការសហគមន៍នេសាទ ការិយាល័យអភិវឌ្ឍន៍សហគមន៍ ផ្នែកអភិវឌ្ឍន៍សហគមន៍ អ្នកភូមិ អ្នកពាក់ព័ន្ធ និងរដ្ឋបាលជលផល ដែលត្រូវធ្វើការចុះហត្ថលេខាក្នុងពិធីមហាសន្និបាតសហគមន៍។

ទាំងនេះបានបង្ហាញឲ្យឃើញថាក្នុងដំណាក់កាលនីមួយៗ គឺត្រូវបានចូលរួមពិភាក្សាដោយមតិភាគច្រើន និងសម្របសម្រួលដោយមន្ត្រីជំនាញជលផល អង្គការដៃគូរអភិវឌ្ឍន៍រហូតទទួលបានសិទ្ធិគ្រប់គ្រាន់ក្នុងការគ្រប់គ្រងកន្លែងនេសាទរបស់ខ្លួនដោយស្របច្បាប់។

### ២.៧.១.៥. ការផ្គត់ផ្គង់ និងគ្រប់គ្រងហិរញ្ញវត្ថុ

➢ **ការផ្គត់ផ្គង់ហិរញ្ញវត្ថុ**

យោងតាមសម្ដីដែលយើងបានធ្វើការសម្ភាសន៍ជាមួយលោក **សឹម ហ៊ឹម** ដែលជាប្រធាននៃគណៈកម្មការសហគមន៍នេសាទបានមានប្រសាសន៍ថា ប្រភពថវិកាដែលបានមកពីការវិភាគទានរបស់សមាជិកសហគមន៍ ការផាកពិន័យបទល្មើស និងអំណោយថវិកាដែលបានមកពីសប្បុរជនជំនួយរបស់រដ្ឋាភិបាល អង្គការ NGOs និងចំណូលរបស់សហគមន៍តាមរយៈអេកូទេសចរណ៍។ រាល់កញ្ចប់ចំណូលថវិការបស់សហគមន៍ត្រូវបានរក្សាទុកនៅបេឡារបស់សហគមន៍។ ថវិកាដែលតម្កល់ទុកនៅបេឡាធិការត្រូវបានចំណាយទៅលើការជួសជួលឧបករណ៍ សម្ភារៈ ទីស្នាក់ការ និងយកមកបំពេញនូវតម្រូវការចាំបាច់ផ្សេងៗដូចជា ការងារប្រជុំ យាមល្បាត ទស្សនៈកិច្ចសិក្សា ក៏ដូចជាសម្រាប់ប្រជាជនដែលចូលរួមល្បាត និងបង្ក្រាបបទលើសផ្សេងៗទៀត។ ជាក់ស្ដែងការចេញយាមល្បាតព្រៃកោងកាង ការបង្ក្រាបបទលើសត្រូវការប្រើប្រាស់ទូកដែលតម្រូវឲ្យយកថវិកាមួយចំណែកសម្រាប់ទិញប្រេងបំរុង និងសម្រាប់ចាក់ទូកដែលចេញទៅល្បាត។

➢ **ការគ្រប់គ្រងហិរញ្ញវត្ថុ**

រាល់កញ្ចប់ថវិកាដែលបានមកពីប្រភពផ្សេងៗនោះ ត្រូវបានផ្ដល់ឲ្យបេឡាជាអ្នករក្សាទុកក្នុងគណនេយ្យរបស់សហគមន៍ និងមានចុះបញ្ជីគណនេយ្យយ៉ាងត្រឹមត្រូវ។ រាល់ថវិកាចំណាយត្រូវមានរបាយការណ៍ទូទាត់ដោយមានសក្ខីបត្រ(វិក័យបត្រ) បិតបញ្ជីឲ្យបានត្រឹមត្រូវ ដើម្បីឲ្យការគ្រប់គ្រងថវិកាទាំងនោះមានសុវត្ថិភាព និងប្រកបដោយតម្លាភាព។ ដើម្បីឲ្យគណៈកម្មការផ្សេងៗទៀតដឹងពីការចំណាយនោះ ពោលគឺរាល់ដំណើរការងារទាក់ទងទៅនឹងចំណូលចំណាយផ្សេងៗត្រូវបានរាយការណ៍ក្នុងការប្រជុំប្រចាំខែរបស់សហគមន៍នេសាទ។ លើសពីនេះលោក **អ៊ុន កម៉ារី** ដែលជាប្រធានអង្គការមហាជនរស្មីសាមគ្គី និងក៏ជាអ្នកស្ម័គ្រចិត្តធ្វើការងារក្នុងសហគមន៍នេសាទត្រពាំងសង្កែបានប្រាប់ឲ្យដឹងថារាល់ថវិកាដែលចំណាយផ្សេងៗ គឺសម្រាប់តែបម្រើឲ្យតែការងារគ្រប់គ្រង ផ្សព្វផ្សាយ អភិរក្ស និងការងារអភិវឌ្ឍន៍ក្នុងសហគមន៍នេសាទនេះតែប៉ុណ្ណោះ។

### ២.៧.២. ផែនការគ្រប់គ្រងកន្លែងនេសាទរបស់សហគមន៍ត្រពាំងសង្កែ

ផែនការ គឺជាគំនិតគិតទុកមុនរបស់មនុស្សប្រកបដោយរបៀបវារៈត្រឹមត្រូវ មានការកំណត់ពេលវេលាច្បាស់លាស់ដើម្បីសម្រេចគោលបំណងអ្វីមួយ។ ការរៀបចំផែនការ គឺជាដំណើរការនៃការបង្កើតសកម្មភាពការងារ និងវិធីសាស្ត្រដើម្បីសម្រេចគោលដៅនៃគម្រោង ឬកម្មវិធីនៅក្នុងរយៈពេលកំណត់ច្បាស់លាស់ណាមួយដោយមានការចូលរួមពីអ្នកពាក់ព័ន្ធជាច្រើន។ ដើម្បីគ្រប់គ្រង

កន្លែងនេសាទសហគមន៍ឲ្យមានប្រសិទ្ធិភាព និងធ្វើការអភិវឌ្ឍសហគមន៍នេសាទប្រកបដោយសមធម៌ និងនិរន្តរភាព។ សហគមន៍នេសាទត្រពាំងសង្កែក៏បានរៀបចំផែនការមួយចំនួនដែលមានរយៈពេលប្រាំឆ្នាំ(២០១៧-២០២២)ផងដែរ។

### ២.៧.២.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោមនេះ ៖

តារាង២.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ក្នុងផ្ទៃសមុទ្រ ទំហំ៣៣៧ហ.ត របស់សហគមន៍នេសាទ | ពេញមួយឆ្នាំ | មងត្រីផ្សេងៗ | ៣០០ម/គ្រួសារ | ៥០គ្រួសារ | |
| | ពេញមួយឆ្នាំ | លបក្ដាម | ៤០គ្រឿង/គ្រួសារ | ២០គ្រួសារ | |
| | ពេញមួយឆ្នាំ | សំណាញ់ | ១វង់/គ្រួសារ | មិនកំណត់ | |
| | ពេញមួយឆ្នាំ | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ១៥គ្រួសារ | |
| | ពេញមួយឆ្នាំ | សន្ទូចមឹក | ៥០ផ្លែ/គ្រួសារ | ៥០គ្រួសារ | |
| | ពេញមួយឆ្នាំ | សន្ទូចដង | ១ផ្លែ/គ្រួសារ | មិនកំណត់ | |
| | ពេញមួយឆ្នាំ | មងបង្គា | ២០០ម៉ែត្រ/គ្រួសារ | ១៧គ្រួសារ | |
| | ពេញមួយឆ្នាំ | ឈឺបរុញដៃ | ១គ្រឿង/គ្រួសារ | ៣០០គ្រួសារ | |
| | ពេញមួយឆ្នាំ | ឆ្នុះបង្គារ | ១គ្រឿង/គ្រួសារ | ៤៥០គ្រួសារ | |
| | ពេញមួយឆ្នាំ | រាវបង្គារ | ២នាក់/គ្រួសារ | មិនកំណត់ | |
| | ពេញមួយឆ្នាំ | លូកក្ដាម(ខ្វា) | ១គ្រឿង/គ្រួសារ | មិនកំណត់ | |
| | ពេញមួយឆ្នាំ | រាវគ្រែង | ២នាក់/គ្រួសារ | មិនកំណត់ | |
| | ពេញមួយឆ្នាំ | រើសសារ៉ាយ | ២នាក់/គ្រួសារ | មិនកំណត់ | |
| - ព្រែកក្បាលរមាស - ព្រែកកំពង់ត្នោត | ពេញមួយឆ្នាំ | មងត្រីផ្សេងៗ | ១៤០ម/គ្រួសារ | ៥គ្រួសារ | |
| | ពេញមួយឆ្នាំ | លបក្ដាម | ២០គ្រឿង/គ្រួសារ | ៥គ្រួសារ | |
| | ពេញមួយឆ្នាំ | សំណាញ់ | ១វង់/គ្រួសារ | មិនកំណត់ | |

| | | | | | |
|---|---|---|---|---|---|
| - ព្រៃកស្ពានខៀវ (តាមព្រៃកនីមួយៗ) | ពេញមួយឆ្នាំ | សន្ទូចរនង | ១០០ផ្លែ/គ្រួសារ | ៥គ្រួសារ | |
| | ពេញមួយឆ្នាំ | សន្ទូចដង | ១ផ្លែ/គ្រួសារ | មិនកំណត់ | |
| | ពេញមួយឆ្នាំ | ឈឺបរុញដៃ | ១គ្រឿង/គ្រួសារ | ៧គ្រួសារ | |
| | ពេញមួយឆ្នាំ | ផ្ទងផាង | ១វង់/គ្រួសារ | ២៥គ្រួសារ | |
| | ពេញមួយឆ្នាំ | ឆ្នុះបង្គារ | ១គ្រឿង/គ្រួសារ | ២០គ្រួសារ | |
| | ពេញមួយឆ្នាំ | រាវបង្គារ | ២នាក់/គ្រួសារ | មិនកំណត់ | |
| | ពេញមួយឆ្នាំ | លូកក្តាម(ខ្វា) | ១គ្រឿង/គ្រួសារ | មិនកំណត់ | |

(ឧបសម្ព័ន្ធទី៣)

### ២.៧.២.២. ផែនការកែលម្អដែននេសាទ

ក្រៅពីផែនការដូចដែលបានរៀបចំឡើងខាងលើនេះ សហគមន៍នេសាទត្រពាំងសង្កែបានធ្វើការរៀបចំឡើងនូវផែនការផ្សេងៗមួយចំនួនទៀត នៅក្នុងគោលបំណងដើម្បីកែលម្អ ថែរក្សាដែននេសាទឲ្យបានស្អាត និងស្ថិតស្ថេរ។ សហគមន៍នេសាទត្រពាំងសង្កែ បានរៀបចំផែនការកែលម្អដែននេសាទដែលត្រូវបានរៀបចំឡើងដូចខាងក្រោម៖

តារាង២.២ ផែនការកែលម្អដែននេសាទសហគមន៍

| ដែននេសាទ | ទំហំ (ហិចតា) | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម-បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| កន្លែងសហគមន៍នេសាទត្រពាំងសង្កែ | ៣៣៧ ហ.ត | ៣៣៧ ហ.ត | ស្វែងរកម្ចាស់ជំនួយ (ធ្វើគម្រោងស្នើសុំ) | ២០១៧-២០១៩ | |
| | | | ប្រជុំផ្សព្វផ្សាយ | ២០១៧-២០១៩ | |
| | | | កំណត់ទីតាំង | ២០១៧-២០១៩ | |
| | | | បោះបង្គោលព្រំបន្ថែម | ២០១៨-២០២១ | |
| កន្លែងនេសាទសហគមន៍ | ពង្រីកបន្ថែម | ពង្រីកបន្ថែម | ស្វែងរកម្ចាស់ជំនួយ (ធ្វើគម្រោងស្នើសុំ) | ២០១៨-២០១៨ | |
| | | | ប្រជុំផ្សព្វផ្សាយ | ២០១៨-២០១៨ | |
| | | | កំណត់ពង្រីកកន្លែងនេសាទសហគមន៍ | ២០១៨-២០១៨ | |
| | | | រៀបចំផែនទីសម្រេច | ២០១៨-២០១៨ | |
| | | | បោះបង្គោលព្រំបន្ថែម | ២០១៨-២០២១ | |

(ឧបសម្ព័ន្ធទី៣)

### ២.៧.២.៣. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ដើម្បីធានាឲ្យបាននូវនិរន្តរភាពបរិស្ថាន និងការថែរក្សាប្រព័ន្ធអេកូឡូស៊ីសហគមន៍នេសាទត្រពាំងសង្កែបានរៀបចំនូវផែនការដើម្បីកំណត់ និងរៀបចំកន្លែងអភិរក្សដែលមានរៀបរាប់នៅក្នុងតារាងចខាងក្រោមនេះ៖

តារាង២.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម-បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| កន្លែងសហគមន៍នេសាទត្រពាំងសង្កែ | ៣៦ | - ត្រីមេពូជ<br>- ស្មៅសមុទ្រ<br>- សារ៉ាយសមុទ្រ | -ស្វែងរកជំនួយ<br>-បោះបង្គោលព្រំ<br>-ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងហាមឃាត់ប្រជាពលរដ្ឋដែលជាអ្នកនេសាទឱ្យបានទូលំទូលាយ<br>-ដាក់ប្រអប់សិប្បនិមិត្តលូសបន្លា និងចុះឃាមល្បាតការពារកន្លែងអភិរក្សរយៈពេល៥ឆ្នាំ | ២០១៧-២០១៨ | |

(ឧបសម្ព័ន្ធទី៣)

### ២.៧.២.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក

យើងដឹងហើយថា ព្រៃលិចទឹកគឺជាប្រភពជំរកត្រីដ៏សំខាន់មួយ ដោយវាបានផ្តល់ជាជំរកសម្រាប់ត្រីបន្តពូជ និងជាប្រភពសម្រាប់ទ្រទ្រង់បរិស្ថាននៅក្នុងទឹក។ ហេតុដូចនេះហើយដើម្បីបង្កើននូវបរិមាណទិន្នផលត្រី និងថែរក្សាបរិស្ថានជុំវិញបឹង សហគមន៍នេសាទត្រពាំងសង្កែបានរៀបចំផែនការគ្រប់គ្រងព្រៃលិចទឹកឡើងវិញដូចមាននៅក្នុងតារាងខាងក្រោម៖

តារាង២.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

| ឈ្មោះដែននេសាទ | ទំហំ (ហិចតា) | ប្រភេទព្រៃឈើការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| កន្លែងនេសាទសហគន៍ត្រពាំងសង្កែ | ៥៥ | ព្រៃកោងកាង | ផ្សព្វផ្សាយពីកន្លែងព្រៃលិចទឹកឱ្យបានទូលំទូលាយ | ២០១៧ | ២០១៨ | |
| | | | បោះបង្គោលព្រំព្រៃកោងកាងចំនួន២០បង្គោលនិងសរសេរស្លាកសញ្ញា | ២០១៧ | ២០១៨ | |
| | | | ដាំព្រៃកោងកាងចំនួន ៥០០០០ដើមបន្ថែម | ២០១៧ | ២០២២ | |
| | | | ថែរក្សាការពារនិងអភិរក្សព្រៃកោងកាង | ២០១៧ | ២០២២ | |

(ឧបសម្ព័ន្ធទី៣)

### ២.៧.២.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

សព្វថ្ងៃដោយសារតែកំណើនប្រជាជនចេះតែមានការកើនឡើងជារៀងរាល់ថ្ងៃ វាក៏បានធ្វើឱ្យតម្រូវការត្រីក៏មានការកើនឡើងផងដែរ នេះគឺជាហេតុដែលធ្វើឱ្យការផ្គត់ផ្គង់ត្រីតែមួយមុខគឺមិនគ្រប់គ្រាន់នោះទេ ដែលចាំបាច់តម្រូវឱ្យមានការអភិវឌ្ឍវារីវប្បកម្មឱ្យខានតែបាន។ ដើម្បីបំពេញតម្រូវការដែលកំពុងតែមានការខ្វះខាតនេះ សហគមន៍នេសាទត្រពាំងសង្កែបានរៀបចំផែនការអភិវឌ្ឍន៍វារីវប្បកម្មដែលជាកត្តារួមចំណែកផ្គត់ផ្គង់ដ៏មានសារៈសំខាន់មួយផងដែរនោះ ជាពិសេសគឺបានផ្តល់ឱ្យប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍នេសាទទាំងមូល មានលទ្ធភាពចិញ្ចឹមបាន ហើយផែនការនេះត្រូវបាននរៀបចំឡើងដូចខាងក្រោមនេះ៖

តារាង២.៥ ផែនការអភិវឌ្ឍន៍វារីវប្បកម្មនៅក្នុងសហាគមន៍នេសាទត្រពាំងសង្កែ

| ប្រភេទ វារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ចិញ្ចឹមត្រីតាមបៃចំនួន (៦គ្រួសារ) | ២បx២.៥មx៣មx១.៥ម | ត្រីឆ្តង់ | ២០០កូន/ឆ្នាំ | ២០១៧ | ២០២១ |
| | ២បx២.៥មx៣មx១.៥ម | ត្រីផ្ទក់ | ២០០កូន/ឆ្នាំ | ២០១៧ | ២០២១ |
| | ២បx២.៥មx៣មx១.៥ម | ត្រីតុកកែ | ២០០កូន/ឆ្នាំ | ២០១៧ | ២០២១ |
| ចិញ្ចឹមត្រីតាមស្រះចំនួន (១០គ្រួសារ) | ១៥មx១០មx២ម | ទីឡាព្យា អណ្តែង | ១០៥០០កូន/ឆ្នាំ | ២០១៧ | ២០២១ |

(ឧបសម្ព័ន្ធទី៣)

### ២.៧.២.៦. ផែនការសាងសង់ស្នាក់ការល្បាតសហាគមន៍នេសាទ

ផែនការសាងសង់ស្នាក់ការល្បាតសហាគន៍នេសាទ ត្រូវបានរៀបចំនៅមាត់ពាមចំណុចកោះលលក ដូចខាងក្រោមះ

តាងរាង២.៦ ផែនការសាង់សង់ស្នាក់ការល្បាត

| សកម្មភាព | លទ្ធផលរំពឹងទុក | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| សាងសង់ស្នាក់ការល្បាតដែលមានទំហំ៥មx៦ម | - សហាគមន៍មានស្នាក់ការល្បាតសម្រាប់ធ្វើការនៅពេលយប់<br>-មានលទ្ធភាពនៅក្នុងការពារកន្លែងនេសាទ | គណៈកម្មការសមាជិក ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០១៧ | ២០១៩ |
| បណ្តាញអគ្គិសនី(ស៊ុលឡា) | មានថាមពលអគ្គិសនីសម្រាប់ធ្វើការ | | ២០១៧ | ២០១៩ |

(ឧបសម្ព័ន្ធទី៣)

### ២.៧.២.៧. ផែនការថវិកាសម្រាប់ទ្រទ្រង់អភិវឌ្ឍន៍សហគមន៍នេសាទ

សហគមន៍នេសាទត្រពាំងសង្កែ បានធ្វើផែនការថវិកាសម្រាប់អភិវឌ្ឍន៍សហគមន៍ ដូចដែលមានរៀបចំឡើងខាងក្រោមនេះ៖

តារាង២.៧ ផែនការថវិកាសម្រាប់ទ្រទ្រង់អភិវឌ្ឍន៍សហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| ភាគទានសមាជិកភាពសហគមន៍នេសាទ | - ផ្សព្វផ្សាយការចូលរួមជាសមាជិក និងបង់ប្រាក់សមាជិក<br>- ប្រមូលភាគទាន១០០រៀល/ម្នាក់ | ២០១៧ | ២០២២ | ១០០០រៀលក្នុងម្នាក់ (៧៣៤នាក់) |
| ភាគទានប្រចាំឆ្នាំ | - ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទាន<br>- ប្រមូលភាគទានប្រចាំឆ្នាំសមាជិក ស.ន ១០០០រៀល/ម្នាក់ | ២០១៧ | ២០២២ | ១០០០រៀលក្នុងម្នាក់ |
| កម្រៃអ្នកនេសាទមិនមែនជាសមាជិក និងអ្នកមកពីក្រៅ | - ប្រមូលប្រាក់កម្រៃពីអ្នកនេសាទមិនមែនជាសមាជិក និងអ្នកមកពីក្រៅ ៥០០០រៀល/ម្នាក់ | ២០១៧ | ២០២២ | អ្នកនេសាទមិនមែនជាសមាជិកបានបង់កម្រៃប៉ាន់ប្រមាណ ៥០ទូក/ថ្ងៃ |
| សរសេរគម្រោងស្នើសុំថវិកាពីរាជរដ្ឋាភិបាល សប្បុរសជន និងអង្គការដៃគូ | - ទំនាក់ទំនងជាមួយរដ្ឋាភិបាល និងអង្គការដៃគូ<br>- សរសេរគម្រោងសំរាប់ស្នើសុំ<br>- តាមដាន និងត្រួតពិនិត្យបញ្ហានានានៅក្នុងសហគមន៍នេសាទ | ២០១៧ | ២០២២ | |

(ឧបសម្ព័ន្ធទី៣)

### ២.៧.៣. ផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍសហគមន៍នេសាទ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំឡើងដូចខាងក្រោមនេះ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តន៍តាមដាន ត្រួតពិនិត្យ និងធ្វើការវាយតម្លៃលើការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗជាពិសេសអំពីបញ្ហានេសាទ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង និងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការស្វែងរកថវិការសំរាប់ទ្រទ្រង់សហគមន៍នេសាទជាដើម។
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញពាក់ព័ន្ធ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្របច្ចេកទេស និងថវិកាសម្រាប់ដំណើរការអនុវត្តន៍ផែនការ។
- រៀបចំផែនការ ធ្វើការអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់ និងផែនការសកម្មភាពប្រចាំឆ្នាំ។
- ទាក់ទងជាមួយរដ្ឋបាលជលផល អង្គការ និងស្ថាប័នពាក់ព័ន្ធ ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ។
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ។
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍។
- ពង្រឹងសមត្ថភាពបច្ចេកទេសបន្ថែមទៀត ទៅលើការគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ។

- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទនីមួយៗ ដើម្បីចូលរួមអនុវត្តន៍ផែនការ។
- ធ្វើសមាហរណកម្មបញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទ ទៅក្នុងផែនការអភិវឌ្ឍន៍ភូមិ ឃុំ និងផែនការស្ថាប័ននានា។
- រៀបចំធ្វើស្នាក់ការល្បាតសហគមន៍នេសាទចំនួនមួយខ្នង និងទិញទូកម៉ាស៊ីនចំនួន១គ្រឿងសម្រាប់គ្រប់គ្រង និងថែរក្សាការពារកន្លែងនេសាទសហគមន៍។

តាមរយៈការរៀបចំផែនការ និងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍នេសាទនេះ សហគមន៍នេសាទមានការរំពឹងទុកថា ប្រជាពលរដ្ឋនៅក្នុងសហគមន៍ទាំងមូលនឹងចូលរួមសហការក្នុងដំណើរការគម្រោងនេះប្រកបដោយការយកចិត្តទុកដាក់ និងការទទួលខុសត្រូវខ្ពស់។ បន្ថែមពីនេះទៀត តាមរយៈការអភិវឌ្ឍនេះប្រជាពលរដ្ឋនៅក្នុងសហគមន៍នឹងមានជីវភាពល្អប្រសើរឡើងមួយកម្រិតទៀត ដែលជាហេតុធ្វើឱ្យសហគមន៍នេសាទមានការរីកចម្រើនឡើង និងមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងសមធម៌។

## ២.៨. ចំនួនអ្នកនេសាទ ឧបករណ៍ និងអនុផលនេសាទ

### ២.៨.១. អ្នកនេសាទ

- អ្នកនេសាទដែលជាសមាជិកសហគមន៍មានចំនួន៥១៣នាក់ ស្រី៧៦នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកនៅក្នុងសហគមន៍មានចំនួន ២,០២៧នាក់ ស្រី៣០៤នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិក ដែលមកពីក្រៅសហគមន៍នេសាទមានចំនួន៨៧២នាក់ស្រី១៣១នាក់។

### ២.៨.២. ឧបករណ៍នេសាទ

ការប្រើប្រាស់ឧបករណ៍សម្រាប់នេសាទ គឺវាពិតជាការសំខាន់ណាស់នៅក្នុងការប្រកបរបរនេសាទពិសេសអ្នកនេសាទជាប្រចាំថ្ងៃដើម្បីទទួលបានផលនេសាទច្រើន។ ប៉ុន្តែតែនៅក្នុងនោះផងដែរការប្រើប្រាស់ឧបករណ៍នេសាទក៏ត្រូវទាមទារឱ្យសមស្របជាមួយលក្ខន្តិកៈ និងបទបញ្ជារបស់សហគមន៍នេសាទដែលបានចែងកំណត់នោះដែរ។ ដើម្បីឱ្យសមស្របតាមគោលការណ៍នៃការអភិរក្ស ការពារ ថែរក្សា និងការប្រើប្រាស់ធនធានដោយនិរន្តរភាព។

ក្នុងនោះដែលសហគមន៍នេសាទត្រពាំងសង្កែក៏មាននូវឧបករណ៍នេសាទ និងទូកកាណូតដូចជា៖

តារាង២.៨ ៖ គ្រឿងឧបករណ៍នេសាទដែលអនុញ្ញាតឲ្យប្រើសម្រាប់សមាជិកសហគមន៍នេសាទត្រពាំងសង្កែ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|---|
| មងត្រីផ្សេងៗ | ម៉ែត្រ | ៣៧ | ៤០០ម/គ្រួសារ | ១៤,៨០០ម | ពេញមួយឆ្នាំ |
| លបក្តាម | គ្រឿង | ៥ | ៥០គ្រឿង/គ្រួសារ | ២៥០គ្រឿង | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ៧ | ១វង់/គ្រួសារ | ៥វង់ | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៧ | ៣០០ផ្លែ/គ្រួសារ | ២,១០០ផ្លែ | ពេញមួយឆ្នាំ |
| សន្ទូចមឹក | ផ្លែ | ៣០ | ៦០ផ្លែ/គ្រួសារ | ១,៨០០ផ្លែ | ពេញមួយឆ្នាំ |
| សន្ទូចដង | ផ្លែ | ២៥ | ១ផ្លែ/គ្រួសារ | ២៥ផ្លែ | ពេញមួយឆ្នាំ |
| មងបង្គា | ម៉ែត្រ | ៦ | ៣០០ម/គ្រួសារ | ១,៨០០ម | ពេញមួយឆ្នាំ |
| ឈឺបរុញដៃ | គ្រឿង | ៤១៥ | ១គ្រឿង/គ្រួសារ | ៥០វង់ | ពេញមួយឆ្នាំ |
| មងអួនអូស | ម៉ែត្រ | ៥ | ១២ម/គ្រួសារ | ៦០ម | ពេញមួយឆ្នាំ |
| ផ្ទងជាង | វង់ | ២៥ | ២វង់/គ្រួសារ | ៥០វង់ | ពេញមួយឆ្នាំ |
| ឆ្នុះបង្គារស្មរចាក់ | គ្រឿង | ៣១៤ | ១គ្រឿង/គ្រួសារ | ៣១៤គ្រឿង | ពេញមួយឆ្នាំ |
| រាវបង្គារ | នាក់ | ៩០ | ២នាក់/គ្រួសារ | ១៨០នាក់ | ពេញមួយឆ្នាំ |
| លូកក្តាម(ខ្វា) | គ្រឿង | ១៥០ | ១គ្រឿង/គ្រួសារ | ១៥០គ្រឿង | ពេញមួយឆ្នាំ |
| រាវគ្រែង | នាក់ | ៤៨ | ២នាក់/គ្រួសារ | ៩៦នាក់ | ពេញមួយឆ្នាំ |
| រើសសារ៉ាយ | នាក់ | ៧៨ | ២នាក់/គ្រួសារ | ១៥៦នាក់ | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៥៥គ្រឿង | ៣០០-១,០០០គីឡូក្រាម | ៦-២២សេះ |
| ទូកអុំ និងចែវ | ២៥គ្រឿង | ៥០-១០០គីឡូក្រាម | |

(ឧបសម្ព័ន្ធទី៣)

សហាគមន៍នេសាទ ក៏បានអនុញ្ញាតឲ្យប្រើប្រាស់នូវឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកនៅសហាគមន៍នេសាទ។

តារាង២.៩ គ្រឿងឧបករណ៍នេសាទ ដែលអនុញ្ញាតឲ្យប្រើសម្រាប់ប្រាស់អ្នកមិនមែនជាសមាជិកសហាគមន៍នៅក្នុងតំបន់

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ ឧបករណ៍ |
|---|---|---|---|---|---|
| មងត្រីផ្សេងៗ | ម៉ែត្រ | ១០២ | ៤០០ម/គ្រួសារ | ៤០,៨០០ម | ពេញមួយឆ្នាំ |
| លបក្ដាម | គ្រឿង | ១៣ | ៥០គ្រឿង/គ្រួសារ | ៦៥០គ្រឿង | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ១៤ | ១វង់/គ្រួសារ | ១៤វង់ | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ១៩ | ៣០០ផ្លែ/គ្រួសារ | ៥,៧០០ម | ពេញមួយឆ្នាំ |
| សន្ទូចមឹក | ផ្លែ | ៨៣ | ៦០ផ្លែ/គ្រួសារ | ៤,៩៨០ផ្លែ | ពេញមួយឆ្នាំ |
| សន្ទូចដង | ផ្លែ | ៥៩ | ១ផ្លែ/គ្រួសារ | ៥៩ផ្លែ | ពេញមួយឆ្នាំ |
| មងបង្គា | ម៉ែត្រ | ១៧ | ៣០០ផ្លែ/គ្រួសារ | ៥,១០០ម | ពេញមួយឆ្នាំ |
| ឈឺបរុញដៃ | គ្រឿង | ១,១៤៦ | ១គ្រឿង/គ្រួសារ | ១,១៤៦គ្រឿង | ពេញមួយឆ្នាំ |
| មងអួនអូស | ម៉ែត្រ | ១៤ | ១២ម/គ្រួសារ | ១៦៨ម | ពេញមួយឆ្នាំ |
| ផ្នូងផាង | វង់ | ៥៩ | ២វង់/គ្រួសារ | ១១៨វង់ | ពេញមួយឆ្នាំ |
| ឆ្នុះបង្គារស្នរចាក់ | គ្រឿង | ៨៦៧ | ១គ្រឿង/គ្រួសារ | ៨៦៧គ្រឿង | ពេញមួយឆ្នាំ |
| រាវបង្គារ | នាក់ | ២៤៨ | ២នាក់/គ្រួសារ | ៤៩៦នាក់ | ពេញមួយឆ្នាំ |
| លូកក្ដាម(ខ្វា) | គ្រឿង | ៤១៤ | ១គ្រឿង/គ្រួសារ | ៤១៤គ្រឿង | ពេញមួយឆ្នាំ |
| រាវគ្រែង | នាក់ | ១៣២ | ២នាក់/គ្រួសារ | ២៦៤នាក់ | ពេញមួយឆ្នាំ |
| រើសសារ៉ាយ | នាក់ | ២១៥ | ២នាក់/គ្រួសារ | ៤៣០នាក់ | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៥៦គ្រឿង | ៤០០-៥០០គីឡូក្រាម | ៦-៥សេះ |
| ទូកអុំ និងចែវ | ៧២គ្រឿង | ១០០-២០០គីឡូក្រាម | |

(ឧបសម្ព័ន្ធទី៣)

សហាគមន៍នេសាទ ក៏បានអនុញ្ញាតផងដែរនូវការប្រើប្រាស់ឧបករណ៍នេសាទ និងទូកកាណូត របស់អ្នកមិនមែនជាសមាជិកសហាគមន៍ដែលមកពីខាងក្រៅសហាគមន៍ ដែលចូលមកនេសាទនៅក្នុងដែននេសាទរបស់សហាគមន៍ត្រពាំងសង្កែ។

តារាង២.១០ គ្រឿងឧបករណ៍នេសាទដែលអនុញ្ញាតឲ្យប្រើសម្រាប់អ្នកមិនមែនជាសមាជិកសហាគមន៍ និងអ្នកនេសាទមកពីក្រៅសហាគមន៍

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|---|
| មងត្រីផ្សេងៗ | ម៉ែត្រ | ៤៣ | ៤០០ម/គ្រួសារ | ១៧,២០០ម | ពេញមួយឆ្នាំ |
| លបក្តាម | គ្រឿង | ៦ | ៥០គ្រឿង/គ្រួសារ | ៣០០គ្រឿង | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ៨ | ១វង់/គ្រួសារ | ៨វង់ | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៩ | ៣០០ផ្លែ/គ្រួសារ | ២,៧០០ផ្លែ | ពេញមួយឆ្នាំ |
| សន្ទូចមឹក | ផ្លែ | ៣៨ | ៦០ផ្លែ/គ្រួសារ | ២,២៨០ផ្លែ | ពេញមួយឆ្នាំ |
| សន្ទូចដង | ផ្លែ | ២៥ | ១ផ្លែ/គ្រួសារ | ២៥ផ្លែ | ពេញមួយឆ្នាំ |
| មងបង្គា | ម៉ែត្រ | ៧ | ៣០០ម/គ្រួសារ | ២,១០០ម | ពេញមួយឆ្នាំ |
| ឈឺបរុញដៃ | គ្រឿង | ៤៩៣ | ១គ្រឿង/គ្រួសារ | ៤៩៣គ្រឿង | ពេញមួយឆ្នាំ |
| មងអួនអូស | ម៉ែត្រ | ៦ | ១២ម/គ្រួសារ | ៧២ម | ពេញមួយឆ្នាំ |
| ផ្ងងផាង | វង់ | ២៥ | ២វង់/គ្រួសារ | ៥០វង់ | ពេញមួយឆ្នាំ |
| ឆ្នុះបង្គារស្នរចាក់ | គ្រឿង | ៣៧២ | ១គ្រឿង/គ្រួសារ | ៣៧២គ្រឿង | ពេញមួយឆ្នាំ |
| រាវបង្គារ | នាក់ | ១០៦ | ២នាក់/គ្រួសារ | ២១២នាក់ | ពេញមួយឆ្នាំ |
| លូកក្តាម(ខ្វា) | គ្រឿង | ១៧៨ | ១គ្រឿង/គ្រួសារ | ១៧៨គ្រឿង | ពេញមួយឆ្នាំ |
| រាវគ្រែង | នាក់ | ៥៦ | ២នាក់/គ្រួសារ | ១១២នាក់ | ពេញមួយឆ្នាំ |
| រើសសារ៉ាយ | នាក់ | ៩២ | ២នាក់/គ្រួសារ | ១៨៤នាក់ | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៦០គ្រឿង | ៤០០-១,០០គីឡូក្រាម | ៦-៥-១០ សេះ |

(ឧបសម្ព័ន្ធទី៣)

### ២.៨.៣. ការប៉ាន់ប្រមាណផលនេសាទប្រចាំឆ្នាំ

ទិន្នផលនេសាទដែលចាប់បានប្រចាំឆ្នាំ មានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ។ ក្នុងនោះផងដែរសហគមន៍នេសាទ បានធ្វើការប៉ាន់ស្មានទៅលើទិន្នផលនេសាទសរុបប្រចាំឆ្នាំ ដោយសរុបទៅលើគ្រួសារដែលបាននេសាទនៅក្នុងដែននេសាទសហគមន៍ត្រពាំងសង្កែដូចខាងក្រោម៖

តារាង២.១១ ការប៉ាន់ប្រមាណទិន្នផលនេសាទប្រចាំឆ្នាំរបស់សហគមន៍

| ប្រភេទផលនេសាទ | **បរិមាណផលនេសាទគិតជាមធ្យមប្រចាំគ្រួសារ (គិតជា គក = គីឡូក្រាម) (គ្រួសារអ្នកនេសាទ)** | | |
|---|---|---|---|
| | **រដូវប្រាំង** | **រដូវវស្សា** | **សរុបប្រចាំឆ្នាំ** |
| ត្រីចម្រុះ | ៩៩៥ គក | ៩៨៥ គក | ១,៩៨០ គក |
| ក្រែង | ២,៤៦៤ គក | ២,៣៣៦ គក | ៤,៨០០ គក |
| ក្តាម | ៦៩ គក | ៦៧ គក | ១៣៦ គក |
| មឹក | ៥៤៨ គក | ៥៣២ គក | ១,០៨០ គក |
| បង្គារ | ៦២ គក | ៥៩ គក | ១២១ គក |
| ផ្សេងៗ | - | - | - |

(ឧបសម្ព័ន្ធទី៣)

# ជំពូក៣

# ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

## ៣.១. ការវិភាគលើស្ថានភាពរបស់សហគមន៍នេសាទត្រពាំងសង្កែ

### ៣.១.១. ស្ថានភាពរស់នៅមុនពេលបង្កើតសហគមន៍នេសាទត្រពាំងសង្កែ

មុនពេលបង្កើតនូវសហគមន៍នេសាទត្រពាំងសង្កែ ប្រជាជនដែលរស់នៅក្នុងភូមិភាគច្រើនរស់នៅក្នុងសភាពក្រីក្រ ដោយពួកគាត់ប្រកបមុខរបរចិញ្ចឹមជីវិតដោយពឹងផ្អែកលើការនេសាទ និងការធ្វើស្រែចំការខ្លះៗតែប៉ុណ្ណោះ។ លើសពីនេះទៀត មុនពេលមិនទាន់បង្កើតនូវសហគមន៍នេសាទឡើងគេឃើញមានបទល្មើសនេសាទកើតឡើងពាសពេញភូមិទាំងមូលដូចជា ការកាប់បំផ្លាញព្រៃកោងកាងដែលជាជំរកសំខាន់របស់ត្រី ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ដូចជា ស្បៃមុង ការឆក់ និងការឈ្លានពានដែននេសាទពីសំណាក់ប្រទេសជិតខាងជាដើម។ មិនត្រឹមតែប៉ុណ្ណោះទេ គេក៏ឃើញមានបញ្ហាបរិស្ថានដែលគ្មានការថែរក្សាឲ្យបានត្រឹមត្រូវដែលជាហេតុធ្វើឲ្យទិន្នផលត្រីមានការថយចុះជាខ្លាំង។ ចំណែកស្ថានភាពរស់នៅ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានសភាពដុនដាបយ៉ាងខ្លាំង ដោយពួកគេគ្មានលទ្ធភាពដើម្បីទ្រទ្រង់ជីវភាពគ្រួសារ ព្រោះការនេសាទត្រីទទួលបានទិន្នផលទាប ហើយបែរជាងាកទៅរកខ្ចីបំណុលគេដើម្បីមកដោះស្រាយជីវភាពរស់នៅរបស់ពួកគាត់។ ពួកគេបាននិយាយថា មូលហេតុដែលការនេសាទទទួលបានទិន្នផលទាបគឺដោយសារតែពួកគេខ្វះខាតបច្ចេកទេស មានអ្នកនេសាទកើនឡើងច្រើនជាពិសេសការនេសាទខុសច្បាប់ជាច្រើន ដោយពុំមានការហាមឃាត់ និងមិនមានការសហការពីមន្ត្រីជំនាញពាក់ព័ន្ធជាដើម។

លើសពីនេះទៅទៀត បញ្ហាទាំងអស់នេះវាបានជះឥទ្ធិពលទៅដល់ការសិក្សាអប់រំកូនៗរបស់ពួកគេ ដោយពុំមានលទ្ធភាពផ្គត់ផ្គង់នូវសម្ភារៈសិក្សា និងថ្លៃសិក្សាបានឡើយដោយពួកគេជាទូទៅមានលទ្ធភាពរៀនសូត្របានត្រឹមកម្រិតបឋមសិក្សាតែប៉ុណ្ណោះ។ ដូចច្នេះពួកគេ ក៏បង្ខំចិត្តបោះបង់ការសិក្សាចោលដើម្បីជួយឪពុកម្ដាយរបស់ពួកគេ ដោយជួយការងារផ្ទះ ការងារនេសាទ និងការងារកសិកម្មដើម្បីជួយសម្រួលបន្ទុកគ្រួសារ។ ទន្ទឹមនឹងនេះផងដែរ ការផ្ដល់តំលៃទៅលើស្ត្រីក៏នៅមានកម្រិតនៅឡើយដោយសារពួកគាត់ត្រូវទទួលបានការមើលងាយ និងអំពើហឹង្សារពីពួកបុរសៗ ព្រោះថាបុរសៗគឺជាអ្នកប្រកបមុខរបរចិញ្ចឹមគ្រួសារទាំងមូល ចំណែកឯស្ត្រីនៅតែធ្វើការងារផ្ទះតែប៉ុណ្ណោះ។ ម៉្យាងវិញទៀត ការអនុវត្តច្បាប់នៅពេលនោះ នៅមានសភាពធូររលុងដែលជាហេតុធ្វើឲ្យការបញ្ជ្រាបយេនឌ័រ ក៏ខ្សោយទៅតាមហ្នឹងដែរ។ ចំពោះផ្នែកការថែទាំសុខភាព

និងសុខុមាលភាព វិញនៅពេលមានជម្ងឺពួកគាត់ពុំមានលទ្ធភាពនៅក្នុងការបង់ថ្លៃព្យាបាលជម្ងឺឡើយដោយពួកគាត់ពឹងផ្អែកទៅលើជំនឿពីបុរាណ និងការប្រើប្រាស់ថ្នាំបុរាណជាដើម។

តាមរយៈស្ថានភាពទាំងអស់នេះហើយ វាបានឆ្លុះបញ្ចាំងបានថា ស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមុនពេលមិនទាន់បង្កើតសហគមន៍នេសាទពិតជាមានភាពលំបាកជាខ្លាំង ដែលជាហេតុធ្វើឲ្យមានគំនិតនៃការបង្កើតសហគមន៍នេសាទឡើង ដោយមានការចូលរួមផ្តល់ជាយោបល់ពីរដ្ឋបាលជលផល អង្គការក្រៅរដ្ឋាភិបាល (NGOs) និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។

### ៣.១.២. ស្ថានភាពរស់នៅក្រោយពេលបង្កើតសហគមន៍នេសាទត្រពាំងសង្កែ

ក្រាហ្វិក៣.១៖ បង្ហាញពីស្ថានភាពរស់នៅក្រោយពេលបង្កើតសហគមន៍នេសាទត្រពាំងសង្កែ




យោងទៅតាមក្រាហ្វិកដែលបានពីឯកសារចាស់ក្នុងឆ្នាំ ២០១៦ ស្តីពីស្ថានភាពនៃការគ្រប់គ្រងសហគមន៍នេសាទត្រពាំងសង្កែ ដែលគេបានធ្វើការសម្ភាសន៍ប្រជាពលរដ្ឋចំនួន៨៣គ្រួសារបានបង្ហាញទិន្នន័យថាការនេសាទបានជួយជីវភាពប្រជាជនក្នុងសហគមន៍ចំនួន ៧៣% បើធៀបទៅនឹងការងារផ្សេងៗទៀត។ ក្នុងនោះការបង្កើតការងារបន្ថែម ដូចជាការងារដាំផ្សិត ដាំបន្លែចិញ្ចឹមសត្វមានចំនួន ៥៤%។ ចំណែកនៅចុងឆ្នាំ ២០១៥ គម្រោងរបស់អង្គការ FACT បានធ្វើការប្រជុំផ្សព្វផ្សាយ ពង្រឹងសមត្ថភាព និងបានផ្តល់នូវចំណេះដឹងទាក់ទងទៅនឹងសារៈប្រយោជន៍របស់ព្រៃកោងកាង។ នៅក្នុងនោះក៏បានរៀបចំឲ្យមានក្រុមដាំបន្លែសរីរាង្គចំនួន ១០គ្រួសារដើម្បីទ្រទ្រង់ជីវភាពរស់នៅ ដោយផ្តល់នូវបច្ចេកទេសដាំដំណាំ ការទស្សនៈកិច្ចសិក្សាពូជ ជីកំប៉ុស្តិ៍ និងបង្គោលរបងព័ទ្ធជុំវិញផងដែរ។ ចំណែកឯ ផ្នែកសេវាកម្មទេសចរណ៍នៅក្នុងសហគមន៍នេសាទមានដូចជា

ការជួលបន្ទប់ ការការពារសន្តិសុខ អាហារដ្ឋាន ជូនភ្ញៀវទេសចរស្នាក់នៅ និងដាំកោងកាងជាដើម មានចំនួន ៣៩% និងការលក់ដូរផ្សេងៗ មានចំនួន ២៤%។ ក្រៅពីនេះ ក៏មានការងារបើកទូកដើម្បីជូនភ្ញៀវទេសចរទស្សនាព្រៃកោងកាង មើលអំពិលអំពែកនៅពេលយប់ចំនួន ១៦% ដោយសារភ្ញៀវទេសចរមិនមានជាប្រចាំនោះទេ។ បន្ថែមពីនេះ នៅក្នុងសហគមន៍នេសាទត្រពាំងសង្កែមានមូលនិធិបដិភាគសម្រាប់ជួយដល់គ្រួសារក្រីក្រលំបាក មិនមានលទ្ធភាពប្រកបមុខរបរផ្សេងៗ សម្រាប់ជួសជុលផ្ទះ និងសម្ភារៈផ្សេងៗ ចំនួន ៧% ប៉ុណ្ណោះ។ ដោយសារនេះជាប្រាក់បដិភាគដោយស្ម័គ្រចិត្ត និងមិនមានការឧបត្ថម្ភច្រើននោះទេ។

បន្ថែមពីការវិភាគទិន្នន័យលើឯកសារចាស់ដែលគេបានសិក្សាស្រាវជ្រាវក្នុង ឆ្នាំ ២០១៦ ដោយពួកយើងខ្ញុំ បានធ្វើការសាកសួរពីប្រជាពលរដ្ឋ និងសម្ភាសន៍ជាមួយលោក **ស៊ឹម ហ៊ីម** ដែលជាប្រធានសហគមន៍នេសាទត្រពាំងសង្កែបន្ថែមរួចមកបង្ហាញថា ក្រោយពីការបង្កើតសហគមន៍នេសាទពីឆ្នាំ ២០០៩ មកដល់ឆ្នាំ ២០១៩ នេះកម្រិតជីវភាពប្រជាជនមានការប្រសើរឡើងជាងមុនតាមរយៈការទាញយកធនធានធម្មជាតិក្នុងសហគមន៍មកប្រើប្រាស់ គឺការប្រកបរបរនេសាទនៅក្នុងដែនសហគមន៍ និងការបង្កើតឱ្យមាននៅតំបន់ទេសចរណ៍នៅក្នុងសហគមន៍នេសាទផ្ទាល់។ ផ្សេងពីនេះក៏មានការលក់ដូរនៅតាមភូមិនីមួយៗផងដែរ។ ការប្រកបរបរលក់ដូរនេះទាមទារឲ្យមានអតិថិជនច្រើន ដើម្បីឲ្យការលក់ដូរទទួលបានប្រាក់កំរៃខ្ពស់ ដែលជំរុញឲ្យជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់សហគមន៍នេសាទប្រសើរឡើង។ ក្នុងនោះដែលប្រជាពលរដ្ឋមួយចំនួនបានទៅចូលរួមធ្វើម្ហូប បើកទូកជូនភ្ញៀវទេសចរ និងសកម្មភាពផ្សេងៗទៀត ដើម្បីទទួលបានប្រាក់កំរៃពីវិស័យអេកូទេសចរណ៍ របស់សហគមន៍នេសាទត្រពាំងសង្កែ។ ក្រៅពីនេះទៀត សហគមន៍នេសាទបានធ្វើការបណ្តុះបណ្តាលប្រជាជនពីវិធីសាស្ត្របណ្តុះផ្សិត ដាំបន្លែ និងចិញ្ចឹមសត្វដែលពួកគាត់អាចយកទៅប្រកបរបរប្រចាំថ្ងៃបាន ទាំងនេះដោយសារតែមានការចូលរួមជួយផ្សព្វផ្សាយបណ្តុះបណ្តាលបច្ចេកទេស និងមានការសហការពីអង្គការម្ចាស់ជំនួយ និងសមាជិកគណៈកម្មការសហគមន៍នេសាទផងដែរ។

លើសពីនេះទៀត ទិន្នផលត្រីក៏មានការកើនឡើងជាងមុន ដោយសារតែមានការរៀបចំគ្រប់គ្រង និងថែរក្សាពីប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ ហើយពួកគាត់ក៏ទទួលបានការអប់រំពីស្ថាប័នពាក់ព័ន្ធ ដែលបានធ្វើឱ្យបទល្មើសនេសាទត្រូវបានកាត់បន្ថយផងដែរ។ បន្ថែមពីនេះ ពួកគាត់ថែមទាំងបាននាំគ្នាចូលរួមថែរក្សាអភិរក្ស និងជួយដាំព្រៃកោងកាងនៅតំបន់ដែននេសាទរបស់សហគមន៍ ដែលជាជម្រកមួយដ៏សំខាន់សម្រាប់ត្រីបង្ករកំណើត។

ជាការពិតណាស់ ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងសហគមន៍មានការប្រសើរឡើងជាងមុន ដោយពួកគាត់អាចផ្គត់ផ្គង់ជីវភាពរស់នៅបាន និងមានជម្រកសមរម្យសម្រាប់រស់នៅ ហើយយើងក៏សង្កេតឃើញមានការរីកចម្រើនលើផ្នែកមួយចំនួនទៀតដែលមានដូចជា៖

➢ **ការផ្តល់តម្លៃដល់តួនាទីស្ត្រី**

សព្វថ្ងៃនេះដោយសារតែស្ត្រី និងបុរសមានសិទ្ធិស្មើគ្នា ដែលធ្វើឱ្យការចូលរួមរបស់ស្ត្រីនៅតាមស្ថាប័ននានា និងជាពិសេសនៅតាមសហគមន៍ដែលផ្តល់ឱ្យពួកគេនូវការទទួលស្គាល់ជាផ្លូវការ និងការបញ្ចេញយោបល់នៃការសម្រេចចិត្តក្នុងកិច្ចការងារផ្សេងៗ ដោយពួកគេអាចចូលរួមធ្វើសកម្មភាពនៅក្នុងក្របខណ្ឌដ៏សំខាន់មួយក្នុងកិច្ចការពារ ការអភិរក្ស ការអប់រំ ការអភិវឌ្ឍ និងការផ្សព្វផ្សាយព័ត៌មានផ្សេងៗ។ លើសពីនេះទៅទៀត ស្ត្រីបានចូលរួមនៅក្នុងការចរចា អប់រំទៅលើជនល្មើសជលផល និងទប់ស្កាត់បទល្មើសនានានៅក្នុងសហគមន៍ផងដែរ។ តាមរយៈនេះ វាបានបង្ហាញឱ្យឃើញនូវតួនាទីដ៏សំខាន់ ក្នុងការធ្វើការសម្រេចចិត្ត និងកិច្ចការងារអភិវឌ្ឍន៍សហគមន៍។

➢ **សេរីភាព និងសិទ្ធិកាន់កាប់**

ការផ្តួចផ្តើមបង្កើតនូវសហគមន៍នេសាទ បានធ្វើឱ្យមានការផ្លាស់ប្តូរទាំងស្រុងនូវលក្ខណៈនៃការប្រើប្រាស់ធនធានធម្មជាតិ ដែលជាផ្នែកសំខាន់មួយនៃការបែងចែកធនធានប្រកបដោយសមធម៌។ ចំណែកឯ ប្រជាពលរដ្ឋដែលរស់នៅតំបន់សហគមន៍នេសាទត្រពាំងសង្កែទទួលបាននូវសិទ្ធិសេរីភាព និងកាន់កាប់ដូចជា៖

- សេរីភាពនៅក្នុងការបញ្ចេញមតិទាក់ទងនឹងទុកកង្វល់របស់ខ្លួន
- សេរីភាពនៅក្នុងការប្រើប្រាស់ធនធានជលផល ដែលមាននៅក្នុងសហគមន៍នេសាទដើម្បីប្រកបរបរចិញ្ចឹមជីវិត
- ប្រជាពលរដ្ឋមានសិទ្ធិ រិះគន់ និងជួយកែលម្អដល់សហគមន៍នេសាទដើម្បីធ្វើការអភិវឌ្ឍន៍សហគមន៍ឱ្យបានរីកចម្រើនទៅមុខ
- ប្រជាពលរដ្ឋមានសិទ្ធិស្មើរៗគ្នា នៅក្នុងការការពារ និងអភិរក្សធនធានជលផលជាដើម។

➢ **សុខភាព និងសុខមាលភាព**

ចាប់តាំងពីបង្កើតសហគមន៍នេសាទត្រពាំងសង្កែមក គេក៏ឃើញមានអង្គការដៃគូពាក់ព័ន្ធរួមជាមួយប្រធានសហគមន៍នេសាទត្រពាំងសង្កែ ចុះជួយពន្យល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីរបៀបថែរក្សាសុខភាពនិងអប់រំប្រជាពលរដ្ឋឱ្យចេះមានអនាម័យក្នុងការហូបចុក និងការរស់នៅផងដែរ។ មិនត្រឹមតែប៉ុណ្ណោះទេ នៅពេលដែលប្រជាពលរដ្ឋពុំមានលទ្ធភាពគបង់ប្រាក់ទេនោះ សហគមន៍

ក៏មានកញ្ចប់ថវិកាមួយផ្នែកសម្រាប់ជួយនៅពេលមានគ្រោះអាសន្នផងដែរ។ តាមរយៈសមិទ្ធផលទាំងអស់នេះហើយ ប្រជាជនរស់នៅក្នុងសហគមន៍នេសាទទាំងមូលទទួលបាននូវផលប្រយោជន៍ជាច្រើនពីការអភិវឌ្ឍសហគមន៍ ដែលជាកត្តាមួយរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទផងដែរ។

➢ **ការកសាងធនធានមនុស្ស**

តាមការសម្ភាសន៍ជាមួយប្រធានសហគមន៍នេសាទលោក **ស៊ឹម ហ៊ីម** បានមានប្រសាសន៍ថាចាប់តាំងពីដំណើរការសហគមន៍នេសាទត្រពាំងសង្កែមក ឃើញមានកម្មវិធីជាច្រើនបានរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធដូចជា រដ្ឋបាលជលផលជាដើម ដើម្បីផ្តល់នូវវគ្គបណ្តុះបណ្តាលផ្សេងៗ និងការផ្តួចផ្តើមបង្កើតជំនាញនានាដល់សមាជិកសហគមន៍នេសាទ និងប្រជាជនក្នុងសហគមន៍។ តាមរយៈការបណ្តុះបណ្តាលទាំងនេះ បានធ្វើឱ្យពួកគាត់ទទួលបានផលប្រយោជន៍មួយចំនួនដូចជា៖

- ជួយអភិវឌ្ឍន៍ជំនាញ ដើម្បីធ្វើឱ្យប្រសើរឡើងនូវឱកាសក្នុងការចិញ្ចឹមជីវិតរស់នៅ ដោយពួកគាត់ទទួលបាននូវការបណ្តុះបណ្តាលលើការចិញ្ចឹមសត្វ ចិញ្ចឹមត្រី និងជំនាញកែលម្អគុណភាពសម្រាប់កែច្នៃម្ហូបអាហារ និងវិធីសាស្ត្រស្វែងរកទីផ្សារសម្រាប់លក់ជាដើម។
- ទទួលបាននូវចំណេះដឹងក្នុងការចាត់ចែង ដើម្បីធ្វើការគ្រប់គ្រងសហគមន៍នេសាទ ជាពិសេសនោះពួកគាត់ទទួលបាននូវការបណ្តុះបណ្តាល ការអប់រំផ្នែកភាពជាអ្នកដឹកនាំ គណនេយ្យ មូលដ្ឋាននៃការគ្រប់គ្រងហិរញ្ញវត្ថុ របៀបដោះស្រាយជម្លោះ និងបញ្ហាផ្សេងៗទៀតដែលកើតមានក្នុងសហគមន៍នេសាទត្រពាំងសង្កែ។
- ទទួលបានបណ្តុះបណ្តាលនូវបច្ចេកទេសបន្ថែម ការអនុវត្តជាក់ស្តែង ការវាយតម្លៃសក្តានុពលនៃធនធានជលផល និងការអភិរក្សធនធានជលផលក្នុងសហគមន៍។

ជាការពិតណាស់ ការអភិវឌ្ឍធនធានមនុស្ស គឺជាចំណែកសំខាន់សម្រាប់ការរីកចម្រើនរបស់សហគមន៍នេសាទ។ តាមរយៈការអភិវឌ្ឍនេះ ប្រជាពលរដ្ឋទទួលបានចំណេះដឹងកើនឡើងជាលំដាប់ ដោយពួកគាត់បានយល់អំពីច្បាប់ជលផល និងច្បាប់ផ្សេងៗទៀត ចេះថែរក្សាការពារ និងអភិរក្សតំបន់នេសាទដើម្បីឱ្យសហគមន៍នេសាទមានការរីកចម្រើនជានិរន្តរ៍។

សរុបមកចាប់តាំងពីសហគមន៍នេសាទត្រពាំងសង្កែបានបង្កើតឡើង គេសង្កេតឃើញថា ស្ថានភាពនៃការអភិវឌ្ឍរបស់សហគមន៍នេសាទ មានការរីកចម្រើនខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារតែមានការចូលរួមពីប្រជាពលរដ្ឋ អង្គការដៃគូ និងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត។

## ៣.២. សមិទ្ធិផលរបស់សហគមន៍នេសាទត្រពាំងសង្កែ

ចាប់តាំងពីការបង្កើតឡើងនូវសហគមន៍នេសាទក្នុងឆ្នាំ ២០០៩ រហូតមកដល់សព្វថ្ងៃនេះ នៅក្រោមការគ្រប់គ្រង និងការអភិវឌ្ឍន៍យ៉ាងល្អពីសំណាក់គណៈកម្មការសហគមន៍នេសាទ សមាជិកសហគមន៍នេសាទ អាជ្ញាធរ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ក៏ដូចជាប្រជាជនក្នុងមូលដ្ឋាន ដែលពួកគេបានខិតខំប្រឹងប្រែងធ្វើការងារសំខាន់ៗជាច្រើន ដូចជា ការផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធនឹងសារៈសំខាន់នៃព្រៃកោងកាង ការការពារធនធានជលផល ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍ជាដើម។ ក្នុងនោះដែលសហគមន៍ក៏បានសម្រេចនៅលទ្ធផលជោគជ័យជាច្រើនផងដែរដូចជា៖

- ការរៀបចំបង្កើតឡើងនូវគណៈកម្មការចម្រុះ ដើម្បីចុះសិក្សាវាយតម្លៃផលប៉ះពាល់ និងកំណត់ព្រំដែនគ្រប់គ្រងបណ្ដោះអាសន្នដល់សហគមន៍នេសាទត្រពាំងសង្កែ។
- ដំណើរការចុះត្រួតពិនិត្យ សិក្សាវាយម្លៃរបស់គណៈកម្មការចម្រុះស្ថាប័នក្នុងភូមិសាស្ត្រដែនគ្រប់គ្រងសហគមន៍នេសាទ។
- សម្រេចជោគជ័យលើផែនការកសាងបង្គោល ស្លាកសញ្ញា និងការទទួលខុសត្រូវការបោះបង្គោលព្រំប្រទល់ដែនគ្រប់គ្រងសហគមន៍នេសាទចំនួន ១៥ បង្គោល។
- រៀបចំលក្ខន្តិកៈសហគមន៍នេសាទ និងបទបញ្ជាផ្ទៃក្នុង (ឧបសម្ព័ន្ធទី២)
- រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទ (ឧបសម្ព័ន្ធ៤)
- ដំណើរការចុះចុចទីតាំងដែនគ្រប់គ្រងសហគមន៍នេសាទតាមប្រព័ន្ធ GPS ដោយអ្នកជំនាញ និងធ្វើផែនទីភូមិសាស្ត្រ។ (ឧបសម្ព័ន្ធទី៥)
- ទីស្នាក់ការសហគមន៍ និងសាលប្រជុំសម្រាប់សហគមន៍ ទំហំ(១២ម x ៨ម) ធ្វើអំពីឈើប្រក់ស្បូវ ដែលឧបត្ថមដោយអង្គការ Action Aid
- ថ្នាលបណ្ដុះកូនកោងកាង ទំហំ(១៥ម x ១០ម) និងទំហំ(២៥ម x ១៨ម) បណ្ដុះបានប្រមាណ ១៩មកូន ឧបត្ថម្ភដោយអង្គការ CWDCC និង Action Aid
- កន្លែងតំបន់អភិរក្ស (ព្រៃកោងកាងមានចំនួន៩ហិចតា ដាំដុះបន្ថែម ២៥ ហិចតា និងស្មៅសមុទ្រ ចំនួន ៤៥ហិចតា)។

- ទំលាក់ប្រអប់សិប្បនិម្មិត (ចំនួន៥៥ប្រអប់) សម្រាប់ជាជម្រកត្រីឧបត្ថម្ភដោយអង្គការAction Aid
- អាហារដ្ឋានសម្រាប់ភ្ញៀវទេសចរណ៍ (ទំហំ ៨ម x ៥ម) ធ្វើអំពីឈើប្រក់ស្បូវឧបត្ថម្ភដោយអង្គការ CWDCC
- បន្ទប់បឹងកាឡូសម្រាប់ភ្ញៀវទេសចរចំនួន ១៦បន្ទប់ នឹងបន្ទប់ទឹកចំនួន ៦បន្ទប់
- ផ្លូវចូលសហាគមន៍ប្រវែង ៣០០ម ដែលមានការគាំទ្រដោយ CYA
- ស្រះចិញ្ចឹមត្រីក្នុងសហាគមន៍ ទំហំ (១៥ម x ១២ម)
- ចំណតរថយន្ត ម៉ូតូកង់ ទំហំ (២៥ម x ១០ម)
- កន្លែងជួសជួលទូកមួយកន្លែង
- បណ្ណាល័យចំនួនមួយកន្លែងនៅក្នុងសហាគមន៍ផ្ទាល់។ល។

យោងតាមការសាកសួរផ្ទាល់ជាមួយប្រធានសហាគមន៍នេសាទត្រពាំងសង្កែ បានឱ្យដឹងថាកន្លងមកមានអង្គការមួយចំនួនដូចជា អង្គការ FACT អង្គការ CWDCC និងអង្គការដទៃទៀត ដោយបានសហការដោយផ្តល់ជាជំនួយជាបច្ចេកទេស ថវិកា ការអប់រំ ការស្តារកូនកោងកាង និងដាំកោងកាងឡើងវិញ។ ជាក់ស្តែងអង្គការ CWDCC និងរដ្ឋបាលជលផលខេត្តបានជួយជាបច្ចេកទេស និងសម្របសម្រួលក្នុងការបង្កើតសហាគមន៍នេះឡើង និងជាអ្នកសម្របសម្រួលលើការបង្កើតឡើងសហាគមន៍អេកូទេសចរណ៍ផងដែរ។ អង្គការ FACT បានស្តារព្រៃកោងកាងចំនួន ២៥ហិចតា ដើម្បីជួយឱ្យមាននិរន្តរភាពនៃជីវចម្រុះ និងពង្រឹងស្ថានភាពជីវភាពរបស់អ្នកនេសាទតាមរយៈការនេសាទក្នុងតំបន់ ព្រោះកោងកាងបានផ្តល់ជាពងកូនត្រី ជាជំរក ជាកន្លែងរកចំណីសម្រាប់ពពួកត្រីជាច្រើន និងការពារគ្រោះថ្នាក់ពីធម្មជាតិដូចជា ខ្យល់ព្យុះផងដែរ។ ហើយបានបង្កើតជាសួនបន្លែធម្មជាតិសម្រាប់ជាប្រភពចំណូល និងបង្កើនទំនាក់ទំនងប្រជាជនក្នុងមូលដ្ឋាន។ នៅក្នុងនោះដែល សហាគមន៍នេសាទក៏ទទួលបានការបណ្តុះបណ្តាលកម្មវិធីជាច្រើនដល់សមាជិកគណៈកម្មការ និងប្រជាជនដើម្បីលើកកម្ពស់ជីវភាពប្រជាជនឱ្យប្រសើរឡើងជាងមុន តាមរយៈការប្រកបរបរនេសាទ ការចូលរួមក្នុងវិស័យអេកូទេសចរណ៍ធម្មជាតិ និងលក់ដូរផលិតផលផ្សេងៗ។ កន្លងមកសហាគមន៍នេសាទត្រពាំងសង្កែ ធ្លាប់ទទួលបាននូវការកោតសរសើរទៅលើការអភិវឌ្ឍសហាគមន៍នេសាទពីរដ្ឋបាលជលផល មន្ទីរទេសចរណ៍ខេត្ត និងមន្ទីរបរិស្ថានផងដែរ។
(របាយការណ៍អង្គការ FACT, ២០១៥)

## ៣.៣. បញ្ហាប្រឈមប្រឈមចំពោះការអភិវឌ្ឍសហគមន៍នេសាទ

នៅក្នុងដំណើរការអភិវឌ្ឍន៍សហគមន៍នេសាទត្រពាំងសង្កែ ទោះបីជាមានការអភិវឌ្ឍបានល្អប្រសើរយ៉ាងណាក៏ដោយ ក៏នៅតែមានបញ្ហាមួយចំនួនតូច ដែលជះឥទ្ធិពលអវិជ្ជមានទៅលើដំណើរការអភិវឌ្ឍនេះដូចជាៈ

- ទ្រឹស្តីសហគមន៍នេសាទជាទ្រឹស្តីថ្មី ពុំទាន់មានការអនុវត្តន៍ណាមួយឱ្យបានទូលំទូលាយនៅគ្រប់តំបន់នោះទេ ដែលជាធ្វើឱ្យការយល់ដឹងរបស់ប្រជាជននៅតាមតំបន់ភាគច្រើនមានការយល់ដឹងទាប ដែលជាហេតុធ្វើឱ្យមានការលំបាកក្នុងការរៀបចំ និងអនុវត្តន៍ទៅតាមស្ថានភាពជាក់ស្តែង។
- មានបទល្មើសនេសាទមួយចំនួន ដែលកើតមានឡើងដោយសារពួកអ្នកនេសាទមកពីក្រៅសហគមន៍នេសាទ ដែលលួចចូលនេសាទនៅដែននេសាទរបស់សហគមន៍។
- ការបាត់បង់ជីវៈចម្រុះ និងទីជម្រក
- ការកាប់បំផ្លាញព្រៃកោងកាង ដែលធ្វើឱ្យព្រៃកោងកាងប្រឈមនឹងការបាត់បន្តិចម្តងៗ។
- គ្រោះធម្មជាតិ ខ្យល់ព្យុះ ដែលធ្វើឱ្យមានផលលំបាកដល់ការនេសាទរបស់ប្រជាជន។
- បញ្ហាដែលធំចុងក្រោយដែលជាកង្វល់របស់សហគមន៍នេសាទ និងប្រជាពលរដ្ឋនៅក្នុងសហគមន៍ គឺក្រសួងទេសចរណ៍មានគម្រោងសាងសង់កំពង់ផែទេសចរណ៍អន្តរជាតិ ដែលគម្រោងសាងសង់នេះអាចធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី។

## ៣.៤. ដំណោះស្រាយចំពោះបញ្ហាប្រឈមនៃការអភិវឌ្ឍសហគមន៍នេសាទ

ដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ សហគមន៍នេសាទត្រពាំងសង្កែបានចាត់វិធានការដើម្បីដោះស្រាយបញ្ហាទាំងនេះដូចខាងក្រោមៈ

- សហគមន៍នេសាទបាន កោះហៅប្រជាពលរដ្ឋក្នុងសហគមន៍នេសាទមកពន្យល់បន្ថែម និងបានចាត់តាំងសមាជិកឱ្យចុះអប់រំបន្ថែមពាក់ព័ន្ធទ្រឹស្តី និងបទបញ្ញារបស់សហគមន៍នេសាទនៅតាមតំបន់នីមួយៗ ដើម្បីឱ្យពួកគាត់យល់កាន់តែច្បាស់ពីបញ្ហាទាំងនោះ។
- រៀបចំពេលវេលាល្បាតឱ្យបានត្រឹមត្រូវ ដើម្បីទប់ស្កាត់បទល្មើស និងកោះហៅអ្នកដែលលួចនេសាទខុសច្បាប់នោះមកណែនាំ និងធ្វើកិច្ចសន្យាហើយធ្វើការពន្យល់ពួកគាត់ឱ្យចូលជាសមាជិកសហគមន៍នេសាទ ដែលអាចឱ្យពួកគាត់នេសាទបានដោយស្របច្បាប់ គោរពតាមកិច្ចព្រមព្រៀង និងគោរពតាមលក្ខន្តិកៈរបស់សហគមន៍នេសាទ។

- ធ្វើការអប់រំពីផលប្រយោជន៍នៃព្រៃកោងកាង ដល់ប្រជាពលរដ្ឋឱ្យបានដឹង និងដឹកនាំឱ្យប្រជាជននាំគ្នាដាំកោងកាងឡើងវិញដើម្បីជួយការពារពីគ្រោះធម្មជាតិផងដែរ។
- សហគមន៍បានស្នើសុំឱ្យមានការជជែកគ្នារវាងស្ថាប័នពាក់ព័ន្ធ នឹងសុំឱ្យស្ថាប័នទាំងនោះចុះសិក្សាពីផលប៉ះពាល់ទាំងនោះ។

## ៣.៥. ការវិភាគ SWOT

ក្រោយពីបានធ្វើការចុះកម្មសិក្សា នៅក្នុងសហគមន៍នេសាទត្រពាំងសង្កែ ដែលស្ថិតនៅក្នុងស្រុកទឹកឈូ ខេត្តកំពត ពីការអភិវឌ្ឍរបស់សហគមន៍នេសាទត្រពាំងសង្កែរួចមក យើងខ្ញុំបានយល់ដឹងអំពីវិធីសាស្ត្រនៅក្នុងការធ្វើផែនការ យុទ្ធសាស្ត្រនៃការអភិវឌ្ឍ និងដំណើរការ នៃការអភិវឌ្ឍរបស់សហគមន៍នេសាទកាន់តែច្បាស់។ យើងខ្ញុំបានសង្កេតឃើញថា សហគមន៍នេសាទទាំងមូលក៏មាននូវ ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងកត្តាគំរាមកំហែងផងដែរ។ ចំណុចទាំងអស់នោះ ត្រូវបានធ្វើការវិភាគដូចខាងក្រោមនេះ៖

### ៣.៥.១. ការវិភាគលើចំណុចខ្លាំង

- មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់
- គណៈកម្មការមានទំនួលខុសត្រូវខ្ពស់ទៅលើតួនាទី និងភារកិច្ច ជាពិសេសប្រកាន់យកសុទិដ្ឋិនិយម
- មានផែនការសកម្មភាព យុទ្ធសាស្ត្រច្បាស់លាស់
- អនុវត្តន៍រាល់គម្រោងផែនការដែលបានគ្រោងទុក
- មានតម្លាភាពថវិកា
- ប្រជាជនយល់ដឹង និងចូលរួមលើការការពារធនធានក្នុងមូលដ្ឋានរបស់ខ្លួន
- ប្រជាជនមានចំណេះដឹងពីការការពារធនធានធម្មជាតិ និងអភិរក្សព្រៃកោងកាង
- ប្រជាជនគោរពលក្ខន្តិកៈច្បាប់ និងបទបញ្ញាផ្ទៃក្នុងច្រើន
- សមាជិកចូលរួមដោះស្រាយបទល្មើសនេសាទ
- មានសម្មទ្ធិផលច្រើន (តំបន់អភិរក្ស អេកូរទេសចរណ៍ជាដើម)
- មានមុខរបរសម្រាប់រកចំណូល(អេកូទេសចរណ៍)
- មានទំនាក់ទំនងល្អជាមួយអង្គការដៃគូម្ចាស់ជំនួយ
- ធនធានជលផលក្នុងសហគមន៍មានការកើនឡើងជាដើម។

### ៣.៥.២. ការវិភាគលើចំណុចខ្សោយ

- ចំណូលសហគមន៍មិនទៀងទាត់ (ប្រចាំថ្ងៃ)
- ថវិកាឧបត្ថម្ភមានរយៈពេលខ្លី (ថវិកាគម្រោង)
- ធនធាននៅមានកម្រិត (មនុស្ស ថវិកា និងសម្ភារៈ)
- ជីវភាពប្រជាជននៅមានកម្រិត
- ការចូលរួមគ្រប់គ្រងធនធាននៅមានកម្រិត
- ការអនុវត្តផែនការមានលក្ខណៈយឺតយ៉ាវ
- ការផ្សព្វផ្សាយ អប់រំទៅដល់ប្រជាជននៅមានកម្រិត
- ខ្វះខាតមធ្យោបាយ សម្ភារៈ និងថវិកាសម្រាប់បំរើការក្នុងសហគមន៍ ដូចជាការចុះយាមល្បាត និងផ្សព្វផ្សាយ អំពីលក្ខន្តិកៈបទបញ្ញត្តិសហគមន៍ ឬផ្សព្វផ្សាយព័ត៌មានផ្សេងៗ។

### ៣.៥.៣. ឱកាស

- មានការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលដូចជា CWDCC, FACT, ActionAid, FAO, និងអង្គការផ្សេងៗទៀត។
- ការសហការល្អពីអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ
- មានការស្ម័គ្រចិត្តចូលរួមការងារអភិរក្សធនធានធម្មជាតិក្នុងសហគមន៍ពីយុវជនខ្មែរ និងជនបរទេស។
- ទាក់ទាញការគាំទ្រពីអង្គការនានា ឬស្ថាប័នផ្សេង
- ទាក់ទាញភ្ញៀវទេសចរទៅលេងក្នុងសហគមន៍ ដោយសារមានការថែរក្សាដើមកោងកាងយ៉ាងស្រស់ស្អាតពីសហគមន៍នេសាទ។

### ៣.៥.៤. ការគំរាមកំហែង

- ការអន្តរាគមន៍ពីមន្ត្រីជំនាញនៅមានកម្រិត មិនទាន់ពេលវេលា
- ប្រជាជនមិនយល់ច្បាស់ពីបញ្ហាប្រឈមនៅពេលអនាគត
- មានការនេសាទល្មើសច្បាប់ពីអ្នកខាងក្រៅសហគមន៍
- ការចាក់ដីរំលោភលើដែនសហគមន៍ពីអ្នកមានអំណាច
- គម្រោងសាងសង់កំពង់ផែអន្តរជាតិដែលអាចប៉ះពាល់ដល់ជីវចំរុះ និងដែននេសាទរបស់សហគមន៍នេសាទជាដើម។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

យោងទៅតាមរបាយការណ៍នៃកម្មសិក្សាស្តីពី ការអភិវឌ្ឍរបស់សហគមន៍នេសាទត្រពាំងសង្កែដែលមានទីតាំងស្ថិតនៅ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត បានបង្ហាញឱ្យឃើញថា ដំណើរការនៃការអភិវឌ្ឍសហគមន៍នេសាទមានភាពល្អប្រសើរឡើងគួរឱ្យកត់សំគាល់ ចាប់តាំងពីការរៀបចំកកើតសហគមន៍នេសាទមក ដូចជាការកសាងនូវឯកសារបទដ្ឋានគតិយុត្តិ ការរៀបចំនូវរចនាសម្ព័ន្ធ ការបែងចែកតួនាទី ការរៀបចំផែនការ យុទ្ធសាស្ត្រអនុវត្តផែនការ និងផែនការគ្រប់គ្រងហរិញ្ញវត្ថុផងដែរ។ ជាក់ស្តែងសហគមន៍នេសាទត្រពាំងសង្កែ បានចូលរួមយ៉ាងខ្លាំងនៅក្នុងការអភិវឌ្ឍ ការអភិរក្ស និងជាពិសេសការអភិវឌ្ឍលើធនធានជលផលតាមតំបន់ដែននេសាទជាប្រព័ន្ធមួយប្រកបដោយនិរន្តភាព។

បន្ថែមពីនេះទៀត មានកត្តាជាច្រើនទៀតដែលជំរុញឱ្យសហគមន៍នេសាទត្រពាំងសង្កែមានការរីកចម្រើន គឺដោយសារតែមានការចូលរួម និងសហការល្អពីគណៈកម្មការសហគមន៍ប្រធានសហគមន៍ សមាជិក និងប្រជាពលរដ្ឋក្នុងការអនុវត្តផែនការសកម្មភាពទាំងឡាយរបស់សហគមន៍នេសាទបានយ៉ាងល្អ។ ជាពិសេសសហគមន៍នេសាទត្រពាំងសង្កែមានទំនាក់ទំនងល្អជាមួយ អាជ្ញាធររដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូផងដែរ។ មិនត្រឹមតែប៉ុណ្ណោះទេ សមាជិកសហគមន៍មានការយល់ដឹងខ្ពស់ និងបានចូលរួមរាល់ការបណ្តុះបណ្តាលបច្ចេកទេសរបស់ អង្គការដៃគូ និងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត។ តាមរយៈការសាកសួរប្រធានសហគមន៍នេសាទត្រពាំងសង្កែ បន្ទាប់ពីសមាជិកក្នុងសហគមន៍ និងប្រជាជននៅក្នុងសហគមន៍ បានយល់ដឹងពីបច្ចេកទេសធ្វើឱ្យពួកគេប្រើប្រាស់ឧបករណ៍នេសាទបានត្រឹមត្រូវ ហើយបានកាត់បន្ថយរាល់ការប្រព្រឹត្តិបទល្មើសនេសាទក្នុងដែនសហគមន៍ថែមទៀតផងដែរ។ រាល់សមិទ្ធិផលទាំងអស់នេះបានឱ្យឃើញពីការរីកចម្រើន ក្រោមការដឹកនាំល្អរបស់ប្រធានសហគមន៍នេសាទត្រពាំងសង្កែ និងសមាជិកសហគមន៍ទាំងអស់ក្នុងការអភិវឌ្ឍសហគមន៍នេសាទរបស់ពួកគេ។

សរុបសេចក្តីមក ការអភិវឌ្ឍរបស់សហគមន៍នេសាទត្រពាំងសង្កែ គឺបានដើរតួយ៉ាងសំខាន់ក្នុងគោលបំណងការពារ គ្រប់គ្រង ប្រើប្រាស់ អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិប្រកបដោយនិរន្តភាព ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រក្នុងសហគមន៍មូលដ្ឋាន ដែលស្របទៅតាមគោលនយោបាយរបស់រដ្ឋាភិបាលដើម្បីជួយអភិវឌ្ឍន៍ភូមិ ឃុំ ឱ្យមានការរីកចម្រើន។

## ២. ការផ្ដល់អនុសាសន៍

ដើម្បីជាយុទ្ធសាស្ត្រនៅក្នុងការអភិវឌ្ឍសហគមន៍នេសាទត្រពាំងសង្កែ ប្រកបដោយនិរន្តភាព យើងខ្ញុំសូមធ្វើការបញ្ចេញមតិ និងយោបល់នៅក្នុងគោលបំណងចូលរួមកែលម្អនូវចំណុះខ្វះខាតទាំងឡាយ ដើម្បីជួយសម្រួល និងពង្រឹងការអភិវឌ្ឍវិស័យជលផលនៅក្នុងសហគមន៍នេសាទត្រពាំងសង្កែឱ្យកាន់តែប្រសើរឡើង។

➢ **សហគមន៍នេសាទ**

- គួរតែផ្ដល់ការបណ្ដុះបណ្ដាលពង្រឹងសមត្ថភាព សមាជិកក្នុងសហគមន៍ក្នុងការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងការចូលរួមដោះស្រាយបញ្ហានៅក្នុងសហគមន៍នេសាទបន្ថែមទៀត។
- ជំរុញឱ្យគណៈកម្មការក្នុងភូមិទាំងអស់ធ្វើសកម្មភាពព្រមគ្នា និងចេះយោគយល់អធ្យាស្រ័យគ្នា ដើម្បីធ្វើការអភិវឌ្ឍសហគមន៍ឱ្យរីកចម្រើនបន្ថែមទៀត។
- ខិតខំប្រឹងប្រែងទាក់ទាញក្រសួងពាក់ព័ន្ធ និងបណ្ដាញអង្គការអភិវឌ្ឍន៍នានាដើម្បីស្វែងរកប្រភពជំនួយផ្សេងៗ សំរាប់ទ្រទ្រង់ការអភិវឌ្ឍសហគមន៍បន្ថែមទៀត។

➢ **ប្រជាពលរដ្ឋ**

- ត្រូវចាប់យកឱកាស ពង្រឹងស្មារតីក្នុងការធ្វើឱ្យសហគមន៍របស់ខ្លួនជាអង្គភាពមាននិរន្តភាព។
- ចូលរួមអនុវត្តន៍ច្បាប់ រាយការណ៍ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទដោយការប្រើប្រាស់ឧបករណ៍ខុសច្បាប់។
- លះបង់ពេលវេលាមួយចំណែក សម្រាប់ទទួលយកចំណេះដឹង ជំនាញនានាដែលសហគមន៍បានរៀបចំ។
- ចូលរួមសកម្មភាពថែរក្សាអភិរក្ស ការពារធនធានធម្មជាតិ ជាពិសេសព្រៃកោងកាងនៅក្នុងសហគមន៍នេសាទឱ្យបានគង់យូរអង្វែង។

➢ **ផ្នែករដ្ឋបាលជលផល និងអាជ្ញាធរមូលដ្ឋាន**

- ត្រូវជួយពង្រឹងការផ្សព្វផ្សាយ និងការអនុវត្តន៍ច្បាប់ដល់ប្រជាពលរដ្ឋដែលទាក់ទងពីសារៈសំខាន់នៃធនធានធម្មជាតិ និងការអភិរក្សនៅតាមសហគមន៍នេសាទ។
- ជួយគាំទ្រថវិកា និងផ្គត់ផ្គង់សម្ភារៈ បច្ចេកទេសផ្សេងៗ ដើម្បីអភិវឌ្ឍសហគមន៍ប្រកបដោយប្រសិទ្ធិភាព។

- ចុះជួអន្តរាគមន៍ និងដោះស្រាយសកម្មភាពបទល្មើសនេសាទឱ្យទាន់ពេលវេលា។
- បង្កើនការផ្សព្វផ្សាយស្តីពីការអភិវឌ្ឍសហគមន៍នេសាទ ការគ្រប់គ្រង ការអភិរក្ស និងការការពារធនធានធម្មជាតិ។
- គួរតែបង្កើនកិច្ចសហការគ្នាបន្ថែមរវាងស្ថាប័នជំនាញ ស្ថាប័នពាក់ព័ន្ធផ្សេងៗ និងអាជ្ញាធរមូលដ្ឋានឱ្យបានច្រើន។
- ត្រូវមានវិធានការណ៍ច្បាស់លាស់ ដើម្បីធ្វើការបណ្តុះបណ្តាលដល់គណៈកម្មការសហគមន៍នេសាទ។

➢ **អង្គការក្រៅរដ្ឋាភិបាល**

- កសាងសមត្ថភាពបន្ថែមលើការងាររដ្ឋបាលដល់សហគមន៍ និងគណនេយ្យដល់គណៈកម្មការសហគមន៍។
- បន្តការផ្តល់ជំនួយគាំទ្រដល់សហគមន៍នេសាទក្នុងប្រទេសកម្ពុជា និងជួយស្វែងរកអង្គការដៃគូរអភិវឌ្ឍន៍ផ្សេងៗទៀត។

# ឯកសារយោង


- ឃីម ចាន់ល័ក្ខ និងឈុន សិរីចណ្ណ, ២០១៦, *ការអភិវឌ្ឍរបស់សហគមន៍នេសាទកំពុងត្រឡាចលើ,* របាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- នួន វណ្ណា, ឆៃលាង បញ្ញា និងឯម វណ្ណារ៉ា, ២០០៦, *គំរោងអភិវឌ្ឍន៍សហគមន៍អ្នកក្រីក្រក្នុងរាជធានីភ្នំពេញ,* របាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ស្រ៊ន វត្ថុ និងហេង រ៉ាំបូ, *ការអភិវឌ្ឍសហគមន៍ចម្រុះរបស់អង្គការការីតាស កម្ពុជា នៅឃុំព្រែក ឬស្សី ស្រុកល្វាឯម ខេត្តកណ្ដាល,*របាយរបាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ស៊ុត សុជាមុនីរត្ន និងស៊ាង សុខ, ២០១១, *ការអភិវឌ្ឍសហគមន៍របស់អង្គការស៊ីស៊ីឌីដើម្បីកាត់បន្ថយភាពក្រីក្រក្នុងខេត្តក្រចេះ,* របាយរបាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ទ្បៅ ធន់សោភ័ណ្ឌ និងអន សុខអេង, ២០១១, *ការអភិវឌ្ឍសហគមន៍នៅក្នុងភូមិព្រៃទទឹង,*របាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- សែម ឡុងឌី និងយឹង មឿន, ២០០៧, *ការអភិវឌ្ឍន៍សហគមន៍តាមរយៈកសិកម្មចំរុះ,* របាយរបាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ៥ឆ្នាំលើកទី២ (២០០១-២០០៥) ក្រសួងអភិវឌ្ឍន៍ជនបទឆ្នាំ ២០០០។
- ច្បាប់ស្តីពីជលផល, ២០០៧។
- អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ, ២០០៥។
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨, រាជរដ្ឋាភិបាលកម្ពុជា។
- នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ, រដ្ឋបាលជលផល,(២០០៧) ។ អាចរកបាននៅ http://www.fia.gov.kh/khmer/index.php?page=cfdd (ចូលមើលថ្ងៃទី ០១ ឧសភា ២០១៩)
- កម្រងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងសហគមន៍នេសាទនៅកម្ពុជា, ២០០៨ រៀបចំដោយរដ្ឋបាលជលផល។
- Jonh Repley. (2007) Understanding Development: Theory and Practice in the Third Word, Third Edition. Boulderl, Colorado; Lynne Rienner.

- Michael P. Todaro, & Stephen C. Smith. (2009). Economic Development 11th Edition. Boston; Peason, Addison-Wesley.
- https://Regional-Economic-Development-Francois-Perroux/dp/ (ចូលមើលថ្ងៃទី ០១ ឧសភា ២០១៩) ។
- https://en.wikipedia.org/wiki/Rural-Community-Development (ចូលមើលថ្ងៃទី ០១ ឧសភា ២០១៩) ។
- http://aquaticcommons.org/2496/1/CFDOStrategicPlan_opt.pdf (ចូលមើលថ្ងៃទី ០៣ ឧសភា ២០១៩) ។
- https://opendevelopmentcambodia.net/topics/community-fisheries/ (ចូលមើលថ្ងៃទី ០៣ ឧសភា ២០១៩) ។
- http://fia.maff.gov.kh/newsdetail/skvYflaFbf (ចូលមើលថ្ងៃទី ០៣ ឧសភា ២០១៩)។
- http://www.fia.gov.kh/khmer/index.php?page=cfdd&fbclid=IwAR3DON0MDeu7jnczivRVa_YaCMztGYmNs3uQCwHtfPbgyvBTEWDeHd3SIto (ចូលមើលថ្ងៃទី ០៥ ឧសភា ២០១៩) ។

# បញ្ជីសំណួរពាក់ព័ន្ធការស្រាវជ្រាវ
# សំរាប់ធ្វើការសម្ភាសន៍នៅក្នុងសហគមន៍នេសាទត្រពាំងសង្កែ

១. ស្ថានភាពទូទៅរបស់សហគមន៍នេសាទត្រពាំងសង្កែ

- ប្រវត្តិ និងទីតាំងភូមិសាស្ត្ររបស់សហគមន៍នេសាទ
- រចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍នេសាទ
- ទស្សនៈវិស័យ បេសកម្ម សកម្មភាព និងគោលដៅរួម
- មូលនិធិពីតាមស្ថាប័ននីមួយៗ
- សមិទ្ធិផលរបស់សហគមន៍
- ស្ថានភាពសហគមន៍នេសាទមុនពេល និងក្រោយពេលបង្កើតសហគមន៍។

២. តើប្រជាពលរដ្ឋដែលនៅក្នុងសហគមន៍ទទួលបានផលអ្វីខ្លះ?

៣.តើប្រជាពលរដ្ឋទទួលបានឱកាសការងារយ៉ាងដូចម្តេចខ្លះ?

៤. តើប្រជាពលរដ្ឋទទួលបានចំណេះដឹងទូទៅ និងជំនាញអ្វីខ្លះពីសហគមន៍?

៥.តើប្រជាពលរដ្ឋទទួលបាននូវសេវានៃការបង្កើតមុខរបរថ្មីអ្វីខ្លះ?

៦.តើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាពាក់ព័ន្ធផ្សេងៗមានអ្វីខ្លះ?

៧. តើប្រជាពលរដ្ឋមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្តអ្វីខ្លះ?

៨. តើប្រជាពលរដ្ឋមានជីវភាពដូចម្តេចនៅពេលដែលបានបង្កើតសហគមន៍ឡើង?

៩. តើសហគមន៍មានគម្រោងអភិវឌ្ឍន៍អ្វីខ្លះបន្តទៀត?

១០. តើសហគមន៍មានគោលនយោបាយអភិវឌ្ឍដូចម្តេចខ្លះ?

១២. តើលក្ខន្តិកៈ និងបទបញ្ជានៅក្នុងសហគមន៍ត្រូវបានរៀបចំឡើងដូចម្តេច?

១១. តើសហគមន៍មានផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍អ្វីខ្លះ?

១២. តើសហគមន៍មានបញ្ហាប្រឈមអ្វីខ្លះដែលជួបប្រទះ?

១៣. តើសហគមន៍ដោះស្រាយបញ្ហាទាំងនោះដោយរបៀបណាខ្លះ?

១៤. តើប្រជាពលរដ្ឋពេញចិត្តចំពោះគោលនយោបាយ និងការអភិវឌ្ឍរបស់សហគមន៍ដែរឬទេ?

១៥. តើស្ថាប័នពាក់ព័ន្ធមាមការវាយតម្លៃទៅលើសហគមន៍នេះយ៉ាងដូចម្តេច?

១៦. តើសហគមន៍មានទិសដៅអភិវឌ្ឍន៍បន្តសម្រាប់រយៈពេល៥ឆ្នាំខាងមុខអ្វីខ្លះ?

## សកម្មភាពសម្ភាសន៍ជាមួយប្រធានសហគមន៍ លោក សឹម ហ៊ីម ( អាចយឺតពណ៌ស )





# ផលនេសាទនៅក្នុងសហគមន៍នេសាទត្រពាំងសង្កែ





# សកម្មភាពចុះល្បាតនៅពេលយប់របស់សហគមន៍នេសាទ





# សកម្មភាពជួសជុល និងកសាងផ្លូវចូលក្នុងសហគមន៍នេសាទ





សកម្មភាពគណៈកម្មការសហគមន៍នេសាទប្រជុំ និងដោះស្រាយបញ្ហាក្នុងសហគមន៍



សកម្មភាពពន្យល់ណែនាំបន្ថែមអំពីលក្ខន្តិកៈ និងដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ



# លិខិតសរសើរពីរដ្ឋបាលជលផលក្នុងការអភិវឌ្ឍសហគមន៍



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
រដ្ឋបាលជលផល

លិខិតសរសើរ

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ និងកោតសរសើរចំពោះលោក **ស៊ឹម ហ៊ឹម** ប្រធានគណៈកម្មការសហគមន៍នេសាទ និងលោក លោកស្រីដែលជាគណៈកម្មការព្រមទាំងសមាជិកសហគមន៍នេសាទត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូរ ខេត្តកំពត ដែលមានស្នាដៃល្អក្នុងការចូលរួម គ្រប់គ្រង ថែរក្សាការពារ និងអភិរក្សធនធានជលផលក្នុងសហគមន៍បានយ៉ាងល្អប្រសើរ។

រដ្ឋបាលជលផលសូមគាំទ្រ និងលើកទឹកចិត្តដល់សហគមន៍នេសាទ ក្នុងការបន្តដំណើរសកម្មភាពនេះតទៅមុខទៀត និងសូមជូនពរដល់លោក លោកស្រីដែលជាគណៈកម្មការព្រមទាំងសមាជិកសហគមន៍នេសាទត្រពាំងសង្កែ ប្រកបដោយសិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ខែធ្នូ ឆ្នាំ២០១៣
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល

# ម្ចាស់ជំនួយពីអង្គការនានា និងស្ថាប័នរដ្ឋ

